CDA COLLABORATIVE LEARNING PROJECTS

# គំរោងស្តាប់មតិយោបល់ (LISTENING PROJECT)

## របាយការណ៍ស្តីពីទស្សនកិច្ចមូលដ្ឋាន

Cambodia

November 2007

COLLABORATIVE LEARNING PROJECTS

ការចងក្រងឯកសារនេះ ជាចំណែកមួយនៃគំរោងសហប្រតិបត្តិការស្តាប់មតិយោបល់ (collaborative listening project) ដែលដឹកនាំដោយ CDA ហើយក៏ជាផ្នែកមួយនៃសំណុំឯកសារដែលអាចចាត់ទុកថា ជាការរកឃើញដំបូងខ្លះៗរបស់គំរោង។ ឯកសារទាំងនេះបានរៀបរៀងឡើង ដើម្បីកំណត់បញ្ហា និងប្រធានបទអន្តរវិស័យដែលទាក់ទងទៅនឹងស្ថានភាពមួយចំនួន។ ករណីនីមួយៗគឺជាទស្សនៈ និងគំនិតរបស់មនុស្សម្នាក់ៗ ក្នុងពេលរៀបរៀងឯកសារនេះឡើង។

**ឯកសារនេះ ពុំមែនជាលទ្ធផលចុងក្រោយរបស់គំរោងទេ។** បើទោះជាឯកសារនេះ អាចដកស្រង់ជាឯកសារយោងបាន តែក៏នៅជាឯកសារការងារ (working paper) នៃកិច្ចសហប្រតិបត្តិការប្រឹងប្រែងសិក្សាដែរ។ គេពុំអាចបកស្រាយជាទូទៅ ពីការរកឃើញគំរោងទាំងមូល ចេញពីករណីជាក់លាក់ណាមួយនោះបានឡើយ។

CDA សូមថ្លែងអំណរគុណដល់បុគ្គល និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងឆន្ទៈក្នុងការចែករំលែកបទពិសោធន៍ និងមតិយោបល់របស់ខ្លួន សម្រាប់របាយការណ៍នេះ។

ឯកសារគំរោងទាំងអស់ មិនមែនសុទ្ធតែផ្សព្វផ្សាយជាសាធារណៈទេ។ បើសិនជារបាយការណ៍ធ្វើឡើងនៅក្នុងតំបន់ណាមួយ ដែលមានការស្នើសុំឱ្យការពារភាពអនាមិក និងសុវត្ថិភាពរបស់ពួកគេ យើងរក្សាឯកសារទាំងនោះជាលក្ខណៈផ្ទាល់ខ្លួន ដើម្បីការពារដល់បុគ្គល និងសហគមន៍ដែលបានចូលរួម។

# សាវតារគំរោងស្តាប់មតិយោបល់

គំរោងកិច្ចសហប្រតិបត្តិការសិក្សារបស់ CDA រួមជាមួយដៃគូមួយចំនួន ក្នុងអង្គការជាតិ អន្តរជាតិ ព្រមទាំងម្ចាស់ជំនួយ ទីភ្នាក់ងារជំនួយមនុស្សធម៌ និងទីភ្នាក់ងារអភិវឌ្ឍន៍ផ្សេងទៀត បានផ្តួចផ្តើមគំរោងស្តាប់មតិយោបល់នេះឡើង ដើម្បីស្វែងយល់ឱ្យបានទូលំទូលាយជាលក្ខណៈប្រព័ន្ធ អំពីទស្សនៈ និងការយល់ឃើញរបស់ប្រជាជន ដែលរស់នៅក្នុងសង្គមជាភាគីអ្នកទទួលជំនួយអន្តរជាតិ។ គំរោងស្តាប់មតិយោបល់ ស្វែងរកទស្សនៈពីអ្នកមានបទពិសោធន៍ និងមានការពិចារណាខ្ពស់ ព្រមទាំងមានមុខតំណែងផ្សេងៗ នៅក្នុងសង្គមនៃប្រទេសអ្នកទទួលជំនួយ ដើម្បីវាយតម្លៃ ពីឥទ្ធិពល នៃកិច្ចប្រឹងប្រែងរបស់អ្នកផ្តល់ជំនួយអន្តរជាតិ។ អ្នកដែលឆ្លងកាត់ព្រំដែន ដើម្បីបំពេញការងារជំនួយមនុស្សធម៌ ជំនួយអភិវឌ្ឍន៍ កិច្ចប្រឹងប្រែងកសាងសន្តិភាព ការអភិរក្សបរិស្ថាន និងសិទ្ធិមនុស្ស អាចរៀនសូត្របានយ៉ាងច្រើន ដោយស្តាប់ការវិភាគ និងការវិនិច្ឆ័យរបស់ប្រជាជនក្នុងប្រទេសទាំងនេះ ដែលពួកគេឆ្លុះបញ្ចាំងអំពីលទ្ធផលភ្លាមៗ និងឥទ្ធិពលរយៈពេលវែងនៃកិច្ចប្រឹងប្រែងទាំងនោះ។

ក្រុមអ្នកស្តាប់មតិយោបល់ពុំបានធ្វើការងាររបស់ខ្លួន ដោយផ្អែកលើកម្រងសំណួរដែលបានរៀបចំជាមុន ឬពិធីសារសម្ភាសន៍ ដែលរឹងត្អឹងឡើយ។ ផ្ទុយទៅវិញ យើងប្រាប់ប្រជាជនថា ក្នុងនាមជាអ្នកចូលរួមនៅក្នុងការងារជំនួយអន្តរជាតិ យើងចង់ស្តាប់ពីពួកគេថា តើពួកគេយល់ឃើញដូចម្តេចចំពោះកិច្ចប្រឹងប្រែងទាំងនេះ? យើងសួរពួកគេថា តើពួកគេអាចចំណាយពេលខ្លះប្រាប់យើងអំពីទស្សនៈ និងគំនិតរបស់ពួកគេបានដែរឬទេ? តាមវិធីសាស្ត្រនេះ យើងអាចធានាបាន ការជជែកអំពីបញ្ហានៃការព្រួយបារម្ភរបស់ពួកគេ ដោយមិនកំណត់ប្រធានបទជាក់លាក់ជាមុនឡើយ។ យើងចង់ឱ្យអ្នកដែលសន្ទនាជាមួយយើង ផ្តួចផ្តើមគំនិតលើកឡើងអំពីបញ្ហាទាំងឡាយ ដែលពួកគេព្រួយបារម្ភបំផុត ទាក់ទងនឹងកិច្ចប្រឹងប្រែងជំនួយអន្តរជាតិ។

កិច្ចសន្ទនាភាគច្រើន ធ្វើឡើងជាមួយបុគ្គលម្នាក់ ឬពីរនាក់។ ប៉ុន្តែនៅក្នុងករណីខ្លះ មានការបង្កើតជាក្រុមធំ ហើយការចាប់ផ្តើមសន្ទនាក្រុមតូច ក៏បានក្លាយជាការពិភាក្សាដោយសេរី។ ជាទូទៅ មិនមានការរៀបចំទុកជាមុនទេ (លើកលែងតែការណាត់ជួបជាមួយមន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀត)។ ក្រុមអ្នកស្តាប់មតិយោបល់បានធ្វើដំណើរទៅតាមសហគមន៍ និងធ្វើការជជែកជាមួយអ្នកណាក៏ដោយ ដែលមានពេល និងចង់ពិភាក្សា ដោយស្តាប់មតិទាំងអ្នកដែលបានទទួល និងមិនបានទទួលជំនួយអន្តរជាតិ។

ក្នុងរយៈពេលបីឆ្នាំ គំរោងស្តាប់មតិយោបល់ នឹងបំពេញទស្សនកិច្ចចំនួន២0 ដែលរហូតមកទល់ពេលនេះ កម្ពុជាគឺជា ទស្សនកិច្ចទី១១ហើយ។ គំរោងនេះប្រមូល និងវិភាគអ្វីដែលស្តាប់ឮពីប្រជាជននៅក្នុងតំបន់ទាំងនេះ ដើម្បីបញ្ចូល

ទស្សនៈទាំងនោះ ទៅក្នុងការងារជំនួយនៅពេលអនាគត និងធ្វើឱ្យល្អប្រសើរឡើងនូវប្រសិទ្ធភាពជំនួយ។

គំរោងស្តាប់មតិយោបល់ ក៏ដូចជា ដំណើរការកិច្ចសហប្រតិបត្តិការសិក្សាទាំងឡាយ ពឹងផ្អែកទាំងស្រុងលើ ការចូលរួម និងរួមចំណែកប្រកបដោយអត្ថន័យរបស់អ្នកពាក់ព័ន្ធទាំងអស់។ អ្នកចូលរួមនៅកម្ពុជា គួរតែទទួលបាននូវការកោតសរសើរយ៉ាងខ្លាំង ចំពោះការគាំទ្រយ៉ាងស្មោះស្ម័គ្រ ការបញ្ចេញគំនិតយោបល់ ព្រមទាំងការលះបង់ពេលវេលារបស់ពួកគេចូលរួមនៅក្នុងកិច្ចប្រឹងប្រែងនេះ។

## គំរោងស្តាប់មតិយោបល់នៅកម្ពុជា

គំរោងស្តាប់មតិយោបល់ បានសហការជាមួយអង្គការជាតិ（LNGOs）និងអន្តរជាតិ (IOs) មួយចំនួននៅកម្ពុជា រៀបចំការប្រជុំពិភាក្សាអំពីការស្តាប់មតិយោបល់ ដែលមានរយៈពេល១២ថ្ងៃ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៧។ ការប្រជុំពិភាក្សានេះ បានរៀបចំឡើងដោយអង្គការអុកស្វាមអាមេរិក (Oxfam America) និងឧបត្ថម្ភដោយបុគ្គលិក និងរួមចំណែកថវិកាពីអង្គការអេកសិនអេដ (Action Aid) គណៈកម្មាធិការសេវាមិត្តអាមេរិក (AFSC) គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (CCHR) ដៃគូអភិវឌ្ឍន៍សកម្មភាព (DPA) អង្គការហេលិនខិលល័រអន្តរជាតិ (HKI) អង្គការស្មាមញញឹមនៃកុមារ (PSE) និងមូលនិធិអាស៊ី (TAF)។ ជនជាតិកម្ពុជាចំនួន១០នាក់ និងជនបរទេសចំនួន០៧នាក់ រួមទាំងបុគ្គលិកម្នាក់ និងទីប្រឹក្សាបច្ចេកទេស០២នាក់មកពី CDA បានចូលរួមនៅក្នុងការប្រជុំ ស្តីពីការស្តាប់មតិយោបល់នេះ។

ក្រុមអ្នកស្តាប់មានចំនួនប្រាំក្រុម ដែលក្នុងមួយក្រុមមានសមាជិកពី ០៣ ទៅ០៤ នាក់ ដែលរួមមានបុគ្គលិកអង្គការអន្តរជាតិ០១នាក់ និងបុគ្គលិកខ្មែរ០២ ឬ០៣នាក់ ព្រមទាំងអ្នកបកប្រែម្នាក់ដែលជួលពីខាងក្រៅ។ ក្រុមការងារទាំងនេះបានស្តាប់មតិយោបល់ប្រជាជននៅក្នុងខេត្ត-ក្រុងចំនួន០៥ គឺបាត់ដំបង កំពត មណ្ឌលគីរី ព្រមទាំងក្នុង និងជុំវិញក្រុងភ្នំពេញ។ តំបន់ទាំងនេះត្រូវបានជ្រើសរើសដោយ CDA និងទីភ្នាក់ងារចូលរួម ដោយផ្អែកលើភាពខុសប្លែកគ្នាក្នុងការទទួលបានជំនួយអន្តរជាតិ ស្ថានភាពសង្គម និងសេដ្ឋកិច្ច ភាពខុសគ្នានៃជនជាតិ និងស្ថានភាពជនបទ និងទីក្រុង។ ដោយឡែកខេត្តបាត់ដំបងត្រូវបានជ្រើសរើស ដោយសារខេត្តនេះទទួលបានជំនួយអន្តរជាតិយ៉ាងច្រើនគួរកត់សំគាល់ និងមានជនមាតុភូមិនិវត្តន៍មកតាំងទីលំនៅច្រើន។ ចំណែកខេត្តមណ្ឌលគីរីត្រូវបានជ្រើសរើស ដោយសារខេត្តនេះនៅឆ្ងាយដាច់ស្រយាល មិនទាន់មានជំនួយទៅដល់មុនឆ្នាំ២០០២ និងជាតំបន់មួយដែលអាចស្តាប់មតិយោបល់របស់ជនជាតិដើមភាគតិចព្នង។ ខេត្តពោធិ៍សាត់ទទួលបានជំនួយអន្តរជាតិច្រើនប្រភេទ រាប់បញ្ចូលទាំងកម្មវិធី ដែលផ្តោតលើកិច្ចការពារបរិស្ថាន។ ខេត្តកំពតផ្តល់ឱកាសឱ្យយើងបានស្តាប់មតិយោបល់ពីប្រជាជន ដែលទទួលជំនួយមនុស្សធម៌ជាច្រើនលើក ដែលមួយផ្នែកបណ្តាលមកពីជួបគ្រោះទឹកជំនន់ជាប្រចាំ។

នៅក្នុងខេត្តនីមួយៗ ភ្នាក់ងារមូលដ្ឋានបានស្ម័គ្រចិត្តចំណាយពេលវេលារបស់ខ្លួន ក្នុងការជួយសម្រួលការងារ

របស់ក្រុមអ្នកស្តាប់មតិយោបល់។ ពេលវេលា និងកិច្ចប្រឹងប្រែងជាច្រើនថ្ងៃរបស់ពួកគេ មានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការផ្តល់ដល់ក្រុមអ្នកស្តាប់មតិយោបល់ នូវព័ត៌មានទំនាក់ទំនង និងការចូលជួបក្រុមប្រជាជនផ្សេងៗ រាប់បញ្ចូលទាំង អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ជនមាតុភូមិនិវត្តន៍ ជនជាតិភាគតិចដែលរស់នៅតំបន់ដាច់ស្រយាល ជនប្តូរលំនៅថ្មីទៅជាយក្រុងភ្នំពេញ ប្រជាជនរស់នៅក្នុងភូមិបណ្តែតទឹក និងប្រជាជនដទៃទៀត។ ការជួយជ្រោមជ្រែងរបស់ពួកគេ ក៏បានជួយឱ្យក្រុមការងារចៀសផុតពីភាពលំអៀង ពេលចុះទៅកាន់តំបន់គំរោង និងភូមិដែលសមាជិកក្រុមអ្នកស្តាប់មតិយោបល់មិនស្គាល់ផងដែរ។ ទីភ្នាក់ងារ/អង្គការក្នុងស្រុកទាំងនេះ រួមមាន អង្គការអាហ្វីស៊ីបកម្ពុជា (AFESIP Cambodia) អង្គការអនាគតកុមារ អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ មន្ទីរបរិស្ថានខេត្តពោធិ៍សាត់ អង្គការសត្វ និងរុក្ខជាតិអន្តរជាតិ (Fauna and Flora International) ក្រុមសម្ព័ន្ធភាពសកម្មភាពនេសាទ (FACT) អង្គការពុទ្ធិកុមារ (PKO) សមាគមអភិវឌ្ឍន៍ជនបទ (RDA) សមាគមថែទាំសុខភាពគ្រួសារកម្ពុជា (RHAC) អង្គការសង្គ្រោះសត្វព្រៃ (SCW) គំរោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម (SME-Renewable) និងសមាគមអភិរក្សសត្វព្រៃ (WCS)។

នៅក្នុងខេត្តទាំងប្រាំនេះ ក្រុមការងារបានធ្វើការពិភាក្សាប្រមាណ១១៤លើក ជាមួយប្រជាជនចំនួន២២២នាក់។ ក្រុមអ្នកស្តាប់មតិយោបល់ រក្សានូវតុល្យភាពសមស្របក្នុងការពិភាក្សាជាមួយស្ត្រី និងបុរស ព្រមទាំងព្យាយាមជួបជាមួយទាំងយុវជន និងចាស់ទុំ ដោយភាគច្រើនមានអាយុចន្លោះពី៣០ ដល់ ៥៥ឆ្នាំ។ ក្រុមការងារបានស្តាប់មតិយោបល់ភាគច្រើនពីជនជាតិខ្មែរ ប៉ុន្តែនៅខេត្តមណ្ឌលគិរី យើងបានព័ត៌មានជាច្រើនពីជនជាតិភាគតិច។ ក្រុមអ្នកស្តាប់មតិយោបល់បានខិតខំប្រឹងប្រែងដើម្បីចូលទៅដល់តំបន់ដាច់ស្រយាល ហើយភាគច្រើននៃការសន្ទនា បានធ្វើឡើងនៅតាមភូមិជនបទ តែមានក្រុមការងារមួយក្រុម បានទទួលភារកិច្ចពិសេសឱ្យជួបពិភាក្សាជាមួយប្រជាជនដែលរស់នៅក្នុង និងជាយក្រុងភ្នំពេញ។

ក្រុមការងារ បានជួបជាមួយបុគ្គលផ្សេងៗជាច្រើន មានតាំងពីសមាជិកសភា មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ អាជីវករ កសិករ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រធានភូមិ ព្រមទាំងអ្នកដឹកនាំសាសនា។ សមាជិកក្រុមការងារក៏បានជួបជាមួយអ្នកពាក់ព័ន្ធនៅក្នុងកិច្ចប្រឹងប្រែងជំនួយបរទេស រាប់បញ្ចូលទាំងបុគ្គលិកអង្គការជាតិ និងអន្តរជាតិ ស្ថាប័នសិក្សាស្រាវជ្រាវ ក្រុមសិទ្ធិមនុស្ស និងអ្នកស្រាវជ្រាវជាលក្ខណៈបុគ្គល ព្រមទាំងបុគ្គលិកអង្គការសហប្រជាជាតិ និងក្រសួង/ស្ថាប័នរដ្ឋាភិបាល ដែលសម្របសម្រួល និងអនុវត្តជំនួយបរទេសនៅកម្ពុជាផងដែរ។ នៅថ្នាក់ភូមិ ក្រុមអ្នកស្តាប់មតិយោបល់ បានជួបជាមួយទាំងអ្នកដែលបាន និងមិនបានទទួលជំនួយ។ នៅក្នុងតំបន់ជនមាតុភូមិនិវត្តន៍រស់នៅ សមាជិកក្រុមអ្នកស្តាប់មតិយោបល់ បានជួបជាមួយអតីតជនភៀសខ្លួន និងប្រជាជនរស់នៅក្នុងសហគមន៍ជិតខាង ដែលមិនបានទទួលជំនួយលើការធ្វើសមាហរណកម្ម។

ការសន្ទនាបានធ្វើឡើយជាលក្ខណៈបុគ្គល នៅក្រៅផ្ទះ និងក្រៅផ្លូវការ។ ពេលខ្លះ ក្រុមការងារបានជួបប្រជុំ

ជាមួយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប៉ុន្តែជាទូទៅ យើងជៀសវាងការពិភាក្សាជាផ្លូវការ។ ក្រុមអ្នកស្តាប់មតិយោបល់ប្រើវិធីសាស្ត្រជួបដោយចៃដន្យ ក្នុងការកំណត់អ្នកចូលរួម ដោយសុំជួបពិភាក្សាជាមួយប្រជាពលរដ្ឋនៅក្រៅផ្ទះរបស់ពួកគេ នៅតាមផ្លូវ ឬនៅពេលលក់ទំនិញ។ មុនដំបូង ប្រជាពលរដ្ឋមួយចំនួន រួញរាមិនចង់ពិភាក្សាជាមួយក្រុមអ្នកស្តាប់មតិយោបល់ទេ ប៉ុន្តែនៅពេលដែលកាន់តែមានភាពជិតស្និទ្ធ និងយល់ពីគ្នាទៅវិញទៅមក ពួកគេកាន់តែនិយាយបើកចំហឡើង។

បើទោះបីជា បានពិភាក្សាជាមួយមនុស្សច្រើនជាង២០០នាក់ និងមានការចូលរួមពីប្រជាជនខ្មែរពីមជ្ឈដ្ឋានជាច្រើនក៏ដោយ ក៏គំរោងស្តាប់មតិយោបល់ទទួលស្គាល់ថា នៅមិនទាន់បានបញ្ចូលមតិយោបល់ជាច្រើនទៀត។ របាយការណ៍នេះ បង្ហាញពីប្រធានបទ និងសណ្ឋានជាទូទៅនៃកិច្ចពិភាក្សា ប៉ុន្តែមិនអាចតំណាងមតិយោបល់ ជំនឿ និងអារម្មណ៍របស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់បានឡើយ។

## ការសង្ខេបពីនិជ្ជភាពទូទៅនៃជំនួយនៅកម្ពុជា

ក្រោយពីបានទទួលឯករាជ្យពីបារាំងនៅក្នុងឆ្នាំ១៩៥៤ រដ្ឋាភិបាលកម្ពុជា បានផ្តួចផ្តើមគំនិតអភិវឌ្ឍន៍តាមរយៈជំនួយទ្វេភាគីរហូតដល់ឆ្នាំ១៩៧០។ រយៈពេលប្រាំឆ្នាំក្រោយមក ជំនួយទ្វេភាគីបានបញ្ចប់ ហើយអង្គការមិនមែនរដ្ឋាភិបាល បានដើរតួនាទីដ៏សំខាន់ ក្នុងការជួយជនរងគ្រោះនៃសង្គ្រាមមិនប្រកាសរបស់កម្ពុជា។ បន្ទាប់ពីខ្មែរក្រហមបានឡើងកាន់អំណាចនៅក្នុងឆ្នាំ១៩៧៥ អំពើប្រល័យពូជសាសន៍បានកើតឡើង រាល់ជំនួយពីខាងក្រៅត្រូវកាត់ផ្តាច់។ នៅក្នុងរបបនេះ រាល់ដំណើរការអភិវឌ្ឍន៍ ដែលកម្ពុជាបានធ្វើពីមុនបានត្រូវបញ្ចប់។ អ្នកចេះដឹង បញ្ញាវន្ត ស្ថិតក្នុងចំណោមប្រជាជនកម្ពុជាប្រមាណ១,៦លាននាក់ ស្មើនឹងប្រមាណ២០ភាគរយនៃប្រជាជនសរុប ត្រូវសម្លាប់ដោយខ្មែរក្រហម។ នៅសម័យខ្មែរក្រហម ប្រជាជនខ្មែររាប់សែននាក់បានរត់ភៀសខ្លួនទៅប្រទេសថៃ ហើយកិច្ចប្រឹងប្រែងជំនួយសង្គ្រោះបានដោះស្រាយតម្រូវការរបស់ជនភៀសខ្លួនទាំងនោះ។ ក្នុងរយៈពេលម្ភៃឆ្នាំក្រោយមក ប្រជាជនខ្មែរជាង២០០ ០០០ នាក់ បានផ្លាស់ប្តូរទីលំនៅ ដែលភាគច្រើនបានទៅរស់នៅសហរដ្ឋអាមេរិក ហើយជនភៀសខ្លួននៅសល់បានធ្វើមាតុភូមិនិវត្តន៍មកកាន់កម្ពុជាវិញនៅពាក់កណ្តាលទសវត្សរ៍ទី៩០។

នៅពេលដែលពួកខ្មែរក្រហមត្រូវទម្លាក់ពីអំណាចនៅក្នុងឆ្នាំ១៩៧៩ កិច្ចប្រឹងប្រែងផ្តល់ជំនួយអន្តរជាតិ បានកើនឡើងយ៉ាងខ្លាំង។ ខណៈដែលទីភ្នាក់ងារផ្តល់ជំនួយ បានផ្តល់ធនធានយ៉ាងច្រើនទៅលើវិស័យសុខាភិបាល កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន រដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីរក្សាភាពម្ចាស់ការលើដំណើរការទាំងនេះ។ ការផ្តោតភាគច្រើនទៅលើជំនួយសង្គ្រោះ និងការស្តារឡើងវិញ ក្រោមការដឹកនាំរបស់ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដោយមានភាពជាដៃគូតិចតួចជាមួយរដ្ឋាភិបាល។ ទីភ្នាក់ងារអន្តរជាតិធ្វើកិច្ចការតិចតួច

បំផុត ក្នុងការដោះស្រាយការរំលោភសិទ្ធិមនុស្ស ប្រព្រឹត្តដោយពួកខ្មែរក្រហម ដែលបានបន្សល់ទុកមរតកនៃភាពតក់ស្លុតដក់ជាប់នៅក្នុងអារម្មណ៍ របស់ប្រជាជនកម្ពុជា ហើយទើបតែត្រូវដោះស្រាយក្នុងរយៈពេលជិត៣០ឆ្នាំក្រោយ ដោយការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅក្នុងឆ្នាំ២០០៣។

នៅក្នុងឆ្នាំ១៩៨២ ការហាមឃាត់ជំនួយត្រូវបានអនុវត្តយ៉ាងតឹងរឹងមកលើកម្ពុជា ដោយអង្គការសហប្រជាជាតិ នៅក្នុងកិច្ចប្រឹងប្រែងដើម្បីបញ្ចប់ "ការកាន់កាប់" របស់ប្រទេសវៀតណាម។ ការហាមឃាត់ជំនួយអស់រយៈពេលជិតដប់ឆ្នាំ បានធ្វើឱ្យរាំងស្ទះដល់កិច្ចប្រឹងប្រែងស្តារឡើងវិញ ទោះបីជាមានជំនួយសង្គ្រោះបន្ទាន់ តាមរយៈទីភ្នាក់ងារអង្គការសហប្រជាជាតិ ដោយមានកិច្ចសហការ និងសម្របសម្រួលជាមួយរដ្ឋាភិបាលក៏ដោយ។ ក្រោយមក ការហាមឃាត់ជំនួយនេះ ត្រូវបានជំទាស់ដោយអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលបានផ្តួចផ្តើមគំនិតលើកិច្ចប្រឹងប្រែងផ្តល់ជំនួយ រហូតទាល់តែការហាមឃាត់នេះ ត្រូវបានដកចេញនៅក្នុងឆ្នាំ១៩៨៨។

ដោយរំពឹងថា សន្តិភាព និងការបញ្ចប់ជម្លោះ កើតមានយ៉ាងពិតប្រាកដ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍បានផ្លាស់ប្តូរយ៉ាងគំហុក។ កងទ័ពវៀតណាមបានដកចេញពីកម្ពុជា ហើយកំណែទម្រង់ផ្ទៃក្នុងបានបើកទ្វារទទួលមូលនិធិជំនួយទ្វេភាគី កាន់តែច្រើនឡើងសម្រាប់សកម្មភាពមនុស្សធម៌ ដែលភាគច្រើនបានអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល។ អង្គការមិនមែនរដ្ឋាភិបាលបានទទួលតួនាទីដឹកនាំដ៏សំខាន់ ក្នុងការរៀបចំ និងពង្រីកកិច្ចប្រឹងប្រែងជំនួយតាមសំណើរបស់ម្ចាស់ជំនួយ ដែលនៅមានភាពរួញរា ក្នុងការផ្តល់មូលនិធិដល់រដ្ឋាភិបាលកម្ពុជា ដែលនៅមិនទាន់មានការទទួលស្គាល់។ ជាលទ្ធផល ស្ថាប័នរបស់ប្រទេសកម្ពុជាពុំបានទទួលការគាំទ្រ ឬពិគ្រោះយោបល់ឡើយ ខណៈដែលជំនួយអភិវឌ្ឍន៍បានពង្រីកខ្លួនយ៉ាងឆាប់រហ័ស។

ក្នុងឆ្នាំ១៩៩១ កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសបានចុះហត្ថលេខា ហើយអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា (UNTAC) បានបង្កើតឡើង ដើម្បីធានានូវការអនុវត្តកិច្ចព្រមព្រៀងសន្តិភាពនេះ។ កិច្ចព្រមព្រៀងសន្តិភាពនេះ បានបង្កើតសម័យអន្តរកាលមួយ ដែលពេលនោះបានរៀបចំការបោះឆ្នោតពហុភាគី បង្កើតរដ្ឋាភិបាលចំរុះ មានការគាំទ្រសង្គមស៊ីវិល និងពង្រឹងសេដ្ឋកិច្ចទីផ្សារ។ ជំនួយបរទេសបានផ្តោតលើការស្តារឡើងវិញ និងការអភិវឌ្ឍ ដែលមានចំនួនស្មើនឹង២/៣នៃចំណាយសរុបរបស់រដ្ឋាភិបាល[1]។

ក្នុងឆ្នាំ២០០៤ រដ្ឋាភិបាលកម្ពុជាបានបង្កើត "យុទ្ធសាស្ត្រចតុកោណ" ដោយកំណត់ពីទស្សនវិស័យលើការអភិវឌ្ឍរបស់ខ្លួន ផ្តោតលើវិស័យកសិកម្ម ការអភិវឌ្ឍផ្នែកឯកជន ការអភិវឌ្ឍធនធានមនុស្ស ព្រមទាំងការស្តារឡើងវិញ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដោយផ្តោតជារួមលើអភិបាលកិច្ចល្អ។ គេបានបង្កើតផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ មួយ

[1] Mysliwiec, Eva, "Envisioning a New Paradigm of Development Cooperation in Cambodia." Cambodian Development Research Institute, February 2004.

ដើម្បីពង្រឹងកិច្ចប្រឹងប្រែងជំនួយរហូតដល់ឆ្នាំ២០០៩។ ការអង្កេតគ្រួសារនៅកម្ពុជាឆ្នាំ២០០៤ បានបង្ហាញថា ប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ បានថយចុះពី៤៧ភាគរយកាលពី ១០ឆ្នាំមុន មកនៅត្រឹម៣៥ភាគរយ ផលិតផលសរុបក្នុងស្រុក បានកើនឡើងជាមធ្យមជាង៧ភាគរយ ក្នុងរយៈពេលដូចគ្នានេះ។ ទោះបីជាយ៉ាងនេះក្តី ជនក្រីក្រនៅជនបទ ដែលស្មើនឹង៩១ភាគរយនៃប្រជាជនសរុបរបស់កម្ពុជា នៅតែបន្តជួបការលំបាក ខណៈដែលប្រជាជននៅតំបន់ទីក្រុង ទទួលបានអត្ថប្រយោជន៍យ៉ាងច្រើន ពីកំណើន និងកិច្ចប្រឹងប្រែងអភិវឌ្ឍន៍ដែលបានរៀបរាប់ខាងលើ[2] ។

## កំណត់សម្គាល់លើពាក្យបច្ចេកទេស និងបរិបទ

ភាគច្រើននៃព័ត៌មាន ដែលបង្ហាញនៅក្នុងឯកសារនេះ ជាការដកស្រង់សំដីផ្ទាល់របស់អ្នកនិយាយ ដើម្បីឱ្យអ្នកអានបានស្តាប់ឮពីមតិយោបល់ និងបទពិសោធន៍របស់អ្នកដែលយើងបានសម្ភាសន៍។ ក្រុមអ្នកស្តាប់មតិយោបល់បានជួបប្រជុំគ្នារយៈពេលពីរថ្ងៃ បន្ទាប់ពីបញ្ចប់ទស្សនកិច្ចចុះមូលដ្ឋាន ដើម្បីឆ្លុះបញ្ចាំងពីអ្វីដែលពួកគេបានឮ ព្រមទាំងដើម្បីកំណត់ និងបែងចែកទៅតាមប្រភេទបញ្ហាដ៏ធំទូលាយ។ មានការណែនាំបង្ហាញអំពីប្រធានបទនីមួយៗ ហើយនៅចុងបញ្ចប់នៃប្រធានបទនីមួយៗ មានកត់ទុកការឆ្លុះបញ្ចាំងរបស់សមាជិកក្រុមការងារ នៅក្នុងផ្នែកដោយឡែកមួយ ដែលដាក់ថា "ការឆ្លុះបញ្ចាំងរបស់ក្រុមអ្នកស្តាប់មតិយោបល់"។

មានការប្រើពាក្យថា "អ្នកខាងក្រៅ" និង "អ្នកខាងក្នុង" ដើម្បីសំគាល់ភាពខុសគ្នារវាងអ្នកនៅក្រៅសហគមន៍ មិនថាជនជាតិខ្មែរ ឬជនបរទេស និងអ្នកជាផ្នែកមួយនៃសហគមន៍ ដែលទទួលផលពីកិច្ចប្រឹងប្រែងជំនួយ។ មានការប្រើពាក្យ "អន្តរាគមន៍" ដើម្បីពិពណ៌នាអំពីគំរោងផ្តួចផ្តើម ដោយអ្នកខាងក្រៅ ដែលមានបំណងជួយជ្រោមជ្រែងដល់សហគមន៍ណាមួយ ឬសង្គមខ្មែរទាំងមូល ដោយមិនគិតថា ជារដ្ឋាភិបាលកម្ពុជា អង្គការជាតិ អង្គការអន្តរជាតិ ស្ថាប័នហិរញ្ញវត្ថុ ឬស្ថាប័នអង្គការឯកជន និងសាធារណៈណាទទួលខុសត្រូវចំពោះគំរោងនោះឡើយ។

នៅពេលក្រុមអ្នកស្តាប់មតិយោបល់ សួរប្រជាពលរដ្ឋអំពី "ជំនួយបរទេស" ចម្លើយដំបូងរបស់ពួកគេ ជារឿយៗគិតថា ជាគំរោងហេដ្ឋារចនាសម្ព័ន្ធធំៗ មិនមែនជាគំរោងនៅតាមមូលដ្ឋាន ដែលអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលនោះឡើយ។ ការពិភាក្សាបន្ថែមទៀត បង្ហាញអោយឃើញអំពីការផ្តួចផ្តើមជំនួយអន្តរជាតិមួយចំនួនធំ អនុវត្តនៅក្នុងសហគមន៍។ ជារឿយៗ ប្រជាពលរដ្ឋមានភាពស្រពិចស្រពិលថា តើគំរោងបង្កើតឡើងដោយកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ឬដោយមូលនិធិផ្ទាល់ខ្លួនរបស់អ្នកដឹកនាំគណបក្សនយោបាយ ឬមានប្រភពមូលនិធិមកពីក្រៅប្រទេស។ នៅពេលដែលប្រជាពលរដ្ឋ ទទួលស្គាល់ថា គំរោងនៅមូលដ្ឋានបានផ្តួចផ្តើមដោយជំនួយអន្តរជាតិនោះ ពួកគេពុំបានដឹងច្បាស់ថា តើជំនួយនោះបានមកពី អង្គការសហប្រជាជាតិ ធនាគារពិភពលោក អង្គការអន្តរជាតិ ឬប្រភពមូលនិធិផ្សេងទៀត

---

[2] Remarks by the Representative of the International Monetary Fund at the Cambodia Consultative Group Meeting, Phnom Penh, March 2-3, 2006. URL: http://www.imf.org/external/np/dm/2006/030206a.htm (accessed on 7/22/08)

ឡើយ។ នៅក្នុងករណីជាច្រើន មូលនិធិបានមកពីប្រភពចំរុះ ឬឆ្លងកាត់តាមរយៈស្ថាប័នផ្សេងៗ មុនពេលចូលទៅដល់សហគមន៍។ នៅពេលដែលប្រជាពលរដ្ឋ បានបញ្ជាក់ថា គំរោងនោះទទួលជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ជារឿយៗពួកគេពុំដឹងច្បាស់ថា តើអង្គការនោះឈ្មោះអ្វីឡើយ។ ដូច្នេះ របាយការណ៍នេះ មិនបែងចែកប្រភេទជំនួយបរទេសទេ ដោយគ្រាន់តែបង្ហាញថា ជា "ការផ្តួចផ្តើមគំនិតពីខាងក្រៅ" ឬជា "កិច្ចប្រឹងប្រែងជំនួយ" តែប៉ុណ្ណោះ។

បញ្ហាចុងក្រោយមួយទៀត ដែលក្រុមអ្នកស្តាប់មតិយោបល់មួយចំនួនជួបប្រទះ គឺភាពស្ទាក់ស្ទើរ និងជួនកាលភាពភ័យខ្លាចរបស់សមាជិកសហគមន៍ ដែលមិនហ៊ាននិយាយជាមួយអ្នកខាងក្រៅ បើទោះជាជនបរទេស ឬជនជាតិខ្មែរក៏ដោយ។ សមាជិកក្រុមអ្នកស្តាប់មតិយោបល់បានកត់សម្គាល់ថា បញ្ហាបែបនេះ កើតមានដោយសារប្រជាពលរដ្ឋមិនបានដឹងច្បាស់អំពីគោលបំណងពិតប្រាកដរបស់ក្រុមអ្នកស្តាប់មតិយោបល់ និងមិនចង់ឱ្យគេមើលឃើញថា ជាអ្នកផ្តល់ព័ត៌មានអវិជ្ជមាន ឬព័ត៌មាននយោបាយដល់អ្នកខាងក្រៅ ដែលអាចធ្វើឱ្យពួកគេ មានបញ្ហាជាមួយប្រធានភូមិ ឬអាជ្ញាធរមូលដ្ឋាននៅពេលក្រោយ។ កង្វល់នេះមានលក្ខណៈពិសេស ពីព្រោះសកម្មភាពចុះស្តាប់មតិយោបល់ប្រជាពលរដ្ឋនេះកើតឡើង ក្នុងអំឡុងពេលត្រៀមរៀបចំមុនការបោះឆ្នោត។ សមាជិកក្រុមអ្នកស្តាប់ មានការយល់ឃើញជាទូទៅថា សមាជិកសហគមន៍ យល់ថា វិធីប្រាស្រ័យទាក់ទងដែលមានសុវត្ថិភាពបំផុត រវាងពួកគេ និងអ្នកមកពីខាងក្រៅ គឺត្រូវកាត់បន្ថយទំនាក់ទំនងឱ្យបានជាអប្បបរមា និងចាត់ទុកអ្វីដែលពួកគេបានដឹងអំពីកិច្ចប្រឹងប្រែងជំនួយបរទេសមិនសំខាន់ដោយធ្វើយ៉ាងណា ចៀសវាងឱ្យផុតពីការជជែកពីបញ្ហាអំពើពុករលួយ និងបក្សពួកនិយម។ម្យ៉ាងទៀត ក៏មានកង្វល់ផងដែរថា ប្រជាពលរដ្ឋនិយាយប្រាប់សមាជិកក្រុមអ្នកស្តាប់មតិយោបល់ ពីអ្វីដែលពួកគេគិតថា ពួកយើងចង់ស្តាប់។ គួរកត់សម្គាល់ថា វាជាផ្នែកមួយនៃប្រវត្តិសាស្ត្ររបស់កម្ពុជា ដែលពីអតីតកាល អ្នកចេះដឹង និងបញ្ញាវន្តជាច្រើន ត្រូវសម្លាប់ដោយពួកខ្មែរក្រហម ហើយរួមចំណែកធ្វើឱ្យមានវប្បធម៌មិនទុកចិត្តគ្នា និងមិនហ៊ាននិយាយស្តី។ នៅក្នុងល័ក្ខខ័ណ្ឌបែបនេះ ប្រជាពលរដ្ឋជាច្រើនបានបើកចំហ និងមានសេចក្តីស្មោះត្រង់ ក្នុងការចែករំលែកគំនិត និងទស្សនៈរបស់ពួកគេអំពីកិច្ចប្រឹងប្រែងជំនួយនៅកម្ពុជា ហើយយើងសូមអរគុណចំពោះពួកគេដែលបានចំណាយពេលវេលាពិភាក្សា ជាមួយយើង។

## វិជ្ជមានទូទៅដែលក្រុមអ្នកស្តាប់មតិយោបល់បានឮ

នៅគ្រប់ការសន្ទនាជាមួយសមាជិកក្រុមអ្នកស្តាប់មតិយោបល់ ប្រជាពលរដ្ឋ បានបង្ហាញនូវការដឹងគុណចំពោះជំនួយអន្តរជាតិ ដែលបានចូលមកប្រទេសកម្ពុជា។ មនុស្សជាច្រើន យល់ឃើញថា បើសិនជាគ្មានជំនួយបរទេសនោះទេ កម្ពុជានឹងពុំមានការរីកចំរើនឡើយ ហើយការរីកចំរើននេះ បានបង្ហាញអោយឃើញយ៉ាងច្បាស់ ពីគុណភាពជីវភាពល្អប្រសើរ ហេដ្ឋារចនាសម្ព័ន្ធដែលគេឃើញមានយ៉ាងច្រើន និងលទ្ធភាពកាន់តែច្រើនក្នុងការទទួលសេវានានា ដូចជាការថែទាំ

សុខភាព និងការអប់រំ។ មានការសង្កត់ធ្ងន់យ៉ាងច្បាស់ថា ជំនួយរូបិយដូចជា ផ្លូវ ប្រឡាយ គ្លីនិក និងសាលារៀន ត្រូវបានឱ្យតម្លៃយ៉ាងខ្លាំង ពីព្រោះពួកគេមើលឃើញជំនួយប្រភេទនេះ ថាជា "ជំនួយផ្ទាល់" ឬជាជំនួយដែលមនុស្សទាំងអស់អាចប្រើប្រាស់បាន។ ការប្រឹងប្រែងដើម្បីជួយប្រជាពលរដ្ឋក្នុងការលើកកំពស់ជីវភាពរបស់ពួកគេ ទោះបីជាតាមរយៈការបណ្តុះបណ្តាលជំនាញបច្ចេកទេស ឬការផ្តល់ដើមទុន ត្រូវបានឱ្យតម្លៃយ៉ាងខ្លាំង។ លទ្ធផលនៃជំនួយអរូបិយជាច្រើន ក៏បានទទួលការកោតសរសើរពីប្រជាពលរដ្ឋ ដូចជាសេចក្តីក្លាហានក្នុងការឡើងនិយាយការពារសិទ្ធិរបស់ខ្លួន ការកើនឡើងសាមគ្គីភាពនៅក្នុង និងរវាងសហគមន៍នានា និងការថយចុះនៃការរស់នៅឯកោពីជនជាតិខ្មែរដូចគ្នា។ មតិយោបល់ជាច្រើនដែលបានឆ្លុះបញ្ចាំងពីការរីកចំរើនទាំងផ្នែករូបិយ និងអរូបិយ មានបង្ហាញនៅក្នុងផ្នែកដែលមានចំណងជើងថា "**ការលើកឡើងជាវិជ្ជមានអំពីកិច្ចប្រឹងប្រែងលើការផ្តល់ជំនួយ**"។

ប្រជាពលរដ្ឋស្ទើរតែទាំងអស់ ដែលយើងបានជួប បានចាប់ផ្តើមការសន្ទនា ដោយការលើកសរសើរអំពីជំនួយបរទេស ប៉ុន្តែជាចុងក្រោយ ពួកគេប្រាប់យើងអំពីផលវិបាកជាអវិជ្ជមានមួយចំនួន នៃកិច្ចប្រឹងប្រែងលើការផ្តល់ជំនួយ។ ប្រជាពលរដ្ឋ បានសំដែងការព្រួយបារម្ភអំពីបញ្ហាផ្សេងៗដូចជា ភាពតានតឹងដែលបណ្តាលមកពីភាពមិនស្មើគ្នា ក្នុងការទទួលបានជំនួយ ការផ្លាស់ប្តូររបៀបរបបសង្គម ការធ្វើឱ្យខូចដល់យន្តការគាំទ្ររបស់សហគមន៍ និងការខកចិត្តចំពោះកង្វះខាតនៃការរីកចំរើនប្រកបដោយអត្ថន័យ។ អតីតជនភៀសខ្លួន ដែលធ្លាប់បានភៀសខ្លួនទៅរស់នៅក្នុងប្រទេសថៃ ក៏បានប្រាប់យើងនូវរឿងរ៉ាវជាច្រើន អំពីបញ្ហាលំបាកដែលពួកគេបានជួបប្រទះ ក្នុងការព្យាយាមចូលមករួមរស់នៅក្នុងសង្គមខ្មែរ និងពីជីវិតនៅក្នុងជំរុំជាយដែន ដែលមិនបានជួយពួកគេក្នុងការត្រៀមខ្លួនសម្រាប់ធ្វើមាតុភូមិនិវត្តន៍ ក្រៅពីការពឹងផ្អែកលើជំនួយផងដែរ។ ជនភៀសខ្លួនមួយចំនួន ក៏បានសម្តែងនូវការខកចិត្តយ៉ាងខ្លាំង និងអារម្មណ៍ភ័យរន្ធត់ជាញឹកញាប់ដោយខ្វះខាតការការពារ ដូចដែលពួកគេធ្លាប់បានទទួលនៅក្នុងជំរុំនៅប្រទេសថៃ ហើយសម្រាប់អតីតជនភៀសខ្លួនជាច្រើន ការការពារនេះ គឺជាជំនួយបរទេសតែម្យ៉ាងគត់ដែលគេធ្លាប់បានទទួល។ ការព្រួយបារម្ភរបស់ ប្រជាពលរដ្ឋទាក់ទងនឹងផលវិបាកជាអវិជ្ជមាននៃអន្តរាគមន៍ពីខាងក្រៅ មានពិភាក្សា នៅក្នុងរបាយការណ៍នេះ ត្រង់ផ្នែកដែលនិយាយអំពី "**ការព្រួយបារម្ភទាក់ទងនឹងកិច្ចប្រឹងប្រែងលើការផ្តល់ជំនួយ**"។

ប្រជាពលរដ្ឋ ក៏បានពិភាក្សាផងដែរ អំពីកង្វះខាតនៃភាពម្ចាស់ការលើគំរោង និងកត់សម្គាល់នូវទំនាក់ទំនងរវាងការទទួលព័ត៌មាន ភាពម្ចាស់ការ និងនិរន្តរភាព។ ប្រជាពលរដ្ឋជាច្រើន ដែលបានទទួលជំនួយដើម្បីកែលំអជីវភាពរស់នៅរបស់ពួកគេ បានពន្យល់ថា អ្វីដែលពួកគេបានទទួល គ្រាន់តែជាផ្នែកមួយនៃអ្វីដែលពួកគេត្រូវការតែប៉ុណ្ណោះ។ ឧទាហរណ៍ ការបណ្តុះបណ្តាលអំពីសកម្មភាពបង្កើតប្រាក់ចំណូល តែគ្មានដើមទុនដើម្បីចាប់ផ្តើមមុខរបរ ការផ្តល់គ្រាប់ពូជថ្មីដោយគ្មានការណែនាំ និងការផ្តល់ពូជមាន់ដែលគ្មានចាក់ថ្នាំបង្ការ។ ដូច្នេះ ប្រជាពលរដ្ឋបានចោទជាបញ្ហា ម្តងហើយម្តងទៀតថា ជំនួយមិនត្រូវបានផ្តល់ឱ្យជាកញ្ចប់សម្រាប់ភាពជោគជ័យឡើយ។ នៅពេលដែលមានបញ្ហា

នេះ ជារឿយៗបណ្តាលមកពីកង្វះខាត "ការទិញទុកបំរុង" សម្រាប់គំរោង។ អ្នកទទួលជំនួយមួយចំនួនតូច តែមានគ្រប់កន្លែងបានប្រាប់ថា ជំនួយពីខាងក្រៅធ្វើអោយជីវិតរបស់ពួកគេ មានការរីកចំរើនតិចតួចប៉ុណ្ណោះ។ ពួកគេយល់ឃើញថា ជំនួយមានរយៈពេលខ្លី ហើយគ្រាន់តែជាសំបកក្រៅប៉ុណ្ណោះ មិនមែនជាអន្តរាគមន៍ប្រកបដោយនិរន្តរភាព ដែលអាចផ្លាស់ប្តូរគុណភាពជីវិតរបស់ពួកគេជារៀងរហូតឡើយ។ បញ្ហាទាំងនេះ បានពិភាក្សាស៊ីជម្រៅថែមទៀតនៅក្នុងផ្នែកដែលនិយាយអំពី "**ការអប់រំ ការចូលរួម និងភាពម្ចាស់ការ**"។

ប្រជាពលរដ្ឋភាគច្រើន បានចាប់ផ្តើមការសន្ទនាដោយនិយាយថា : "ខ្ញុំបានឮអំពីជំនួយតាមវិទ្យុ តែខ្ញុំមិនដែលបានទទួលជំនួយទេ"។ ការពិភាក្សា និងការសង្កេតបន្ថែម បានបង្ហាញថា អ្នកទាំងនោះបានទទួលជំនួយក្នុងទម្រង់ណាមួយ ប៉ុន្តែមានភាពមិនច្បាស់លាស់ថា តើជំនួយគឺជាអ្វី? តើជំនួយបានមកពីប្រភពណា? តើនរណាបានទទួលជំនួយ ហើយហេតុអ្វីបានជាគេបានទទួលជំនួយ? វាហាក់ដូចជាពុំមានការចែករំលែកព័ត៌មានច្បាស់លាស់ និងត្រឹមត្រូវ រវាងអ្នកផ្តល់ និងអ្នកទទួល អំពីកិច្ចប្រឹងប្រែងលើការផ្តល់ជំនួយទេ។ ឧទាហរណ៍ នៅពេលដែលប្រជាពលរដ្ឋបានដឹងថាពួកគេពិតជាបានទទួលជំនួយ ពួកគេពុំបានដឹងច្បាស់ថា តើសាលារៀនថ្មីមួយខ្នងបានកសាងឡើងដោយជំនួយបរទេស បានមកពីរាជរដ្ឋាភិបាល ឬក៏បានមកពីនាយករដ្ឋមន្ត្រី។ កង្វះខាតនៃការយល់ដឹង ការចែករំលែកព័ត៌មាន និងការប្រាស្រ័យទាក់ទងដោយទីភ្នាក់ងារផ្តល់ជំនួយផ្សេងៗ បានលើកឡើងនៅក្នុងផ្នែកដែលនិយាយអំពី "**ការចែករំលែក និងការស្វែងយល់ព័ត៌មានទាក់ទងនឹងកិច្ចប្រឹងប្រែងលើការផ្តល់ជំនួយ**"។

នៅក្នុងការសន្ទនាភាគច្រើន ប្រជាពលរដ្ឋបានកត់សម្គាល់ថា មានការបាត់បង់ជំនួយ ឬមូលនិធិ។ ទោះបីជាប្រជាពលរដ្ឋបានប្រុងប្រយ័ត្នចៀសវាងពាក្យទាំងឡាយ ដូចជា "អំពើពុករលួយ" ក៏ដោយ ក៏ប្រជាពលរដ្ឋជាច្រើនបានពន្យល់ស្របគ្នាថា ជំនួយមិនបានធ្លាក់ដល់ដៃពួកគេទេ។ ពួកគេមិនអាចពន្យល់ថា តើមានអ្វីកើតឡើងចំពោះជំនួយដែលបានសន្យាថានឹងផ្តល់ឱ្យពួកគេបានឡើយ និងលើសពីនេះទៀតនោះ ពួកគេមានជំនឿថា អ្នកផ្តល់សេវា មិនថាទីភ្នាក់ងាររដ្ឋាភិបាល ឬទីភ្នាក់ងារផ្សេងទៀត បានរក្សាទុកនូវចំណែកដ៏ច្រើននៃមូលនិធិ។ ក្រុមការងារគំរោង ស្តីពីការស្តាប់មតិយោបល់ទាំងប្រាំក្រុម បានស្តាប់នូវសំណូមពរដែលថាតើស្ថាប័នណាគួរបែងចែកជំនួយ ដើម្បីបង្កើនលទ្ធផលជាអតិបរមា និងកាត់បន្ថយអំពើពុករលួយ។ អ្នកទទួលជំនួយបានបន្តសង្កត់ធ្ងន់លើតម្រូវការ ឱ្យមានវត្តមានរបស់ម្ចាស់ជំនួយឱ្យបានច្រើន ការពិនិត្យតាមដាន និងការដាក់ល័ក្ខខ័ណ្ឌលើជំនួយឱ្យបានច្រើនថែមទៀត ទាំងនៅក្នុងការពិភាក្សា ជាលក្ខណៈបុគ្គល និងនៅថ្នាក់ភូមិ។ យោបល់ និងទស្សនៈទាំងនេះ មានពិភាក្សានៅក្នុងផ្នែកដែលនិយាយអំពី "**តម្រូវការសម្រាប់តម្លាភាព និងការត្រួតពិនិត្យបន្ថែម**"។

សម្រាប់អ្នកភូមិ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល វាជាការសំខាន់ ដែលម្ចាស់ជំនួយ មានវត្តមានច្រើននៅថ្នាក់ភូមិ និងថ្នាក់គំរោង។ ប្រជាពលរដ្ឋ មានជំនឿថា ប្រសិនបើម្ចាស់ជំនួយចំណាយពេលចុះមូលដ្ឋានច្រើន ពួកគេនឹង

យល់ដឹងបានច្បាស់អំពីបរិបទ និងល័ក្ខខ័ណ្ឌនៃគំរោងនានា ដែលបានអនុវត្ត អាចបត់បែនបានច្រើនអំពីបញ្ហាលំបាក ដែលគំរោងទាំងនោះជួបប្រទះ និងផ្តល់មូលនិធិដល់គំរោងដែលសមស្របបំផុតទៅនឹងតម្រូវការរបស់ប្រជាជនមូលដ្ឋាន។ ទំនោររបស់ម្ចាស់ជំនួយក្នុងការផ្តល់មូលនិធិ យោងតាម "និន្នាការ" និងការផ្លាស់ប្តូរគោលនយោបាយផ្តល់មូលនិធិ ជាប្រចាំរបស់ពួកគេ មានន័យថា អង្គការមិនមែនរដ្ឋាភិបាល អនុវត្តគំរោងរបស់ខ្លួនតម្រូវទៅតាមមូលនិធិ មិនមែនទៅតាមអ្វីដែលពួកគេយល់ឃើញថា អាចជាអាទិភាពរបស់ប្រជាពលរដ្ឋ ដែលពួកគេតំណាងឡើយ។ ល័ក្ខខ័ណ្ឌតម្រូវរបស់ម្ចាស់ជំនួយសម្រាប់ធ្វើរបាយការណ៍ពិបាកបំពេញ និងការសង្កត់ធ្ងន់លើភាពស្ទាត់ជំនាញនៃភាសាអង់គ្លេស ក៏ត្រូវបានកត់សម្គាល់ថាជាការធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក លើការផ្តោតការយកចិត្តទុក ដាក់បំពេញតម្រូវការរបស់សហគមន៍ផងដែរ។ ជាចុងក្រោយ ក្រុមការងារគំរោងស្តីពីការស្តាប់មតិយោបល់ បានទទួលយោបល់ជាច្រើន អំពីអ្វីដែលជាការពិនិត្យតាមដានល្អ និងអ្វីដែលជាការពិនិត្យតាមដានមិនល្អ។ បញ្ហាទាំងនេះបានបង្ហាញនៅក្នុងផ្នែកមួយដែលនិយាយអំពី **"ភាពជាម្ចាស់ជំនួយល្អ"**។

ប្រជាជនខ្មែរមួយចំនួន បានលើកឡើងនូវកង្វល់ចំពោះរបៀបប្រាស្រ័យទាក់ទង ដែលបានកើតឡើង រវាងបុគ្គលិកអន្តរជាតិ និងបុគ្គលិកខ្មែរ និងរវាងអង្គការអន្តរជាតិ និងអង្គការខ្មែរ។ នៅកំរិតបុគ្គល មនុស្សមួយចំនួនបានលើកឡើងពីកង្វល់ចំពោះកង្វះភាពគោរព និងកង្វះការយល់ដឹងអំពីវប្បធម៌ខ្មែរ។ នៅកំរិតទូទៅ មនុស្សមួយចំនួនបានលើកឡើងពីកង្វល់ចំពោះរបៀបដែលទស្សនៈលោកខាងលិច ត្រូវបានដាក់បង្ខំឱ្យខ្មែរធ្វើតាម ដោយសង្កត់ធ្ងន់ថា របៀប និងដំណើរការទាំងនោះ មានបញ្ហាច្រើនជាងការអនុវត្តទស្សនៈថ្មីនោះទៅទៀត។ ឧទាហរណ៍ជាក់ស្តែងមួយចំនួន ដែលបានលើកឡើងរួមមាន របៀបលើកកំពស់ការយល់ដឹងអំពីយេនឌ័រ និងអំពើហិង្សាក្នុងគ្រួសារ របៀបបង្រៀនអំពីការបង្ការមេរោគអេដស៍/ជំងឺអេដស៍ និងរបៀបអនុវត្តកម្មវិធីសហគមន៍អភិរក្ស និងសហគមន៍ព្រៃឈើ។ ចំណុចដែលជាកង្វល់ផងដែរ គឺការភ្ជាប់សាសនាគ្រីស្តទៅនឹងកិច្ចប្រឹងប្រែងផ្តល់ជំនួយ និងទស្សនៈខុសគ្នាអំពីថា តើនរណាគួរកំណត់លក្ខណៈវិនិច្ឆ័យ សម្រាប់ភាពងាយរងគ្រោះ។ បញ្ហាក្រមសីលធម៌របស់ម្ចាស់ជំនួយ ក៏ត្រូវបានលើកឡើងដោយបុគ្គលិកជំនួយជាតិ និងអន្តរជាតិ មួយចំនួន ទាក់ទងនឹងរបៀបចំណាយលុយជំនួយខ្ជះខ្ជាយឥតប្រយោជន៍ ដោយមិនបានចំណាយក្នុងស្មារតីទទួលខុសត្រូវ លើការដោះស្រាយតម្រូវការបន្ទាន់ និងធ្ងន់ធ្ងររបស់ប្រជាជនខ្មែរ។ បញ្ហាទាំងនេះ បានពិភាក្សានៅក្នុងផ្នែកចុងក្រោយ ដែលនិយាយអំពី **"បញ្ហាវប្បធម៌ ការគោរព និងក្រមសីលធម៌"**។

## I. ការលើកឡើងជាវិជ្ជមានទាក់ទងនឹងកិច្ចប្រឹងប្រែងផ្តល់ជំនួយ

ក្រុមអ្នកស្តាប់មតិយោបល់ បានស្តាប់អំពីផលជាវិជ្ជមានជាច្រើនរបស់ជំនួយអន្តរជាតិ ហើយផ្លូវថ្នល់ ត្រូវបានលើកឡើងជាពិសេស ម្តងហើយម្តងទៀត ពីព្រោះប្រជាពលរដ្ឋយល់ឃើញថា ផ្លូវ គឺជាជំនួយផ្ទាល់ *"ជំនួយដែលបានដល់ដៃខ្ញុំ"*។

ផ្លូវមានន័យថា ប្រជាពលរដ្ឋងាយស្រួលក្នុងការចេញចូលទីផ្សារដើម្បីប្រកបរបរចិញ្ចឹមជីវិត បញ្ជូនកូនទៅរៀន ទៅមន្ទីរពេទ្យបានទាន់ពេលវេលា និងកាត់បន្ថយភាពនៅឯកោ។ ប្រជាពលរដ្ឋ ក៏បានពិភាក្សាអំពីការរីកចំរើនលើជីវភាពរស់នៅរបស់ពួកគេ ដោយមានសាលារៀន និងឱកាសទទួលការអប់រំច្រើន និងការយល់ដឹងច្បាស់អំពីជីវិតក្រៅភូមិ របស់ពួកគេ។ ប្រជាពលរដ្ឋ បានកត់សម្គាល់ថា ការផ្ដួចផ្ដើមគំនិតពីខាងក្រៅ ក៏បានជួយផ្ដល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ តាមរយៈកម្មវិធីអប់រំក្រៅប្រព័ន្ធ រាប់បញ្ចូលទាំងការអប់រំអំពីសិទ្ធិមនុស្ស បញ្ហាច្បាប់ និងការបង្កើតសហគមន៍។ មានការកត់សម្គាល់ថា វគ្គបណ្ដុះបណ្ដាល និងកម្មវិធីលើកកំពស់ការយល់ដឹងមួយចំនួន បានកាត់បន្ថយភាពតានតឹងរវាងសហគមន៍ និងបង្ហាញពីរបៀបរួបរួមសាមគ្គីគ្នា ចំណែកកម្មវិធីមួយចំនួនទៀត អនុញ្ញាតឱ្យប្រជាពលរដ្ឋបានចេះដឹង អំពីជំនាញដែលពួកគេអាចប្រើការបានសម្រាប់ជីវភាពរស់នៅរបស់ពួកគេ។ ប្រជាពលរដ្ឋមួយចំនួនតូច បានប្រាប់អំពីការស្រមៃ និងសេចក្ដីប្រាថ្នាចង់បាន ដែលពួកគេបានបង្កើតឡើងដោយសារបានចូលរួមវគ្គអប់រំ និងបណ្ដុះបណ្ដាល។ លទ្ធផល និងឥទ្ធិពលជាវិជ្ជមានមួយចំនួន ដែលប្រជាពលរដ្ឋ បានលើកឡើងនៅក្នុងការសន្ទនា រួមមាន ៖

"ខ្ញុំមានកូន១០នាក់ តែស្លាប់អស់៨នាក់ហើយ ដោយសារជំងឺគ្រុនចាញ់។ ខ្ញុំជឿថា សព្វថ្ងៃនេះ បើសិនជាខ្ញុំមានកូនទៀត កូនៗខ្ញុំនឹងរស់ទាំងអស់ ពីព្រោះមានការថែទាំសុខភាពជាប្រចាំនៅក្នុងភូមិ។ កាលពីមុន ពេលកូនខ្ញុំឈឺ ខ្ញុំបានយកកូនទៅមន្ទីរពេទ្យខេត្ត ប៉ុន្តែពេទ្យអត់មានថ្នាំព្យាបាល។ សព្វថ្ងៃ (អង្គការអន្តរជាតិ) បានផ្ដល់មុងជ្រលក់ និងថ្នាំការពារជំងឺគ្រុនចាញ់នៅក្នុងភូមិ"។ *(ស្ត្រីជនជាតិព្នងម្នាក់ មានអាយុជាង៥០ឆ្នាំ នៅខេត្តមណ្ឌលគិរី)* ។

"បើគ្មាន (អង្គការ) ជួយទេ យើងមិនអាចបានរីកចំរើនដូច្នេះទេ"។ យើងបានក្លាយជាគំរូមួយ ក្នុងការបង្ហាញថាតើការអភិវឌ្ឍន៍អាចកើតឡើងបានដូចម្ដេច"។ តំបន់នេះ ធ្លាប់ទឹកជំនន់លិច ហើយយើងមានជីវភាពក្រីក្រ។ សព្វថ្ងៃយើងជួយបង្ហាត់បង្រៀនគ្នាទៅវិញទៅមក មានការជឿទុកចិត្តគ្នា មានសន្តិសុខល្អ។ វាខុសគ្នា ដូចមេឃ និងដី។ ប្រជាជននៅភូមិនេះ ចេះជួយគ្នាណាស់ ហើយយើងមានការសាមគ្គីគ្នា"។ *(ស្ត្រីម្នាក់ដែលមានអាយុប្រមាណ ៤៥ឆ្នាំ រស់នៅតំបន់ក្រីក្រមួយជិតទីក្រុងភ្នំពេញ)* ។

"កាលពីមុន ប្រជាជនជាច្រើន មិនបានដឹងពីវិធីពន្យារកំណើតទេ ប៉ុន្តែសព្វថ្ងៃ ស្ត្រីជាច្រើនបានយល់ដឹង ហើយមានកូនតិច "។ *( បុរសបីនាក់ និងស្ត្រីម្នាក់រស់នៅក្នុងភូមិដាច់ស្រយាល នៅក្នុងខេត្តមណ្ឌលគិរី)* ។

"បច្ចេកទេសថ្មីនេះ (ដំណាំវិលជុំ) មានប្រយោជន៍ណាស់ ពីព្រោះយើងមានដីចំការគ្រប់គ្រាន់ យើងអាចជួយថែរក្សាព្រៃឈើ ហើយទិន្នផលដែលយើងទទួលបានគឺដូចមុន។ បើសិនជាយើងកាប់ឆ្ការព្រៃ យើងនឹងលែងមានព្រៃឈើទៀត ហើយសត្វក៏គ្មានកន្លែងរស់នៅដែរ"។ *(ការជួបប្រជុំជាមួយប្រជាជន១០នាក់ នៅក្នុងភូមិជនជាតិព្នង នៅខេត្តមណ្ឌលគិរី)* ។

"ជីវិតរបស់ស្ត្រី បានប្រែប្រួលយ៉ាងច្រើន។ កាលពីមុន យើងពុំមានម៉ាស៊ីនកិនស្រូវទេ យើងត្រូវធ្វើអ្វីៗដោយដៃ ហើយដើរផ្លូវឆ្ងាយទៅដងទឹករាល់ថ្ងៃ។ សព្វថ្ងៃ យើងមានម៉ាស៊ីនកិនស្រូវដែលយើងប្រើរួមគ្នា ហើយប្រជាជន មានសុខភាពល្អជាងមុន ដោយសារយើងមានមណ្ឌលសុខភាពនៅជិត។ លើសពីនេះទៀត ក្នុងពេលប្រជុំក្រុមប្រឹក្សាឃុំ ស្ត្រីត្រូវបានលើកទឹកចិត្ត និងសុំឱ្យឡើងនិយាយ និងបញ្ចេញយោបល់ "។ *( ស្ត្រីជនជាតិព្នងម្នាក់ អាយុប្រហែល៣០ឆ្នាំ ក្នុងការប្រជុំនៅក្នុងភូមិមួយ នៅខេត្តមណ្ឌលគិរី)* ។

"កាលពីមុន ខ្ញុំចង់តែសម្លាប់ខ្លួនទេ ដោយសារគេរើសអើងថា ខ្ញុំជាអ្នកកើតអេដស៍ និងក្រីក្រ។ ក្រោយមកមានការលើកទឹកចិត្តពីអ្នកដទៃ និងមានការគាំទ្រពី( អង្គការ) ខ្ញុំបានផ្លាស់ប្តូរជីវិតរបស់ខ្ញុំ ហើយសព្វថ្ងៃ ការរស់នៅបានល្អប្រសើរជាងមុន។ ខ្ញុំអាចចូលសង្គមចុះ។ កាលពីមុនគ្មាននរណាគេចង់ទិញបន្លែរបស់ខ្ញុំទេ តែក្រោយមកអង្គការបានផ្តល់ការអប់រំសុខភាពដល់អ្នកដទៃ ដូច្នេះ សហគមន៍ក៏បានផ្លាស់ប្តូរ "។ *( ស្ត្រីម្នាក់អាយុប្រហែល៣៥ឆ្នាំ មានកូនបួននាក់ រស់នៅក្នុងខេត្តបាត់ដំបង)* ។

" ពីមុនខ្ញុំធ្លាប់ចំណាយពេលពីរម៉ោង ដើម្បីដឹកស្រូវទៅកាន់ទីផ្សារ ឥឡូវចំណាយពេលតែកន្លះម៉ោងទេ។ ផ្លូវនេះកាត់បន្ថយចំណាយលើការធ្វើដំណើរយកស្រូវទៅលក់ "។ *( កិច្ចប្រជុំក្រុមប្រឹក្សាឃុំ ខេត្តបាត់ដំបង)* ។

" ខ្ញុំយល់ឃើញថា ការបណ្តុះបណ្តាល និងការយល់ដឹងអំពីការគ្រប់គ្រងធនធានធម្មជាតិ មានសារៈសំខាន់ណាស់។ ឥឡូវ ខ្ញុំបានយល់អំពីការថែរក្សាព្រៃឈើ ហេតុអ្វីបានជាព្រៃឈើមានសារៈសំខាន់ និងយល់ថា ព្រៃឈើ គឺសម្រាប់អនាគតរបស់កូនចៅយើង"។ *( ប្តីប្រពន្ធជនជាតិព្នង មានអាយុ៣០ឆ្នាំ នៅខេត្តមណ្ឌលគិរី)* ។

"ប្រសិនបើគ្មានជំនួយទេ យើងនឹងពឹងផ្អែកលើកសិកម្មសម្រាប់ចិញ្ចឹមជីវិត ប៉ុន្តែវាជាការពិបាក ក្នុងការកែលំអស្ថានភាពរបស់យើង។ យើងពិបាកគេចផុតពីភាពក្រីក្រ យើងអាចរស់បាន ប៉ុន្តែការអភិវឌ្ឍត្រូវការជំនួយពីខាងក្រៅ។ បើគ្មានជំនួយអន្តរជាតិទេ កម្ពុជាក៏លែងមានដែរ ហើយនឹងមិនមានការផ្លាស់ប្តូរឡើយ។ សព្វថ្ងៃ ការផ្លាស់ប្តូរកំពុងកើតមានជាបន្តបន្ទាប់ "។ *( បុរសជនជាតិអាមេរិកដើមកំណើតខ្មែរ អាយុ៦០ឆ្នាំ ជាបុគ្គលិកអង្គការអន្តរជាតិមួយនៅភ្នំពេញ)* ។

" ប្រព័ន្ធផ្សព្វផ្សាយ និងអង្គការមិនមែនរដ្ឋាភិបាល ធ្វើឱ្យប្រជាពលរដ្ឋ និយាយមិនសូវខ្លាច និងពិភាក្សាដោយសេរី "។ *( បុរសម្នាក់ អាយុប្រហែល៣០ឆ្នាំ ជាអ្នកសម្របសម្រួលអង្គការក្នុងស្រុក ដែលស្ថិតនៅក្នុងសហគមន៍អាណាធិបតេយ្យជិតទីក្រុងភ្នំពេញ)* ។

## II. ការព្រួយបារម្ភទាក់ទងនឹងកិច្ចប្រឹងប្រែងផ្តល់ជំនួយ

### ក. ភាពតានតឹងលើការទទួលបានជំនួយមិនស្មើភាព

ប្រជាពលរដ្ឋមួយចំនួន បានរៀបរាប់ថា ការទទួលជំនួយមិនស្មើភាព និងការផ្គត់ផ្គង់ ជួនកាលបណ្តាលឱ្យមានភាពតានតឹងនៅក្នុងសហគមន៍នានា។ តែទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋបានបង្ហាញយ៉ាងម៉ឺងម៉ាត់ថា ប្រសិនបើជំនួយទៅដល់ដៃប្រជាពលរដ្ឋដែលត្រូវការបំផុតយ៉ាងពិតប្រាកដនោះ នឹងពុំមានការច្រណែន និងភាពតានតឹងឡើយ។

"យើងដឹងថា នរណាក្រីក្រ និងនរណាមិនក្រីក្រ។ ប្រសិនបើមានអង្គការមក យើងនិយាយថា " សូមជួយអ្នកនេះ គេក្រីក្រ។ យើងចង់ឱ្យពួកគេជួយអ្នកក្រីក្របំផុត យើងចែករំលែកសេចក្តីសុខជាមួយគ្រួសារក្រីក្រ យើងច្រណែន តែនៅពេលដែលពួកគេជួយអ្នកមានប៉ុណ្ណោះ "។ *(លោកយាយម្នាក់ នៅខេត្តពោធិ៍សាត់)* ។

" ខ្ញុំច្រណែនណាស់ ចំពោះដំណើរការនៃការផ្តល់អំណោយ ដោយគ្រួសារក្រីក្រពិតប្រាកដខ្លះ នៅតែមិនបានទទួលអំណោយអ្វីសោះ "។ *(ស្ត្រីកសិករ៤នាក់ ដែលមានអាយុពី ២០-៣០ ឆ្នាំ នៅខេត្តកំពត)* ។

" ប្រសិនបើខ្ញុំជាអង្គការវិញ ខ្ញុំនឹងចែកអំណោយឱ្យគ្រប់គ្នា ពីព្រោះបើមិនដូច្នោះទេ អាចមានការច្រណែន ហើយឳពុកម្តាយ មិនបញ្ជូនកូនទៅសាលា ដោយសារការច្រណែននេះ "។ *(អ្នកភូមិព្នង នៅក្នុងខេត្តមណ្ឌលគិរី ឆ្លុះបញ្ចាំងពីការជ្រើសរើសកុមារពីរបីនាក់ សម្រាប់មូលនិធិអាហារូបករណ៍)* ។

" យើងសប្បាយរីករាយ ដោយសារគ្រួសារទាំងអស់ទទួលបានដូចៗគ្នា ហើយពួកគេរាប់មនុស្សទាំងអស់ គ្មាននរណាម្នាក់សល់ទេ។ នៅក្នុងគ្រួសារនីមួយៗ ទទួលបានមុងទៅតាមចំនួនមនុស្សនៅក្នុងផ្ទះ ប៉ុន្តែគ្រួសារនីមួយៗ ទទួលបានធុងដាក់ទឹកធំមួយ។ ការចែកនេះ គឺយុត្តិធម៌ "។ *(ប្តីប្រពន្ធជនជាតិព្នង អាយុ៣០ឆ្នាំ នៅខេត្តមណ្ឌលគិរី)* ។

អតីតជនភៀសខ្លួនមួយចំនួន បានរំលឹកថា ភាពតានតឹងកើតឡើង ដោយសារភាពខុសគ្នាក្នុងការទទួលបានជំនួយ និងសេវាពីខាងក្រៅ រវាងពួកគេ និងអ្នកដែលរស់នៅក្នុងមូលដ្ឋានដែលមិនបានភៀសខ្លួន ក្នុងអំឡុងពេលសង្គ្រាម។

"អគ្គិសនីសម្រាប់ប្រើប្រាស់ គួរត្រូវបានដូចៗគ្នា។ តាមវិធីនេះ ការទំនាក់ទំនងនឹងបានធម្មតា ប្រសិនបើយើងមានផ្លូវថ្នល់ដូចគេ និងមានជីវភាពដូចគេ (អ្នកមូលដ្ឋាន) នោះ វាគ្មានបញ្ហាអ្វីទេ "។ *(ស្ត្រីភៀសខ្លួន អាយុ ២០ឆ្នាំ ដែលបានធ្វើមាតុភូមិនិវត្តន៍ រស់នៅក្នុងខេត្តបាត់ដំបង)* ។

" ប្រជាជនមូលដ្ឋានជាច្រើន សួរថា ហេតុអ្វីបានជាអ្នកជំរុំ មានផ្ទះធំនៅ នៅពេលដែលពួកគេមិនមានដីសម្រាប់ដាំដុះ (ដើម្បីផ្គត់ផ្គង់ជីវភាពរបស់ពួកគេ)? "។ *បុរសអាយុ៧០ឆ្នាំ ជាអតីតជនភៀសខ្លួននៅតាមជំរុំប្រទេសថៃឡង់ រស់នៅខេត្តបាត់ដំបង* ។

" ខ្ញុំច្រណែន ខ្ញុំមិនដឹងថា ហេតុអ្វីបានជាអង្គការ ជួយអ្នកភូមិជនភៀសខ្លួន ហើយមិនជួយភូមិយើង។ ភូមិជនភៀសខ្លួន មានភ្លើងអគ្គិសនីប្រើ។ ធ្វើបែបនេះ មិនស្មើភាពទេ...... យើងច្រណែន ពីព្រោះផ្លូវនៅទីនោះល្អជាង ហើយផ្លូវនៅទីនេះ សុទ្ធតែភក់។ វាធ្វើឱ្យខ្ញុំមានអារម្មណ៍ថា ពួកគេគ្រាន់បើជាងយើង"។ *(បុរសម្នាក់មានអាយុ ៤០ឆ្នាំ ជាអ្នកភូមិមូលដ្ឋានរស់នៅជាប់ភូមិជនភៀសខ្លួន នៅខេត្តបាត់ដំបង)* ។

**ខ.ការផ្លាស់ប្តូរផ្នត់គំនិតសង្គម**

អ្នកដឹកនាំសហគមន៍ និងភូមិមួយចំនួន មានអារម្មណ៍ថា ជំនួយដែលបានកើនឡើងពីខាងក្រៅ បានប៉ះពាល់ជាអវិជ្ជមានដល់ការយល់ឃើញរបស់សហគមន៍ ចំពោះការទទួលខុសត្រូវក្នុងការគ្រប់គ្រង និងការដោះស្រាយបញ្ហាផ្ទាល់ខ្លួនរបស់ពួកគេ។ ជាពិសេស នៅពេលដែលអង្គការ បានចំណាយថវិកាឱ្យប្រជាពលរដ្ឋ ដើម្បីចូលរួមក្នុងកិច្ចប្រជុំ ការបណ្តុះបណ្តាល ឬការអនុវត្តសកម្មភាពនានា ដែលជាការរៀបចំដើម្បីកែលំអសហគមន៍ ធ្វើឱ្យប៉ះពាល់ដល់ស្មារតីនៃការស្ម័គ្រចិត្ត ដែលធ្លាប់មានកន្លងមក។ យើងបានស្តាប់ឮថា ទស្សនៈនៃការជួយគ្នាទៅវិញទៅមកកំពុងតែបាត់បង់ ដូចគ្នានឹងស្មារតីទទួលខុសត្រូវ របស់បុគ្គលម្នាក់ៗ និងសហគមន៍។

" ការចំណាយថវិកាលើប្រជាពលរដ្ឋ (អ្នកស្ម័គ្រចិត្ត) មានភាពចម្រូងចម្រាស់ និងអាចបណ្តាលឱ្យមានជំលោះ និងការច្រណែនឈ្នានីស"។ *(បុគ្គលិកអភិរក្សបរិស្ថានកម្ពុជាម្នាក់ នៅខេត្តមណ្ឌលគិរី)* ។

" យើងសុំឱ្យមានការរួមចំណែកពីសហគមន៍ដែរ ប៉ុន្តែវាពិបាករកអ្នកស្ម័គ្រចិត្ត ពីព្រោះពួកគេចង់បានប្រាក់ខែ"។ *(បុគ្គលិកអង្គការក្នុងស្រុកមួយ នៅខេត្តមណ្ឌលគិរី)* ។

" ប្រជាពលរដ្ឋចាប់ផ្តើមជឿថា ប្រសិនបើពួកគេត្រូវការធ្វើអ្វីមួយ ឬកសាងអាគារណាមួយនៅក្នុងភូមិ វាគឺជាការទទួលខុសត្រូវរបស់អង្គការអន្តរជាតិ......"។ *(បុរសដែលមានអាយុជាង៤០ឆ្នាំម្នាក់ ជាមន្ត្រីកម្មវិធីអង្គការមួយ នៅខេត្តមណ្ឌលគិរី)* ។

"ប្រជាពលរដ្ឋជួយគ្នាទៅវិញទៅមកតិចតួច ហើយសង្ឃឹមលើអង្គការ ឱ្យធ្វើច្រើនជាង ដូចជាការជួយកុមារកំព្រា... កាលពីដើម នៅក្នុងអំឡុងពេលប្រមូលផល យើងធ្វើការងារដោយដៃ ហើយមានស្មារតីជួយគ្នាទៅវិញទៅមកច្រើន។ ឥឡូវ គ្រួសារនានាច្រើនផ្តោតលើការជួយគាំទ្រខ្លួនគេផ្ទាល់។ យើងនៅតែជួយគ្នាទៅវិញទៅមក ប៉ុន្តែតិចតួច វាមិនដូចជាវប្បធម៌នៃការជួយគ្នាដូចកាលពីដើមទេ។ កាលសម័យនោះ ប្រជាជនចេះជួយគ្នាណាស់"។ *(ស្ត្រីអាយុ៥០ឆ្នាំ ជាបុគ្គលិកអង្គការក្នុងស្រុកមួយ នៅខេត្តបាត់ដំបង)* ។

"ខ្ញុំនិយាយថា គំរោងដែលផ្តល់សេវា មានភាពអវិជ្ជមាន ពីព្រោះគំរោងទាំងនោះ ងាយប៉ះពាល់ច្រើនលើវប្បធម៌ និងជំនឿរបស់ប្រជាជន"។ *(បុរសអាយុ៣០ឆ្នាំម្នាក់ ជាប្រធានអង្គការក្នុងស្រុក នៅខេត្តបាត់ដំបង)* ។

**គ. ការពឹងផ្អែក**

ប្រជាពលរដ្ឋមួយចំនួន បានប្រាប់អំពីក្តីបារម្ភរបស់ពួកគេ ចំពោះការពឹងផ្អែកលើជំនួយអន្តរជាតិ និងកម្មវិធី

ដែលគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល។ អង្គការមួយដែលផ្តល់ជំនួយដល់កុមារងាយរងគ្រោះ នៅខេត្តបាត់ដំបង បានគូសបញ្ជាក់ថា ៨០ភាគរយនៃក្រុមគោលដៅរបស់គេ នៅតែផ្តោតលើគ្រួសារជនភៀសខ្លួនដែលបានធ្វើមាតុភូមិនិវត្តន៍តាំងពីប្រមាណ១៥ឆ្នាំមុនមកម្ល៉េះ។ យោបល់ខាងក្រោម គឺជាសំណូមពរពីអតីតជនភៀសខ្លួនទាំងអស់ ដែលរស់នៅប្រទេសថៃ ហើយបានចំណាយពេលជាមធ្យម១០ឆ្នាំ នៅក្នុងជំរុំជនភៀសខ្លួន។ ការឆ្លុះបញ្ចាំងរបស់ពួកគេលើជំនួយដែលពួកគេបានទទួលនៅជំរុំ បញ្ជាក់ថា សេវាកម្មល្អប្រសើរ ប៉ុន្តែមិនបានគ្រប់គ្រាន់ ក្នុងការរៀបចំឱ្យពួកគេរស់នៅដោយឯករាជ្យដូចជាកសិករនៅតាមជនបទ នៅពេលដែលពួកគេត្រឡប់មកដល់កម្ពុជាវិញនោះទេ។ ពួកគេបានធ្វើមាតុភូមិនិវត្តន៍មករស់នៅតំបន់ជាយក្រុងនៃខេត្តបាត់ដំបង ក្នុងអំឡុងទសវត្សឆ្នាំ១៩៩០។

" កាលនៅជំរុំ យើងមិនចេះស្ទូងស្រូវ ហើយមិនដឹងថា គោក្របី មានរូបរាងយ៉ាងណាទេ។ យើងហូបសាច់ដែលគេចែកឱ្យ មានធ្យូងដុត។ យើងស្គាល់ផ្លែឈើ ប៉ុន្តែមិនស្គាល់ដើមឈើទេ។ នៅពេលដែលខ្ញុំមកដល់ស្រុកខ្មែរ ហើយបានឃើញគោ ខ្ញុំគិតថា វាជាឆ្កែធំមួយ។ ខ្ញុំលាន់មាត់ថា "ហេតុអ្វីបានជាឆ្កែធំៗម្លេះនៅស្រុកខ្មែរ?" .... បន្ទាប់ពីចេញពីជំរុំ ជីវិតមានការលំបាកណាស់។ ពីមុន ពួកគេបង្រៀនយើងឱ្យធ្វើស្តេច មិនបង្រៀនឱ្យធ្វើជារាស្ត្រសាមញ្ញទេ ឬមិនឱ្យមានការលំបាកក្នុងជីវិតនោះទេ។ ពួកគេ គួរបង្រៀនឱ្យប្រជាពលរដ្ឋមានជំនាញ បណ្តុះបណ្តាលជំនាញ។ អង្គការគួរបណ្តុះបណ្តាលពីរបៀបធ្វើស្រែចំការ យើងមិនដែលស្គាល់ពីរបៀបរស់នៅដោយលំបាកទេ"។ *(ស្ត្រីម្នាក់អាយុ២០ឆ្នាំ ជាបុគ្គលិកអង្គការក្នុងស្រុក និងជាជនភៀសខ្លួនមាតុភូមិនិវត្តន៍ នៅខេត្តបាត់ដំបង)*។

"នៅជំរុំ ក្មេងៗមិនបានដឹងពីតំលៃនៃការសិក្សាទេ ដោយសារការអប់រំផ្តល់ឱ្យដោយឥតគិតថ្លៃ... និងដោយសារពួកគេរំពឹងថា នឹងបានទៅរស់នៅស្រុកក្រៅ ហើយមានការរស់នៅស្រួល ដូចការរស់នៅក្នុងជំរុំដែរ។ នៅទីនេះ ក្មេងៗត្រូវតែធ្វើការ"។ *(ប្តីប្រពន្ធអាយុ៧០ឆ្នាំ ដែលជាអតីតជនភៀសខ្លួន រស់នៅក្នុងខេត្តបាត់ដំបង)*។

"ជួនកាល ជំនួយ គឺវាល្អហើយ ប៉ុន្តែប្រជាពលរដ្ឋមិនចេះជួយខ្លួនឯងឡើយ"។ *(បុរសម្នាក់អាយុ៣០ឆ្នាំ ជាប្រធានអង្គការក្នុងស្រុកមួយ នៅខេត្តបាត់ដំបង)*។

"ខ្ញុំនិយាយខ្មែរមិនច្បាស់ទេ ខ្ញុំមិនខ្ជិលទេ ខ្ញុំគ្រាន់តែមិនចេះរកការងារធ្វើ នៅពេលដែលខ្ញុំត្រឡប់មកស្រុកវិញ។ ជីវិតរបស់ខ្ញុំបន្ទាប់ពីចេញពីជំរុំ (ជនភៀសខ្លួន) ពិបាកយ៉ាប់យ៉ឺនជាងសម័យប៉ុលពតទៅទៀត"។ *(ស្ត្រីមេម៉ាយកូនមួយ អាយុ៣៥ឆ្នាំម្នាក់ ដែលជាជនមាតុភូមិនិវត្តន៍ រស់នៅខេត្តបាត់ដំបង)*។

**ឃ.ការខកចិត្ត និងការរំពឹកទុកដែលមិនបានដូចប្រាថ្នា**

ប្រជាពលរដ្ឋជាច្រើន ដែលយើងបានស្តាប់ មានការរំពឹងទុកខ្ពស់លើអ្វីដែលជំនួយអន្តរជាតិអាចសម្រេចបាន។ ប្រជាពលរដ្ឋ បានបង្ហាញនូវការបារម្ភពីកង្វះខាតក្នុងការផ្លាស់ប្តូរប្រកបដោយនិរន្តរភាព និងចំណុចលេចធ្លោ ដែលពួកគេយល់ថា គួរតែមានការរីកចំរើនធំដុំ ឬសម្រេចបានឆាប់ជាងនេះ។ ប្រវត្តិស្ថានភាពនៃភាព

ក្រីក្រនៅកម្ពុជា ក៏ជាការពិចារណាដ៏សំខាន់មួយ នៅក្នុងបរិបទសេដ្ឋកិច្ចដ៏ទូលាយ ដែលបង្កប់នូវរំពឹងទុក "ការអភិវឌ្ឍ" ទាំងនោះផងដែរ។ ឧទាហរណ៍ ប្រជាពលរដ្ឋឆ្ងល់ថា តើមន្ទីរពេទ្យអាចទទួលបានជោគជ័យឬទេ នៅពេលដែលប្រជាពលរដ្ឋ ពុំអាចបង់ប្រាក់ថ្លៃសេវាសុខភាពបាន។

" ខ្ញុំឃើញការផ្លាស់ប្តូរ ប៉ុន្តែមិនមានការផ្លាស់ប្តូរច្រើនទេ"។ *(ស្ត្រី អាយុ៥៥ឆ្នាំ លក់ចេកតាមចិញ្ចើមថ្នល់ នៅខេត្តពោធិសាត់)* ។

"កម្រិតជីវភាពរស់នៅមិនបានប្រសើរច្រើនប៉ុន្មានទេ ឧទាហរណ៍ បន្ទាប់ពីការវាយប្រហារលើមជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោក រដ្ឋប្រហារ និងភេរវកម្ម មូលនិធិរបស់ម្ចាស់ជំនួយត្រូវបានកាត់អស់៦០ភាគរយ ហើយអ្នកវិយោគទុនជាច្រើនបានដកចេញ។ ដូច្នេះ មានតែការងារដែលត្រូវការជំនាញតិចតួចប៉ុណ្ណោះ ដែលអាចរកបាន ហើយបច្ចុប្បន្ន មាននិស្សិតតែ១០ភាគរយប៉ុណ្ណោះ ដែលអាចរកការងារបានធ្វើ។ កម្ពុជាខ្វះការងារធ្វើយ៉ាងតិច ១០០.០០០ នាក់ ហើយតំលៃទំនិញនាពេលបច្ចុប្បន្នខ្ពស់ជាងមុន ជំនួយបរទេសមិនអាចទូទាត់តំលៃដែលកើនឡើងនេះបានទេ។ សេដ្ឋកិច្ចសេរី និងរឿងនយោបាយបានធ្វើឱ្យប្រជាជនក្រីក្រ។ លើសពីនេះទៀត អំពើពុករលួយនៅតែជាបញ្ហាដ៏ធំដដែល ហើយអ្នកមានបុណ្យស័ក្តិខ្ពស់ទទួលបានជំនួយ និងលុយច្រើន" ។ *(អ្នកសម្របសម្រួលជំនួយម្នាក់ នៅភូមិសំណង់អនាធិបតេយ្យ ជិតទីក្រុងភ្នំពេញ)* ។

"ជំនួយបានជួយលើកកំពស់ជីវភាពប្រជាពលរដ្ឋ ប៉ុន្តែមិនបានច្រើនប៉ុន្មានទេ សម្រាប់ប្រជាជនខ្លះ។ ប្រសិនបើ គ្រួសារមានទុនខ្លួនឯងខ្លះ ពួកគេមានជីវភាពល្អប្រសើរបានលឿន ជាពិសេសជាមួយជំនួយ/ការគាំទ្របន្ថែម"។ *(ស្ត្រីម្នាក់ អាយុ៤០ឆ្នាំ នៅភូមិនេសាទអណ្តែតទឹក ខេត្តពោធិសាត់)* ។

"សម្រាប់ខ្ញុំ បើអ្នកក្រឡេកមើលប្រវត្តិសាស្ត្រ យើងគួរមានមោទនភាព ដែលយើងមានអ្វីៗដូចពេលនេះ។ ខ្ញុំមានមោទនភាព តែមិនសប្បាយចិត្តទេ។ យើងបានធ្វើការតិចតួចលើហេដ្ឋារចនាសម្ព័ន្ធ តែមិនបានផ្តោតលើមូលធនសង្គម និងការគាំទ្រសុខមាលភាពទេ ហើយនេះមិនមែនជាការល្អសម្រាប់ប្រទេសជាតិនោះឡើយ"។ *(បុគ្គលិកខ្មែរម្នាក់ ធ្វើការជាមួយអង្គការអន្តរជាតិមួយ នៅទីក្រុងភ្នំពេញ)* ។

"គិតត្រឹមថ្ងៃនេះ បន្ទាប់បានទទួលជំនួយបរទេសអស់រយៈពេល១០ឆ្នាំ ស្ថាប័ននានានៅតែទន់ខ្សោយដដែល។ រដ្ឋាភិបាលត្រូវបានជំរុញដោយអង្គការសហប្រជាជាតិ និងអង្គការនានា ឱ្យធ្វើការបន្ថែមនៅជនបទ។ ការចុះមូលដ្ឋាន គ្រាន់តែធ្វើឡើងដោយមានជំនួយបរទេសប៉ុណ្ណោះ..... មានការបរាជ័យមួយយ៉ាងធំ គឺមិនបានបង្កើនប្រាក់ចំណូលនៅជនបទ។ ៧០ភាគរយនៃប្រជាពលរដ្ឋ បានចូលរួមជាចំបងក្នុងការងារកសិកម្ម តែមានតែមួយភាគរយនៃថវិកាសរុបប៉ុណ្ណោះ ដែលបានចំណាយលើវិស័យកសិកម្ម និងមានសម្បទាន រវាងហិរញ្ញប្បទានអប់រំ និងកសិកម្ម នៅពេលដែលមូលនិធិជាច្រើនថែមទៀត គួរតែទម្លាក់ទៅអោយវិស័យទាំងពីរនេះ"។ *(អ្នកស្រាវជ្រាវនៃអង្គការកម្ពុជាមួយ នៅទីក្រុងភ្នំពេញ)* ។

" ជំនួយបច្ចេកទេស គឺស្មើនឹងមួយភាគបីនៃជំនួយអភិវឌ្ឍអន្តរជាតិ ដែលវាច្រើនពេក និងមានការខ្ជះខ្ជាយចំនួនថវិកា

ដ៏ច្រើន.... មានឥទ្ធិពលតិចណាស់នៅទីនេះ ដែលស្ទើរតែមិនអាចដោះស្រាយបញ្ហាកំណើនប្រជាជន បញ្ហាគ្រឿងចក្រ ប្រាក់ខែគ្រូបង្រៀនទាប ។ យុទ្ធសាស្ត្រផ្សេងៗ ត្រូវបានបង្កើតឡើង ប៉ុន្តែថវិកានៅតែតិច ហើយជាលទ្ធផល សាលាឯកជនកំពុងរីកដុះដាលដូចផ្សិតនៅក្នុងប្រទេសនេះ "។ *(បុគ្គលិកជំនួយអន្តរជាតិម្នាក់ នៅទីក្រុងភ្នំពេញ ដែលមានបទពិសោធន៍យូរឆ្នាំនៅកម្ពុជា)* ។

"គុណភាពនៃប្រព័ន្ធអប់រំរបស់យើងនៅមានកម្រិត ហើយយើងមិនបានទទួលអ្វីលើសពីនេះទេ។ គ្រូមានប្រាក់បៀវត្សរ៍ទាប ដូច្នេះវាធ្វើឱ្យពួកគេអស់ទឹកចិត្តក្នុងការជំរុញសិស្សឱ្យខំប្រឹងទៅមុខ។ យើងមានអាគារគ្រប់គ្រាន់ ហើយសិស្សមានកន្លែងអង្គុយ ប៉ុន្តែគ្រូមិនមានប្រសិទ្ធិភាព ពួកគេត្រូវការការបណ្តុះបណ្តាល"។ *(បុគ្គលិកអង្គការអប់រំក្នុងស្រុកមួយ នៅខេត្តកំពត)* ។

"អស់រយៈពេល៣០ឆ្នាំហើយ គ្មាននរណាម្នាក់នៅភូមិនេះ ធ្លាប់បានទទួលការអប់រំគ្រប់គ្រាន់ អាចធ្វើជាគ្រូបង្រៀនបាន ដើម្បីបង្រៀនកុមារនៅក្នុងភូមិនេះទេ"។ *(កិច្ចប្រជុំជាមួយប្រធានភូមិ និងអ្នកភូមិ នៅខេត្តពោធិសាត់)* ។

ប្រជាពលរដ្ឋមួយចំនួន នៅក្នុងខេត្តបាត់ដំបង (ខេត្តជាប់ព្រំដែនថៃ) បាននិយាយទាំងរំជួលចិត្ត អំពីការរំលោភបំពានផ្សេងៗ។ ពួកគេបានឃើញផ្ទាល់ភ្នែក ឬបានអត់ទ្រាំ ក្នុងនាមជាជនភៀសខ្លួននៅជំរុំតាមព្រំដែនថៃ ក្នុងអំឡុងសង្គ្រាមស៊ីវិល។ ការរំលោភបំពានទាំងនោះ រួមទាំងការរំលោភបំពានលើរាងកាយ ការជួញដូរ ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ និងការបៀតបៀនកេរ្តិ៍ខ្មាស់ជាដើម។ ១៥ឆ្នាំក្រោយមក ស្ថានភាពនេះនៅតែជាបញ្ហាមួយ ដែលបានធ្វើឱ្យពួកគេខឹងសម្បារដដែល។ ប្រជាពលរដ្ឋភាគច្រើន ដែលយើងបានជួបពិភាក្សាមិនបានដឹងថា មានបេសកម្មអន្តរជាតិ ដើម្បីការពារប្រជាពលរដ្ឋនៅក្នុងជំរុំជនភៀសខ្លួនពីការរំលោភបំពានឡើយ។ នៅក្នុងចិត្តរបស់ពួកគេ មានតែឆ្មាំព្រំដែនជនជាតិថៃទេ ដែលជាអ្នកទទួលខុសត្រូវចំពោះទុក្ខវេទនារបស់ពួកគេ។ ប្រជាពលរដ្ឋបានបញ្ជាក់ថា វត្តមាននៃជនបរទេស គឺជាក្តីសង្ឃឹមតែមួយគត់ សម្រាប់ពួកគេក្នុងការការពារខ្លួន។

" ជនជាតិខ្មែរ បានចូលមកប្លន់អ្នកនៅក្នុងជំរុំ ហើយជនជាតិថៃបានរត់ចោលពួកគេ។ មនុស្សទាំងឡាយបានរត់សំដៅគ្លីនិកដើម្បីសុវត្ថិភាព ពីព្រោះមានជនបរទេសជាច្រើននៅទីនោះ..... ជនជាតិថៃជាច្រើននាក់ ព្យាយាមគំរាមសម្លុតទារប្រាក់ពួកគេ ធ្វើបាបអ្នកដែលបានចេញក្រៅជំរុំ ហើយបានវាយ និងបាញ់ពួកគេ..... ចោរប្លន់រត់ចូលក្នុងជំរុំ... ពួកគេគួរប្រើកំលាំងអន្តរជាតិ ដើម្បីការពារជនភៀសខ្លួន។ អង្គការអន្តរជាតិ គួរមានបុគ្គលិកបរទេសច្រើនជាងជនជាតិថៃ ពួកគេគួរមានកំលាំងអន្តរជាតិ ធ្វើដូចជា UNTAC" ។ *(ប្តី និងប្រពន្ធ មានអាយុ៧០ឆ្នាំ)* ។

" មនុស្សខ្លះ (អ្នកខាងក្រៅ) មិនបានខ្វល់ខ្វាយចំពោះយើងទេ ។ ពួកគេនៅទីនោះ ដើម្បីសប្បាយ។ មនុស្សខ្លះត្រូវគេយកទៅលាក់ទុក និងវាយធ្វើបាប.... នៅពេលដែលប្រជាពលរដ្ឋ ប្តឹងទៅជនជាតិថៃ ពួកគេមិនធ្វើអន្តរាគមន៍អ្វីឡើយ។ មានបុគ្គលិកបរទេសតែពីរនាក់ប៉ុណ្ណោះ។ ខ្ញុំមិនហ៊ាននិយាយប្រាប់បុគ្គលិកភ្នាក់ងារអន្តរជាតិទាំងនោះទេ ដោយសារជនជាតិថៃ នៅទីនោះ។ នៅពេលយប់ ជនជាតិថៃបានចូលមកក្នុងជំរុំ ហើយធ្វើបាបមនុស្សស្លូតត្រង់... ពួកគេទាត់ធាក់ប្រជាជន ដើម្បីជាល្បែងកំសាន្ត។ នៅឯសាលារៀន ពួកគេដើរក្រឡឹងជុំវិញសំឡឹងរកមើលក្មេងស្រីស្អាតៗ។ ទាហានថៃម្នាក់បានយកដៃរបស់ស្ត្រីម្នាក់

ដាក់ក្នុងប្រេងដែលកំពុងពុះ... ប្រជាពលរដ្ឋបានប្ដឹងទៅស្ត្រីបរទេសម្នាក់ ដែលធ្វើការជាមួយអង្គការអន្តរជាតិមួយ ស្ត្រីនោះបានធ្វើអន្តរាគមន៍ទៅលើទាហានថៃដែលបានប្រព្រឹត្តខុសនោះ។ ពេលដែលស្ត្រីនោះត្រឡប់ទៅផ្ទះវិញពេលយប់ ពួកទាហានថៃទាំងនោះបានធ្វើអ្វីតាមចិត្ត។ ប៉ុន្តែពេលដែលស្ត្រីនោះត្រឡប់មកវិញ យើងទទួលបាននូវការការពារ។ ប្រជាជនស្លូតត្រង់ស្រឡាញ់ គាត់ គាត់គឺជាម្ដាយរបស់ខ្មែរ"។ *(បុរសម្នាក់អាយុ៧០ឆ្នាំ ជាអតីតជនភៀសខ្លួន និងគ្រូបង្រៀននៅជុំរំ)* ។

## ការឆ្លុះបញ្ចាំងរបស់ក្រុមអ្នកស្ដាប់មតិយោបល់

ខណៈដែលអ្នកភូមិជាច្រើន ផ្ដោតលើសារៈសំខាន់នៃជំនួយជាក់ស្ដែង ដែលពួកគេបានឃើញ និងទទួល ប្រជាពលរដ្ឋនៅតំបន់ទីប្រជុំជន បានគូសបញ្ជាក់អំពីទំនាក់ទំនងដ៏រឹងមាំ រវាងតួនាទីនៃការបណ្ដុះបណ្ដាលសាធារណៈ និងឥទ្ធិពលនៃជំនួយ។ សមាជិកក្រុមអ្នកស្ដាប់មតិយោបល់ម្នាក់ បានលើកឡើងជាយោបល់ថា មានកង្វះខាតភាពជាអ្នកដឹកនាំនៅក្នុងប្រទេសនេះ ហើយឥទ្ធិពលនៃការអភិវឌ្ឍនឹងនៅមានកម្រិត បើសិនជាគ្មានភាពជាអ្នកដឹកនាំល្អ និងថាភាពជាអ្នកដឹកនាំត្រូវកសាងតាមរយៈការអប់រំ។ សមាជិកក្រុមអ្នកស្ដាប់មតិយោបល់ផ្សេងទៀត បានដកស្រង់ពាក្យសំដីសមាជិកសភាម្នាក់ ដែលបានមានប្រសាសន៍ថា " តាមរយៈការអប់រំ យើងអាចពន្យល់ប្រជាពលរដ្ឋអំពីមូលហេតុដែលធ្វើឱ្យពួកគាត់ក្រីក្រ មូលហេតុដែលគ្មានការអប់រំ និងមូលហេតុដែលគ្មានសេវាសុខាភិបាល។ នៅពេលនោះ ប្រជាពលរដ្ឋ មានចំណេះដឹង និងអាចចាប់ផ្ដើមធ្វើការផ្លាស់ប្ដូរបាន"។

សម្រាប់ប្រជាពលរដ្ឋជាច្រើន ដែលតស៊ូដើម្បីរស់ តំរូវការបន្ទាន់រយៈពេលខ្លី ល្អប្រសើរជាងការវិនិយោគរយៈពេលវែង លើកិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ។ ភាពតានតឹងរវាងការពេញចិត្តជំនួយ ដែលឆ្លើយតបចំពោះតំរូវការបន្ទាន់ ច្រើនជាងគោលដៅអភិវឌ្ឍន៍រយៈពេលយូរ បានលេចឡើងនៅក្នុងចម្លើយដែលពាក់ព័ន្ធនឹងកិច្ចប្រឹងប្រែងអភិរក្សបរិស្ថាន។ ដូចមនុស្សម្នាក់មកពីខេត្តមណ្ឌលគិរី បាននិយាយថា "ពេលដែលមនុស្សគ្មានអ្វីសម្រាប់ហូប ពួកគេលែងខ្វល់ពីនីតិរដ្ឋ ពួកគេខ្វល់តែពីរកអាហារបំពេញក្រពះប៉ុណ្ណោះ។ ភាពក្រីក្រ គឺជាបញ្ហាដ៏ធំមួយ ការអភិរក្សនឹងមិនអាចធ្វើទៅបានទេ ប្រសិនបើភាពក្រីក្រនៅតែមាននោះ"។

សំនួរមួយបានលើកឡើងក្នុងចំណោមសមាជិកក្រុមអ្នកស្ដាប់មតិយោបល់ជាច្រើនថា តើអ្នកប្រឹងប្រែងជំនួយ បង្រៀនប្រជាពលរដ្ឋថា ពួកគេក្រីក្រ និងមានការរំពឹងទុកច្រើនពីជំនួយដែរឬទេ? ឬថា តើពួកគេបង្រៀនប្រជាពលរដ្ឋថា ពួកគេគួរតែមានជីវភាពប្រសើរជាងនេះ និងមានសិទ្ធិដែរឬទេ? សមាជិកក្រុមអ្នកស្ដាប់មតិយោបល់ម្នាក់ បានមានមតិថា "កាលពីមុន ប្រជាពលរដ្ឋមិនបានដឹងថា ពួកគេត្រូវការការអភិវឌ្ឍនោះទេ ប៉ុន្តែឥឡូវនេះ យើងបង្រៀនពួកគេ ហើយពួកគេចង់បានការអភិវឌ្ឍ"។ ជនជាតិព្នង បាននិយាយថា ជំនួយបានមកដល់តំបន់របស់ពួកគេ " ដោយសារយើងជាអ្នកក្រីក្រ យើងសមទទួលបានជំនួយ "។ អ្នកដទៃទៀត ដែលហាក់ដូចជាមិនក្រីក្រផង ក៏បានស្នើសុំជំនួយ ចំណែកអ្នកខ្លះហាក់ដូចជាក្រីក្រប្រាប់ពួកយើងថា ពួកគេមិនត្រូវការជំនួយទេ"។

## III. ការអប់រំ ការចូលរួម និងភាពម្ចាស់ការ

ប្រជាពលរដ្ឋបាននិយាយថា ពួកគេរំពឹងថាអន្តរាគមន៍ជំនួយនឹងឋិតថេរបានច្រើនឆ្នាំ និងចង់ឱ្យកិច្ចប្រឹងប្រែងទាំងនេះនាំមកនូវការផ្លាស់ប្ដូរដែលមានរយៈពេលវែង។ ពួកគេបានភ្ជាប់យុទ្ធសាស្ត្រមួយចំនួនបញ្ចូលគ្នា ដែលបង្កើតនូវគំរោងមួយឋិតថេរ

ដោយចាប់ផ្តើមពីការអប់រំសហគមន៍អ្នកទទួលជំនួយ ដើម្បីឱ្យពួកគេអាចចូលរួមប្រកបដោយអត្ថន័យ។ តាមរយៈការចែករំលែកទស្សនៈមតិយោបល់រវាងអ្នកខាងក្រៅ និងអ្នកភូមិ ភាពម្ចាស់ការក៏ត្រូវបានបង្កើតឡើង។ ប្រជាពលរដ្ឋបានកត់សម្គាល់ថា ប្រសិនបើគ្មានភាពម្ចាស់ការ គ្មាននរណាម្នាក់នឹងជួសជុលអណ្តូងដែលខូចខាតឡើយ ហើយនោះគឺជាគន្លឹះសម្រាប់អន្តរាគមន៍រយៈពេលវែងដែលនៅតែបន្តមានឥទ្ធិពលលើការរស់នៅរបស់អ្នកភូមិ នៅពេលអង្គការផ្តល់ជំនួយបញ្ចប់គំរោង ហើយត្រឡប់ទៅប្រទេសគេវិញ។

ប្រជាពលរដ្ឋក៏បាននិយាយផងដែរ អំពីភាពម្ចាស់ការដែលបានកើនឡើង នៅពេលដែលអ្នកទទួលជំនួយបានកំណត់អាទិភាពលើតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ និងបានចូលរួមក្នុងការជ្រើសរើសគំរោងសមស្របជាមួយអង្គការ។ នៅពេលដែលប្រជាពលរដ្ឋ ត្រូវបានប្រាប់អំពីបញ្ហាណាមួយ និងមានជំរើសនៅក្នុងការជ្រើសរើសអន្តរាគមន៍ ពួកគេហាក់ដូចជា បានយល់ដឹងច្រើន ឬ " មានភាពម្ចាស់ការ" លើអន្តរាគមន៍នោះ។

នៅក្នុងខេត្តទាំងប្រាំ ប្រជាពលរដ្ឋបានលើកឡើងដោយស៊ីសង្វាក់គ្នា អំពីសារៈសំខាន់នៃការផ្តល់ជំនួយជាកញ្ចប់ សម្រាប់ទទួលបានជោគជ័យ។ មានការយល់ជាទូទៅថា ជំនួយខ្លះបានបាត់បង់ ដោយមានពន្យល់តិចតួច និងគ្មានការតាមដាន ធ្វើឱ្យគំរោងមិនអាចទទួលជោគជ័យបាន និងទទួលបានការប្តេជ្ញាចិត្តតិចតួចពីអ្នកទទួលជំនួយ ក្នុងការប្រើប្រាស់វាឱ្យបានល្អ។

**ក. ការចូលរួមរបស់សហគមន៍**

អង្គការក្នុងស្រុកមួយចំនួន ដែលបានចូលរួមក្នុងកិច្ចប្រឹងប្រែងជំនួយ បានពិភាក្សាអំពីផលប្រយោជន៍នៃការចូលរួមរបស់សហគមន៍ ដែលជាលទ្ធផលនៃកិច្ចប្រឹងប្រែងលើការអប់រំ និងបង្កើនសមត្ថភាព គួបផ្សំជាមួយឆន្ទៈរបស់អង្គការ និងភ្នាក់ងារខាងក្រៅ ក្នុងការស្វែងរក និងផ្តល់តម្លៃដល់មតិយោបល់របស់សហគមន៍ទទួលជំនួយ។ ប្រជាពលរដ្ឋបានគូសបញ្ជាក់ថា ការចូលរួមរបស់សហគមន៍ តាំងពីការចាប់ផ្តើមនៃកិច្ចប្រឹងប្រែងផ្តល់ជំនួយ ជាការសំខាន់ណាស់។ បុគ្គលិកអង្គការក្នុងស្រុក បានបន្ថែមថា គេមិនគួរគ្រាន់តែចុះទៅសហគមន៍ ហើយផ្តល់សម្ភារៈដល់ពួកគាត់ ប៉ុន្តែត្រូវចំណាយពេលវេលាឱ្យបានច្រើនលើការកសាងទំនាក់ទំនង និងសមត្ថភាពធ្វើសេចក្តីសំរេចចិត្ត មុនពេលបង្ហាញពីថវិកា ឬគំរោង។ ប្រជាពលរដ្ឋ ក៏បានលើកឡើងផងដែរថា ការចូលរួមប្រកបដោយអត្ថន័យរបស់សហគមន៍ ក៏បានរារាំងដល់អន្តរាគមន៍ជំនួយមិនសមស្រប និងគ្មានប្រសិទ្ធភាពផងដែរ។

នៅក្នុងតំបន់មួយចំនួន ប្រជាពលរដ្ឋបានរៀបរាប់អំពីគណៈកម្មការនានា ដែលពួកគេបានចូលរួម ដូចជា (គណៈកម្មការអភិវឌ្ឍន៍ភូមិ គណៈកម្មការអ្នកស្ម័គ្រចិត្តភូមិ និងគណៈកម្មការកសាងផែនការផ្សេងៗទៀត) ប៉ុន្តែពួកគេមានបទពិសោធន៍ខុសៗគ្នាទាក់ទងនឹងភាពស៊ីជំរៅ និងថាតើញឹកញាប់ប៉ុណ្ណា ដែលភ្នាក់ងារខាងក្រៅបានពិគ្រោះយោបល់ជាមួយពួកគេ។ នៅក្នុងករណីខ្លះដំណើការនេះមានការចូលរួមច្រើន និងបានជំរុញដោយប្រជាពលរដ្ឋមូលដ្ឋាន ហើយករណីផ្សេងទៀត ក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្វើជាអ្នកដឹកនាំ ឬអង្គការជាតិ និងអន្តរជាតិ ដើរតួជាអ្នកជំរុញដំណើការនេះ។ ក្នុងករណីជាច្រើន អ្នកភូមិ (ទាំងស្ត្រី និងបុរស) មិនបានយល់ច្បាស់អំពីរបៀបដំណើរការរបស់គណៈកម្មការទាំងនេះ នៅថ្នាក់ភូមិរបស់ពួកគេទេ។

"ប្រជាពលរដ្ឋត្រូវការការអប់រំ មុនពេលពួកគេអាចផ្តល់ការរួមចំណែកដ៏ពិតប្រាកដ។ កុំគ្រាន់តែមកប្រកាសថា ធុងទឹក

មកដល់ហើយ។ ត្រូវឱ្យប្រជាពលរដ្ឋចូលរួមតាំងពីពេលចាប់ផ្តើម ហើយកសាងទំនុកចិត្តឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យពួកគេអាចបដិសេធជំនួយបាន។ សម្រាប់យើង នេះមានន័យថា យើងត្រូវចំណាយពេលវេលាឱ្យច្រើននៅក្នុងសហគមន៍ដោយផ្ទាល់..... ជារឿយៗ យើងគ្រាន់តែទៅស្តាប់ និងប្រាប់ពួកគេអំពីការអភិវឌ្ឍសហគមន៍ប៉ុណ្ណោះ។ នៅពេលដែលប្រជាពលរដ្ឋ លើកឡើងពីបញ្ហាដែលពួកគេជួបប្រទះ យើងក៏ជំរុញពួកគេឱ្យចូលរួមក្នុងការពិភាក្សាថា តើអ្នកភូមិត្រូវធ្វើដូចម្តេច ដើម្បីដោះស្រាយបញ្ហាទាំងនោះ។ យើងចង់កសាងសមត្ថភាពធ្វើសេចក្តីសំរេចរបស់សហគមន៍ មុនពេលនាំយកជំនួយជាសាច់ប្រាក់ ឬគំរោងចូលក្នុងសហគមន៍..... អង្គការមួយ បានប្រើការប្រជុំ និងកិច្ចសន្ទនា ដើម្បីកសាងសមត្ថភាព នៅក្នុងភូមិនីមួយៗ ដើម្បីឱ្យពួកគេមានលទ្ធភាពក្នុងការកំណត់តម្រូវការ និងស្វែងយល់អំពីរបៀបបង្កើតការព្រមព្រៀងរួម ក្នុងចំណោមសមាជិកសហគមន៍ ដើម្បីឱ្យប្រជាពលរដ្ឋមានទំនុកចិត្ត ក្នុងការលើកយកបញ្ហារបស់ពួកគេមកពិភាក្សា និងរៀនដោះស្រាយបញ្ហាទាំងនោះដោយខ្លួនឯងផ្ទាល់"។ *(បុរសអាយុជាង៤០ឆ្នាំម្នាក់ ជាបុគ្គលិកអង្គការក្នុងស្រុកមួយ នៅខេត្តមណ្ឌលគិរី)* ។

" ខ្ញុំចង់ស្វែងយល់បន្ថែមអំពីសិទ្ធិមនុស្ស និងរបៀបនៃការគ្រប់គ្រងធនធានធម្មជាតិ — គេបានខ្ញុំប្រាប់ថា ខ្ញុំមិនអាចកាប់ឈើនេះបានទេ ពីព្រោះវាជាតំបន់ការពារធម្មជាតិ។ ខ្ញុំគិតថា មានបញ្ហាជាច្រើននៅក្នុងបញ្ហានេះ ប៉ុន្តែខ្ញុំមិនយល់អំពីការការពារច្រើនប៉ុន្មានទេ"។ *(ស្ត្រីជនជាតិព្នង នៅខេត្តមណ្ឌលគិរី)* ។

" ដោយសារមានអង្គការខាងក្រៅច្រើននៅក្នុងតំបន់នេះ ខ្ញុំបានឃើញអ្នកភូមិរបស់ខ្ញុំមានរបៀបរៀបរយ និងមានមតិច្រើនក្នុងកិច្ចប្រជុំឃុំ ព្រមទាំងបានបញ្ចេញយោបល់របស់ពួកគេ។ មានការចូលរួមកាន់តែច្រើន។ កាលពីមុនជនជាតិព្នង រស់នៅតែឯងក្នុងព្រៃ ហើយមិនបានគិតអំពីសកម្មភាពជាក្រុមអ្វីនោះឡើយ។ ឥឡូវ ពួកគេរស់នៅជាមួយគ្នាក្នុងភូមិ ហើយចូលរួមក្នុងសកម្មភាពជាក្រុម ធ្វើសេចក្តីសំរេចជាមួយគ្នា និងចង់ទំនាក់ទំនងជាមួយសង្គមឱ្យបានទូលំទូលាយជាងនេះ។ នេះគឺជាចំណុច ល្អ "។ *(ស្ត្រីជនជាតិព្នង អាយុ៣០ឆ្នាំ នៅក្នុងខេត្តមណ្ឌលគិរី)* ។

" ប្រជាពលរដ្ឋបានពឹងផ្អែកលើជំនួយ ឬបានចូលរួមក្នុងសកម្មភាពផ្តល់ជំនួយ — ពួកគេកំពុងចូលរួម..... ប្រសិនបើប្រជាពលរដ្ឋ មិនបានចូលរួមពាក់ព័ន្ធជាមួយគំរោងទេ ពួកគេនឹងគ្មានម្ចាស់ការលើគំរោង និងមិនគិតគូរពីវាឡើយ។ ប្រសិនបើប្រជាពលរដ្ឋបានទទួលការវិនិយោគលើការអភិវឌ្ឍ ពួកគេនឹងយកចិត្តទុកដាក់លើការអភិវឌ្ឍនោះ"។ *(មន្ត្រីអង្គការក្នុងស្រុកមួយ នៅខេត្តកំពត)* ។

នៅខេត្តពោធិសាត់ ក្រុមអ្នកស្តាប់មតិយោបល់បានឮគ្រួសារមួយនិយាយថា មានគេមកសួរគាត់ថា តើគាត់មានកូនប៉ុន្មាននាក់ ហើយស្រាប់តែផ្តល់រូបមន្តប្រើទឹកដោះគោសម្រាប់ទារកតែម្តង។ ពួកគេសន្និដ្ឋានថា ប្រធានភូមិគឺជាអ្នកសំរេចថា តើសម្ភារៈ ឬការបណ្តុះបណ្តាលអ្វីដែលត្រូវផ្តល់ឱ្យអ្នកភូមិ ប៉ុន្តែពួកគេពុំបានដឹងថា តើសេចក្តីសំរេចនោះធ្វើឡើងដូចម្តេចទេ ថែមទាំងមិនមានឱកាសប្រាប់ប្រជាពលរដ្ឋអំពីអ្វីដែលជាតំរូវការរបស់ពួកគេទៀតផង។

## ៩. ភាពម្ចាស់ការ

ក្នុងករណីជាច្រើន ទាំងអ្នកដឹកនាំអង្គការក្នុងស្រុក និងអ្នកទទួលជំនួយ បានប្រាប់ក្រុមអ្នកស្តាប់មតិយោបល់ថា ពួកគេមានអារម្មណ៍ថា គំរោងគឺជារបស់ពួកគេផ្ទាល់ ឬសម្រាប់ផលប្រយោជន៍ពួកគេ ដូច្នេះហើយទើបពួកគេមានអារម្មណ៍ទទួលខុសត្រូវក្នុងការចាត់ចែង ការថែទាំ ឬក៏ផ្តល់មូលនិធិដល់គំរោង។ ក្នុងករណីខ្លះ ទំនួលខុសត្រូវបានប្តូរពីអង្គការ ទៅជារចនាសម្ព័ន្ធសហគមន៍ដែលបានបង្កើតឡើងដើម្បីគ្រប់គ្រងគំរោង។ ភាពម្ចាស់ការមានបញ្ហាច្រើន នៅពេលដែលគំរោងមិនសមស្របទៅនឹងតំរូវការរបស់ប្រជាពលរដ្ឋដូចដែលពួកគេបានកំណត់។ ប្រជាពលរដ្ឋ បានគូសបញ្ជាក់ថា គេត្រូវការពេលវេលា ដើម្បីបង្កើតភាពម្ចាស់ការលើគំរោង និងថា វាមិនអាចប្រព្រឹត្តទៅបានលឿននោះទេ។

អ្នកភូមិជនជាតិព្នងពីរនាក់នៅក្នុងខេត្តមណ្ឌលគីរី បានបង្ហាញពីជំនឿយ៉ាងខ្លាំងថា ការស្ថាបនាផ្លូវ គួរមានការចូលរួមពីប្រជាពលរដ្ឋផង ពីអាជ្ញាធរមូលដ្ឋានផង ពីព្រោះវាជាសម្បត្តិសមូហភាព។ អ្នកភូមិមួយចំនួន មានឆន្ទៈក្នុងការរួមចំណែកជាប្រាក់ ចំណែកអ្នកភូមិមួយចំនួនទៀត រួមចំណែកជាកំលាំងពលកម្មសម្រាប់ការស្ថាបនាផ្លូវ ដោយនិយាយថា " ផ្លូវនេះ មិនមែនជាផ្លូវរបស់អង្គការ របស់រដ្ឋាភិបាល ប៉ុន្តែវាជាផ្លូវរបស់អ្នកភូមិ។ យើងគឺជាអ្នកប្រើប្រាស់ផ្លូវនេះ ដូច្នេះយើងគួរតែរួមចំណែកផងដែរ។ យើងមានឆន្ទៈ ក្នុងការប្រមូលថវិកា ដើម្បីចំណាយសម្រាប់ផ្លូវនេះ។ យើងអាចយកថវិកាទៅឱ្យក្រុមប្រឹក្សាឃុំ ឬអង្គការដើម្បីអោយពួកគេស្ថាបនាផ្លូវ។ យើងមិនអាចរួមចំណែកជាកំលាំងពលកម្មទាំងអស់ទេ ដោយសារយើងមានភារៈកិច្ចធ្វើស្រែចំការ ប៉ុន្តែយើងអាចចូលរួមមួយចំណែកលើគំរោងអភិវឌ្ឍន៍នេះ"។

" ភាពម្ចាស់ការមូលដ្ឋាន មានសារៈសំខាន់ ហើយគួរតែផ្ទេរការគ្រប់គ្រងពីជនបរទេស ឱ្យរដ្ឋាភិបាល និងប្រជាពលរដ្ឋនៅមូលដ្ឋាន"។ *(បុគ្គលិកមន្ទីរបរិស្ថាន និងដែនជំរកសត្វព្រៃ ខេត្តពោធិសាត់)*។

"ទោះបីជាពួកគេ (ជនបរទេសដែលជាអ្នកផ្តល់មូលនិធិផ្តួចផ្តើម) មិនត្រឡប់មកវិញ ក៏យើងអាចរស់បានដែរ ហើយយើងនឹងបន្តរស់នៅទីនេះ និងយកកុមារមកចិញ្ចឹមជាច្រើនទៀត ប្រសិនបើចាំបាច់ "។ *(អ្នកគ្រប់គ្រងមណ្ឌលកុមារកំព្រាសាងសង់ដោយក្រុមគ្រីស្តសាសនិក ដែលបានចាកចេញកាលពីពីរឆ្នាំមុន នៅក្នុងភូមិព្នងដាច់ស្រយាលមួយ នៅខេត្តមណ្ឌលគីរី)*។

" ការចូលរួមមានសារៈសំខាន់ ពីព្រោះគំរោងគឺសម្រាប់ពួកគេ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ពួកគេ ប្រសិនបើពួកគេមានភាពម្ចាស់ការ ពួកគេគិតគូរពីគំរោងនេះ។ ដូច្នេះហើយបានជាការយល់ដឹងពីតំរូវការរបស់ប្រជាពលរដ្ឋ និងការបំពេញតម្រូវការទាំងនោះ គឺជាការសំខាន់ "។ *(សមាជិកក្រុមប្រឹក្សាឃុំ នៅខេត្តពោធិសាត់)*។

ក្នុងករណីខ្លះ បញ្ហាប្រឈមសម្រាប់ភាពម្ចាស់ការ ត្រូវបានសង្កត់ធ្ងន់ថា គេត្រូវការពេលវេលាច្រើនដើម្បីឱ្យសហគមន៍បានយល់ដឹង និងចូលរួមធនធាន ជាពិសេសសម្រាប់គំរោងដែលមានបំណងកែប្រែផ្នត់គំនិតវប្បធម៌ និងគុណតម្លៃ ឬគំរោងដែលត្រូវការកិច្ចប្រឹងប្រែង និងធនធានបន្ថែមពីអ្នកទទួលជំនួយ។ ដោយមិនប្រើពេលច្រើនថែមទៀត ដើម្បីបង្កើនការយល់ដឹង ប្រជាពលរដ្ឋបាននិយាយថា វាជាការលំបាក ក្នុងការទទួលបានជោគជ័យលើភាពម្ចាស់ការ។

" យើងចំណាយពេលវេលាយ៉ាងយូរ ដើម្បីយល់អំពីវប្បធម៌ តម្រូវការ និងសមត្ថភាពរបស់សហគមន៍។ គ្មានគំរោងថ្មី

អនុវត្តទេ ប្រសិនបើសហគមន៍ មិនបានពិភាក្សា និងយល់ព្រមលើគំរោងទាំងនោះ។ យើងបានឃើញសមាគមភូមិមូលដ្ឋាន បង្កើនការសន្ទ្យំថវិកាសមូហភាពរបស់ពួកគេ ហើយយើងដឹងថា ពួកគេនឹងមាននិរន្តរភាពនៅពេលអនាគត"។ *(បុរសម្នាក់ អាយុ៤០ឆ្នាំ ជាបុគ្គលិកអង្គការក្នុងស្រុក នៅខេត្តមណ្ឌលគិរី)* ។

**គ. អន្តរាគមន៍ជំនួយទាំងស្រុង ការទទួលកញ្ចប់ទាំងមូល**

ប្រជាពលរដ្ឋនៅក្នុងខេត្តទាំងប្រាំ បានលើកឡើងដោយស៊ីសង្វាក់គ្នា អំពីសារៈសំខាន់នៃការផ្ដល់ជំនួយជាកញ្ចប់។ លើកលែងតែជនក្រីក្រ ប្រជាពលរដ្ឋបានប្រាប់ពួកយើងថា ពួកគេពេញចិត្តកម្មវិធីកសាងសមត្ថភាព ជាងជំនួយសំភារៈរយៈពេលខ្លី ដោយកត់សម្គាល់ថា ពួកគេបានយល់ដឹងពីភាពក្លាហានផ្ទាល់ខ្លួន ពីការសន្សំជំនាញ ដែលពួកគេអាចប្រើបាននៅពេលអនាគត។

" ការទទួលជំនួយជាសំភារៈ និងរបស់របរប្រើប្រាស់ មិនល្អដូចការទទួលការបណ្ដុះបណ្ដាល ឬការកសាងសមត្ថភាពទេ។ បន្ទាប់ពីទទួលបានការបណ្ដុះបណ្ដាលពីអង្គការ យើងមានគំនិតដើម្បីគ្រប់គ្រងលុយកាក់របស់យើង ចាប់ផ្ដើមប្រកបមុខរបររកស៊ី។ វាល្អសម្រាប់ការអភិវឌ្ឍរបស់យើង..... មានការច្នៃប្រឌិតច្រើន មានគំនិតថ្មី"។ *(សមាជិកសហគមន៍ នៅខេត្តពោធិសាត់)* ។

" យើងបានស្នើសុំជំនួយ ហើយបានទទួលពូជស្រូវ ប៉ុន្តែពូជស្រូវថ្មី វាខុសប្លែក វាដុះក្នុងរដូវផ្សេង ហើយវាមិនដូចពូជ ស្រូវចាស់ឡើយ។ យើងនៅតែត្រូវការការបណ្ដុះបណ្ដាលបន្ថែម..... មាន់ដែលគេបានឱ្យយើង ងាប់អស់ហើយ..... ដើមឈើហូបផ្លែ ក៏មិនបានជោគជ័យដែរ ព្រោះវាធន់នឹងអាកាសធាតុនេះមិនបាន។ ជំនួយជាសត្វពាហនៈ មិនបានពិនិត្យតាមដាន ចាក់វ៉ាក់សាំងទាន់ពេលវេលា ហើយមានព័ត៌មានតិចតួច ដែលបានចែករំលែក រវាងអង្គការ និងសហគមន៍"។ *(កសិករជាជនជាតិព្នង នៅខេត្តមណ្ឌលគិរី)* ។

" អង្គការមួយចំនួន មកជួយបង្រៀនប្រជាពលរដ្ឋអំពីរបៀបដាំដុះ មិនសូវមានប្រយោជន៍ប៉ុន្មានទេ ពីព្រោះពួកគេមិនគួរបង្រៀនការដាំដុះតាមតែទ្រឹស្ដីប៉ុណ្ណោះ ប៉ុន្តែគួរបង្ហាញជាមុនដោយការអនុវត្ត។ បើមិនដូច្នោះទេ យើងមិនបានយល់ច្បាស់ទេ យើងត្រូវការអ្វីច្រើនទៀត ក្រៅពីការនិយាយ។ អង្គការគួរផ្ដល់គំរូបង្ហាញពីរបៀបដាំដុះ"។ *(ស្ត្រីមេម៉ាយ អាយុប្រហែល២៥ឆ្នាំ នៅខេត្តបាត់ដំបង)* ។

" ការកសាងសមត្ថភាពរបស់គ្រូបង្រៀន ក៏មានសារៈសំខាន់ណាស់ផងដែរ។ ការកសាងសាលារៀនតែម្យ៉ាង មិនទាន់គ្រប់គ្រាន់ទេ យើងត្រូវបង្កើតការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីថា តើហេតុអ្វីបានជាការអប់រំមានសារៈសំខាន់។ នៅក្នុងតំបន់ខ្លះ វាមិនមែនជាឆន្ទៈរបស់ប្រជាពលរដ្ឋ ដែលមិនចង់បញ្ជូនកូនទៅរៀនទេ ប៉ុន្តែភាពក្រីក្រគឺជាកត្តារារាំងពួកគេ។ នៅក្នុងសហគមន៍ក្រីក្រមួយ កុមារនៅតែបន្តទៅរៀននៅសាលាមត្តេយ្យទាំងស្រាតទទេ ដោយសារឪពុកម្ដាយពុំមានសំលៀកបំពាក់សម្រាប់ពួកគេ។ នៅក្នុងស្ថានភាពប្រភេទនេះ អ្នកត្រូវតែដោះស្រាយបញ្ហាទាំងមូលជារួម។ អ្នកមិនមែនគ្រាន់តែត្រូវផ្ដល់ការអប់រំប៉ុណ្ណោះទេ ប៉ុន្តែត្រូវការដោះស្រាយកត្តាផ្សេងទៀត ដែលធ្វើប្រជាពលរដ្ឋក្នុងស្ថិតក្នុងភាពក្រីក្រ ដូចជាជម្រើសនៃការចិញ្ចឹមជីវភាពនៅមានកំរិត"។ *(ស្ត្រីម្នាក់ អាយុ៥០ឆ្នាំ ជាប្រធានអង្គការក្នុងស្រុក នៅខេត្តពោធិសាត់)* ។

" វាជាការសំខាន់សម្រាប់អង្គការ ក្នុងការផ្ដល់ការគាំទ្របច្ចេកទេស ការត្រួតពិនិត្យ និងតាមដានសម្រាប់ភាពជោគជ័យ

មិនមែនគ្រាន់តែឱ្យលុយ ហើយចាកចេញទៅបាត់នោះទេ" ។ *(អនុប្រធានភូមិ នៅខេត្តពោធិសាត់)* ។

"អង្គការអន្តរជាតិ បានឱ្យប្រជាពលរដ្ឋធ្វើមាតុភូមិនិវត្តន៍ត្រឡប់មកស្រុកវិញ ប៉ុន្តែពួកគេមិនបានចាប់ដៃជាមួយអង្គការអភិវឌ្ឍន៍ឡើយ ។ ដូច្នេះ ប្រជាពលរដ្ឋ បានត្រឡប់កមដល់ស្រុកវិញ ហើយជួបការលំបាកយ៉ាងខ្លាំង ក្នុងការរកស៊ីចិញ្ចឹមជីវិតដើម្បីរស់" ។ *(បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់ ដែលជាជនមាតុភូមិនិវត្តន៍ នៅខេត្តបាត់ដំបង)* ។

" ជនមាតុភូមិនិវត្តន៍ជាច្រើន ទទួលបានការបណ្តុះបណ្តាលជំនាញនៅជំរុំ ប៉ុន្តែក្រោយមក ពួកគេមិនបានប្រើប្រាស់ជំនាញទាំងនោះនៅជនបទទេ ដោយសារជំនាញទាំងនោះ មិនសមស្របសម្រាប់តំបន់ជនបទ ឬដោយសារពួកគេគ្មានដើមទុន" ។ *(បុរសម្នាក់ អាយុ៣០ឆ្នាំ ជាបុគ្គលិកអង្គការក្នុងស្រុក នៅខេត្តបាត់ដំបង)* ។

**ឃ. ជំនួយអភិវឌ្ឍរយៈពេលវែង និងជំនួយសង្គ្រោះបន្ទាន់រយៈពេលខ្លី**

ប្រជាពលរដ្ឋភាគច្រើន ដែលយើងបានស្តាប់ និងដែលបានទទួលជំនួយសង្គ្រោះបន្ទាន់ បានប្រាប់យើងថា ពួកគេចង់បានជំនួយអភិវឌ្ឍន៍រយៈពេលវែង ។ ឧទាហរណ៍ អ្នកដែលបានទទួលកញ្ចប់ជំនួយសម្រាប់ការរស់រាន ពីមេរោគអេដស៍/ជំងឺអេដស៍ ពួកគេចង់បានកម្មវិធីបង្កើតប្រាក់ចំណូល ។

ទោះបីជាសាលារៀនត្រូវបានមើលឃើញថា មានសារៈសំខាន់ក៏ដោយ ក៏មានការទទួលស្គាល់ថា ប្រសិនបើគ្មានការវិនិយោគរយៈពេលវែងទៅលើគ្រូបង្រៀន និងការយល់ដឹងរបស់សហគមន៍អំពីសារៈសំខាន់នៃការអប់រំ តំលៃរបស់សាលារៀនមានកំរិតទាបបំផុត ។ នៅតំបន់ជនបទ ប្រជាពលរដ្ឋមួយចំនួនពុំមានជំនឿលើឱកាស នៃការខិតខំប្រឹងប្រែងលើការអប់រំរយៈពេលវែងទេ ដោយហេតុថា គ្រូបង្រៀនជាច្រើនគ្មានការងារធ្វើ ។ ប្រជាពលរដ្ឋមួយចំនួនបានចោទប្រកាន់ថា ការផ្តល់ឱកាសចូលរៀននៅតាមសាលាមិនគ្រប់គ្រាន់ឡើយ ។ នៅក្នុងភូមិមួយចំនួន ប្រជាពលរដ្ឋគ្មានអាហារបរិភោគ និងសំលៀកបំពាក់ស្លៀកពាក់ ហើយការកសាងសាលារៀន មិនអាចដោះស្រាយបញ្ហាភាពក្រីក្រដ៏ធ្ងន់ធ្ងររបស់ពួកគេបានទេ ។ បុរសម្នាក់ បាននិយាយថា សម្រាប់គាត់ផ្លូវសំខាន់ជាងសាលារៀន ពីព្រោះវាជាក់ស្តែងជាង ។ គាត់អាចមើលវាឃើញ អាចធ្វើដំណើរតាមនោះ ហើយអាចប្រើប្រាស់បាននៅពេលបច្ចុប្បន្ន ។ សាលារៀន គឺជាការអប់រំសម្រាប់កូនរបស់គាត់ ហើយគាត់អាចឃើញប្រយោជន៍របស់វា នៅពេលក្រោយក្នុងជីវិត ។

"ខ្ញុំទទួលបានជំនួយអង្ករពីជនជាតិម៉ាឡេស៊ីម្តងដែរ វាមិនមានប្រយោជន៍ទេ ខ្ញុំចង់រៀនរបៀបរកស៊ី ខ្ញុំចេះដុតនំប៉ុង ប៉ុន្តែខ្ញុំក៏ត្រូវការដើមទុនដែរ" ។ *(ស្ត្រីម្នាក់ អាយុ២៥ឆ្នាំ មានកូនមួយ)* ។

" ការបណ្តុះបណ្តាលជំនាញប្រសើរជាងសម្ភារៈ យើងអាចបង្កើនប្រាក់ចំណូល វាជួយយើងឱ្យចេះច្នៃប្រឌិតច្រើន យើងមានជំរើសច្រើនសម្រាប់ជីវភាពរស់នៅរបស់យើង ហើយយើងអាចប្រើប្រាស់ប្រាក់ចំណេញ ដើម្បីទិញវត្ថុផ្សេងៗដែលយើងត្រូវការ ( ស្រូវអង្ករ ម្ហូបអាហារ និងថ្នាំពេទ្យ) ។ *(ស្ត្រីម្នាក់ក្នុងចំណោមស្ត្រីប្រាំនាក់ដែលឈរលក់ចេកចៀននៅលើចិញ្ចើមថ្នល់ ក្នុងខេត្តកំពត)* ។

"ប្រសិនបើគេផ្តល់ជំនួយកសិកម្មដល់យើង វាជាការប្រសើរ ។ ជំនាញកសិកម្ម និងពូជដំណាំថ្មី អាចឋិតថេរបាន

យូរ ហើយអាចចិញ្ចឹមប្រជាពលរដ្ឋបានយូរ"។ *(ស្ត្រីកសិករម្នាក់ អាយុជាង៦០ឆ្នាំ នៅខេត្តមណ្ឌលគិរី)* ។

**ការឆ្លុះបញ្ចាំងរបស់សមាជិកក្រុមអ្នកស្ដាប់មតិយោបល់**

សមាជិកក្រុមអ្នកស្ដាប់មតិយោបល់ បានកត់សំគាល់ថា ការធ្វើការដើម្បីជំរុញភាពម្ចាស់ការ មានន័យផងដែរថា ជាការផ្ដល់ឱ្យសហគមន៍នូវការគ្រប់គ្រងច្រើនថែមទៀត។ នៅពេលដែលអ្នកខាងក្រៅ ដណ្ដើមឱកាសពីសហគមន៍ក្នុងការកំណត់ថា តើនរណាដែលងាយរងគ្រោះ ឬនរណាដែលសមនឹងទទួលបានធនធានដែលមានកំរិតនោះ ធ្វើឱ្យភាពម្ចាស់ការមានការថយចុះ។ លើសពីនេះទៀត ក៏មានការពាក់ព័ន្ធគួរឱ្យកត់សំគាល់ រវាងការយល់ដឹងពីអន្តរាគមន៍ និងការមានភាពម្ចាស់ការលើអន្តរាគមន៍នោះផងដែរ។ ដូចសមាជិកក្រុមអ្នកស្ដាប់ម្នាក់ បានចង្អុលបង្ហាញថា "តើអ្នកអាចមានការប្ដេជ្ញាចិត្តពេញលេញយ៉ាងដូចម្ដេច ចំពោះការអភិរក្សបរិស្ថាន ដោយគ្មានចំណេះដឹងគ្រប់គ្រាន់ថា ការកាប់ដើមឈើធ្វើឱ្យខូចប្រយោជន៍ និងអន្តរាយដល់អនាគតកូនចៅរបស់អ្នកដោយរបៀបណានោះ?" ដោយគ្មានពត៌មានបែបនេះ អ្នកទទួលជំនួយអាចធ្វើមិនដឹងមិនឮចំពោះជំនួយបានយ៉ាងងាយស្រួល។

ចំពោះបញ្ហាជំនួយរយៈពេលវែង និងរយៈពេលខ្លី សមាជិកក្រុមអ្នកស្ដាប់មតិយោបល់ បានកត់សំគាល់ថា ប្រជាពលរដ្ឋមានទស្សនៈវែងឆ្ងាយ ចំពោះរបៀបដែលពួកគេចង់ជួយខ្លួនឯង ដែលជារឿយៗលាតសន្ធឹងហួសពីចក្ខុវិស័យរយៈពេលខ្លីរបស់អង្គការខាងក្រៅ។ សមាជិកក្រុម បានលើកជាសំនួរថា តើគេនឹងធ្វើសេចក្ដីសំរេចចិត្តដូចម្ដេច ទាក់ទងនឹងថា តើនរណាគួរទទួលបានជំនួយរយៈយូរ ឬរយៈពេលខ្លី ដោយយល់ដឹងថា ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលពេញចិត្តផ្ដល់ជំនួយរយៈពេលខ្លីជាង ពីព្រោះវាងាយស្រួល ហើយស្របនឹងគោលនយោបាយ និងអាទិភាពរបស់ប្រទេសអ្នកផ្ដល់ជំនួយ។ ពួកគេបានកត់សំគាល់ថា លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតំលៃថា តើគំរោងណាមួយទទួលបានជោគជ័យនោះ ជារឿយៗ ពឹងផ្អែកលើគោលបំណងផ្សេងៗគ្នារបស់អ្នកផ្ដល់មូលនិធិអន្តរជាតិ ដែលអាចមានចាប់ពីតំលៃ-ប្រសិទ្ធិភាព (cost-effectiveness) (សម្រាប់មូលនិធិមួយចំនួន) ការសម្រេចគោលបំណងផ្នែកនយោបាយ (សម្រាប់រដ្ឋាភិបាលមួយចំនួន) រហូតដល់និរន្តរភាព (សម្រាប់អង្គការអន្តរជាតិមួយចំនួន)។ មនុស្សមួយចំនួនបានសួរសំនួរថា "តើហេតុអ្វីបានជាកិច្ចការនយោបាយរបស់យើងមិនស៊ីគ្នា?"។

ដើម្បីដោះស្រាយបញ្ហាប្រឈមមុខ ក្នុងការធ្វើការជាមួយប្រជាពលរដ្ឋក្រីក្រ ដែលមានតម្រូវការបន្ទាន់ និងរយៈពេលវែង មនុស្សមួយចំនួនបានផ្ដល់យោបល់ថា អន្តរាគមន៍ត្រូវបំពេញតម្រូវការជាមូលដ្ឋានជាមុនសិន ហើយបន្ទាប់មកត្រូវផ្ដោតលើការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹងអំពីសិទ្ធិរបស់ខ្លួន។ ពួកគេបានបញ្ជាក់ថា នៅពេលដែលប្រជាពលរដ្ឋ បានយល់ដឹងអំពីសិទ្ធិរបស់ខ្លួន និងមានលទ្ធភាពស្វែងរកជំនួយគាំទ្រផ្សេងៗទៀតបាន ស្ថានភាពរបស់ពួកគេនឹងបានប្រសើរឡើង ហើយពួកគេនឹងមានភាពម្ចាស់ការ និងមានសមត្ថភាព។ ឧទាហរណ៍ ប្រសិនបើពួកគេចេះច្បាប់ភូមិបាល នោះពួកគេអាចបន្តទាមទារកម្មសិទ្ធិលើដីនោះ ពីព្រោះវាជាសិទ្ធិស្របច្បាប់របស់ពួកគេ។

ជាទីបញ្ចប់ សមាជិកក្រុមអ្នកស្ដាប់បានពិចារណាថា តើអ្នកផ្ដល់ជំនួយមានតួនាទីអ្វីខ្លះក្នុងការជំរុញភាពម្ចាស់ការ

លើគំរោងការនៅថ្នាក់សហគមន៍? ហើយចំពោះអង្គការក្នុងស្រុក តើបន្ទុកដ៏ធ្ងន់ក្នុងការធ្វើសំណើរ និងសរសេររបាយការណ៍ជាភាសាអង់គ្លេស ប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក៏រិតណាដែរ ក្នុងការអាចអោយពួកគេទទួលខុសត្រូវពិតប្រាកដចំពោះគំរោងរបស់ខ្លួន?

## IV. ពត៌មាន និងការយល់ដឹងអំពីកិច្ចប្រឹងប្រែងជំនួយ

មានការភ័ន្តច្រឡំជាច្រើន ក្នុងចំណោមប្រជាពលរដ្ឋនៅថ្នាក់ភូមិអំពីថា តើជំនួយអ្វីដែលអាចមាន? តើជំនួយបានមកដល់ភូមិរបស់ពួកគេឬទេ? តើជំនួយនឹងមកដល់ភូមិរបស់ពួកគេឬទេ? តើជំនួយមិនធ្លាប់មកដល់ភូមិរបស់ពួកគេឬទេ? និងតើហេតុអ្វីបានជាដូច្នោះ? នៅក្នុងករណីភាគច្រើន ប្រជាពលរដ្ឋ មិនបានដឹងច្បាស់ថា តើជំនួយនោះបានមកពីទីណាទេ ឬតើជំនួយអន្តរជាតិគឺជាអ្វីឡើយ។ អ្នកភូមិក៏មិនយល់ច្បាស់ផងដែរថា តើនៅពេលដែលការផ្តួចផ្តើមគំនិតអភិវឌ្ឍន៍សហគមន៍ត្រូវបានដឹកនាំដោយរដ្ឋាភិបាល ឬដឹកនាំដោយអង្គការអន្តរជាតិនោះ។ តាមរយៈការស្តាប់ប្រជាពលរដ្ឋនៅតាមតំបន់ផ្សេងៗគ្នា យើងបានដឹងច្បាស់ថា វដ្តនៃការប្រាស្រ័យទាក់ទងរវាងអ្នកអនុវត្តកិច្ចប្រឹងប្រែងជំនួយអន្តរជាតិ បើទោះជាម្ចាស់ជំនួយ អង្គការអន្តរជាតិ អង្គការក្នុងស្រុក ឬរដ្ឋាភិបាលកម្ពុជាក្តី មិនបានប្រព្រឹត្តិទៅជាមួយអ្នកទទួលជំនួយទេ។ ហើយប្រសិនបើការប្រាស្រ័យទាក់ទងបែបនេះពិតជាបានកើតឡើងមែននោះ ក៏វាមិនបានទៅដល់អ្នកភូមិទូទៅ ដែលមិនមែនជាគណៈកម្មការសហគមន៍នោះឡើយ។ ប្រជាពលរដ្ឋ តែងតែត្រូវបានគេហៅអោយមកបង្ហាញវត្តមាន និងចូលរួមដោយគ្មានការពន្យល់ណែនាំអំពីគំរោង។ កង្វះខាតព័ត៌មាននេះ ក៏បានជំរុញឱ្យមានទស្សនៈ និងប្រហែលជា ការពិតដែរថា អ្នកខាងក្រៅមកសួរសំណួរ និងធ្វើការសន្យា ប៉ុន្តែមិនបានគោរពតាមការសន្យា។ នៅពេលដែលពួកគេបានធ្វើតាមការសន្យា ប្រជាពលរដ្ឋយល់ថា អ្នកខាងក្រៅទាំងនោះ ជារឿយៗមិនបានពន្យល់អំពីអ្វីដែលពួកគេកំពុងធ្វើទេ ជាពិសេសនៅថ្នាក់សហគមន៍។

### ក. កង្វះការទទួលបានព័ត៌មាន

"ពួកគេ (អ្នកភូមិ) មិនគ្រាន់តែមិនបានដឹងទេ ពួកគេថែមទាំងមិនបានសួរ និងគ្មាននរណាបាននិយាយប្រាប់ទៀតផង។ជួនកាល ពួកគេដឹង ជួនកាលក៏មិនដឹង។ពួកគេមានរឿងច្រើនពេកដែលត្រូវគិតគូរ។ពួកគេរៀនពីឪពុកម្តាយរបស់ពួកគេ ដែលថាពួកគេមិនត្រូវសួរសំណួរទេ។ វាគឺជាផ្នែកមួយនៃវប្បធម៌ខ្មែរ ប្រសិនបើអ្នកហ៊ានសួរដេញដោលច្រើន អ្នកគឺជាកូនអាក្រក់"។ *(បុគ្គលិកខ្មែរធ្វើការជាមួយអង្គការអន្តរជាតិមួយ នៅទីក្រុងភ្នំពេញ)*។

"ខ្ញុំមិនដឹងថា ហេតុអ្វីបានជាបានគេឱ្យធុងទឹកខ្ញុំ និងសំភារៈផ្សេងៗទេ។ ខ្ញុំមិនបានសុំធុងទឹកទេ។ ប៉ុន្តែយល់ថា ហេតុអ្វីបានជាគេកសាងអណ្តូងទឹក ដោយសារអ្នកភូមិមិនមានប្រភពទឹកស្អាតនៅជិតពួកគេ។ អណ្តូងផ្តល់ទឹកសម្រាប់ភូមិទាំងមូល"។ *(ស្រ្តីម្នាក់ អាយុជាង៦០ឆ្នាំ នៅខេត្តមណ្ឌលគីរី)*។

" អ្នកភូមិអង្គការអន្តរជាតិ និងម្ចាស់ជំនួយ ទាំងអស់គ្នាត្រូវដឹងថា តើមានថវិកាប៉ុន្មាន ដែលបានចំណាយនៅក្នុងភូមិ។ពួកគេយកគំរោងមកភូមិយើង ហើយយើងគួរតែដឹងថា តើតុល្យភាពស្ថិតនៅត្រង់ណា"។ *(សមាជិកក្រុមប្រឹក្សាឃុំ*

*នៅខេត្តមណ្ឌលគិរី)* ។

" ប្រជាពលរដ្ឋធ្លាប់បង្កើតក្រុម និងធ្វើសំណើរសុំឱ្យគេដោះមីន ប៉ុន្តែសំណើនោះត្រូវបានបដិសេធ ហើយយើងក៏មិនដឹងថា តើហេតុអ្វីបានជាពួកគេបដិសេធដែរ។ យើងមិនដឹងថា តើផែនការដោះមីនមានអ្វីខ្លះ ឬតើគេរៀបចំផែនការដូចម្តេចឡើយ។ ជួនកាល ប្រជាជនពលរដ្ឋប្រថុយជីវិតដោះមីនដោយខ្លួនឯង"។ *(បុរសបីនាក់ អាយុ៤០ឆ្នាំ នៅខេត្តពោធិសាត់)* ។

" អង្គការបានធ្វើការយ៉ាងច្រើន ប៉ុន្តែមានតែរដ្ឋាភិបាលប៉ុណ្ណោះ ដែលធ្វើបានល្អក្នុងការប្រកាសប្រាប់សាធារណជន អំពីអ្វីដែលពួកគេបានធ្វើ។ ប្រការនេះបានធ្វើឱ្យសហគមន៍មានជំនឿ និងការគោរពតិចតួចចំពោះអង្គការ។ ប្រសិនបើ អង្គការប្រកាសផ្សាយសកម្មភាពរបស់ខ្លួនឱ្យសាធារណជនបានដឹង ប្រជាពលរដ្ឋអាចដឹងថា តើត្រូវទៅរកនរណា ហើយអង្គការអាចផ្តល់សេវាបានប្រសើរជាង ដល់អ្នកដែលត្រូវការសេវាពិតប្រាកដ។ រហូតមកដល់ពេលនេះ មានតែអ្នកដែលអង្គការបានចូលទៅជួបប៉ុណ្ណោះ អាចទទួលបានការឧបត្ថម្ភ ប៉ុន្តែចំណែកអ្នកដែលត្រូវការជំនួយរបស់អង្គការ មិនដឹងថា តើត្រូវធ្វើដូចម្តេចដើម្បីចូលទៅរកជំនួយគាំទ្រពីអង្គការទាំងនោះឡើយ"។ *(ស្ត្រីម្នាក់អាយុជាង២០ឆ្នាំ ជាបុគ្គលិកអង្គការមួយ នៅទីក្រុងភ្នំពេញ)* ។

"វាជាការល្អ ប្រសិនបើពួកគេដឹង (អំពីជំនួយបរទេស)។ តើវាសំខាន់ឬទេ? ប្រហែលជាមិនសំខាន់ទេ"។ *(បុគ្គលិកខ្មែរ ធ្វើការជាមួយទីភ្នាក់ងារអង្គការសហប្រជាជាតិ នៅទីក្រុងភ្នំពេញ)* ។

**៩. កង្វះខាតនៃទំនាក់ទំនងតាមដានបន្ត**

អ្នកភូមិជាច្រើន បានសម្តែងដោយស៊ីសង្វាក់គ្នា នូវការខកចិត្តចំពោះអ្នកខាងក្រៅ ដែលបានចំណាយពេលរបស់ខ្លួនសួរសំណួរ និងធ្វើការសន្យា ដោយមិនដែលត្រឡប់មកជួបពួកគេវិញ ឬផ្តល់ជំនួយដែលបានសន្យាឡើយ។ ប្រការនេះបានរួមចំណែកដល់ការសន្និដ្ឋានថា ជំនួយត្រូវបានប្រើខុស ឬបង្វែរទិសដៅ ឬអ្នកខាងក្រៅគ្មានការទទួលខុសត្រូវ និងមុនគួរទុកចិត្តបាន។

"មានអង្គការជាច្រើន ដែលមកស្តាប់ពីយើង ប៉ុន្តែគ្មានអ្វីកើតឡើងសោះ។ យើងមានការសោកស្តាយចំពោះរឿងនេះ ពីព្រោះពួកគេគ្រាន់តែមកប្រមូលពតិមាន ហើយមិនផ្តល់អ្វីឱ្យប្រជាពលរដ្ឋបន្តិចសោះ។ ប្រជាពលរដ្ឋ ជឿជាក់លើអង្គការ ប៉ុន្តែគ្មានជំនួយពីពួកគេសោះ។ យើងដូចជាគ្មានជាទីពឹងទេ"។ *(បុរសម្នាក់អាយុ៧០ឆ្នាំ ជាសមាជិកក្រុមប្រឹក្សាភូមិ នៅខេត្តបាត់ដំបង)* ។

" អង្គការខ្លះ បានមកធ្វើការសន្យាជាច្រើន ហើយក្រោយមក មិនដែលឃើញត្រឡប់មកវិញសោះ។ ប្រសិនបើអ្នកសន្យា អ្នកធ្វើឱ្យប្រជាពលរដ្ឋមានសង្ឃឹម ហើយពួកគេមានការអាក់អន់ចិត្ត នៅពេលដែលគ្មានការពន្យល់ច្បាស់លាស់ និងគ្មានការតាមដានបន្ត"។ *(សមាជិកក្រុមប្រឹក្សាសហគមន៍ នៅខេត្តមណ្ឌលគិរី)* ។

" ខ្ញុំបានចុះហត្ថលេខា ដើម្បីចូលរៀនវគ្គកាត់ដេរកាលពីពីរឆ្នាំមុន ហើយគ្មានអ្នកណាម្នាក់បានឆ្លើយតបសោះ។

ខ្ញុំជឿថា វគ្គបណ្តុះបណ្តាលមិនបានរៀបចំឡើងទេ ប៉ុន្តែខ្ញុំមិនដឹងថា តើវាមានហេតុផលយ៉ាងម៉េចដែរ" ។ *(ក្រុមស្ត្រីបីនាក់ មានអាយុពី២៥ទៅ៤០ឆ្នាំ នៅខេត្តកំពត)* ។

" អង្គការខ្លះ បានមកនិយាយជាមួយយើង ប៉ុន្តែគ្មានអ្វីកើតឡើងសោះ ។ ប្រសិនម្ចាស់ជំនួយ បានចុះមកម្តងទៀត ដោយផ្ទាល់ ខ្ញុំនឹងនិយាយប្រាប់ពួកគេពីអ្វីមួយដែលខ្ញុំដឹង ប៉ុន្តែបើសិនជាម្ចាស់ជំនួយមកជាមួយអាជ្ញាធរ ខ្ញុំមិនហ៊ាន និយាយអ្វីប្រាប់ពួកគេទេ ខ្ញុំមិនចង់ធ្វើឱ្យអាជ្ញាធរខឹងសម្បារ" ។ *(ស្ត្រីម្នាក់នៅភូមិអណ្តែតទឹកក្នុងខេត្តពោធិសាត់)* ។

"ម្ចាស់ជំនួយគួរតែជួបពួកយើងដោយផ្ទាល់ ដើម្បីឱ្យយើងបានដឹងថា តើហេតុអ្វីបានជាពួកគេសន្យាថាជួយយើង ហើយ បែរជាមិនជួយទៅវិញ" ។ *(ប្តីប្រពន្ធវ័យក្មេង នៅភូមិអណ្តែតទឹក ក្នុងខេត្តពោធិសាត់)* ។

## ការឆ្លុះបញ្ចាំងរបស់ក្រុមអ្នកស្តាប់មតិយោបល់

សមាជិកក្រុមអ្នកស្តាប់មតិយោបល់ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដែលសមាជិកសហគមន៍ហាក់ដូចជាបានដឹង តិចតួចបំផុត អំពីជំនួយអន្តរជាតិដែលបានចូលទៅដល់ពួកគេ ។ ប្រជាពលរដ្ឋបានប្រាប់សមាជិកក្រុមអ្នកស្តាប់មតិ យោបល់ថា ពួកគេមិនដែលបានទទួលជំនួយទេ ខណៈដែលពួកគេអង្គុយនៅពីមុខធុងដាក់ទឹក ដែលមានផ្លាកសញ្ញាអង្គការ អន្តរជាតិ ឬខណៈដែលពិភាក្សា អំពីអណ្តូងទឹក ឬអគារ ដែលកសាងដោយអង្គការជំនួយខាងក្រៅ ។ សមាជិកក្រុមមួយ ចំនួនយល់ថា នេះគឺជាការប៉ុនប៉ងដើម្បីបានជំនួយបន្ថែមទៀត ដោយការអះអាងថាពួកគេមិនបានទទួលជំនួយអ្វីសោះ ចំណែកសមាជិកក្រុមមួយចំនួនទៀត បានលើកឡើងថា ប្រជាពលរដ្ឋមានការព្រួយបារម្ភថា ការនិយាយមិនត្រឹមត្រូវ អាចមានផលប៉ះពាល់អវិជ្ជមាន លើគំរោង និងមូលនិធិជំនួយ ។

សមាជិកក្រុម ក៏បានលើកឡើងផងដែរថា នៅពេលដែលប្រជាពលរដ្ឋទទួលបានជំនួយ គ្មាននរណាបានប្រាប់ ពួកគេថា វាជាជំនួយអន្តរជាតិទេ ។ ជារឿយៗ ប្រជាពលរដ្ឋបានឮតែពាក្យកាត់ថា "អង្គការ" ដោយគ្មានការពន្យល់ បកស្រាយបន្ថែមទៀតឡើយ ។ សមាជិកក្រុមផ្សេងទៀត បានធ្វើការកត់សម្គាល់ថា យើងមិនគួរបកស្រាយកត្តាដែល ប្រជាពលរដ្ឋ មិនបានចែករំលែកព័ត៌មានជាក់លាក់អំពីជំនួយ ជាការបង្ហាញថា ពួកគេមិនបានដឹងអំពីជំនួយទេ ។ សមាជិក ក្រុមមួយចំនួនទៀត បានលើកឡើងថា ប្រជាពលរដ្ឋពិតជាមិនមានបទពិសោធន៍ ក្នុងការឆ្លើយនូវសំណួរទាំងនេះ ប្រាកដ មែន និងមានអារម្មណ៍ខ្មាស់អៀន ដោយសារពួកគេខ្វះការអប់រំ ខ្លាចក្រែងពួកគេនិយាយអ្វីមួយមិនបានសមរម្យ និង ខុសឆ្គង ។

ភាពក្រីក្រ ក៏ជ្រៀតចូលក្នុងការពិភាក្សាផងដែរ ដោយប្រជាពលរដ្ឋភ័យខ្លាចមិនហ៊ានចូលរួមជាមួយអ្នកខាង ក្រៅ ពីព្រោះពួកគេជឿថា ជំនួយមានការលំអៀងទៅរកអ្នកមាន មិនលំអៀងទៅរកអ្នកក្រទេ ។ សមាជិកក្រុមជា ច្រើនបានរាយការណ៍ថា ប្រជាពលរដ្ឋជាច្រើនមានអារម្មណ៍ថា ពួកគេមិនអាចចូលរួមបាន ដោយសារពួកគេក្រីក្រពេក មិនអាចចូលរួមការប្រជុំ និងមិនអាចចូលរួមការងារអ្វីផ្សេងទៀតបាន ពីព្រោះពួកគេត្រូវតែធ្វើស្រែចំការចិញ្ចឹមគ្រួសារ និងពុំមានពេលវេលាចូលរួមការប្រជុំ ។ នៅទីបញ្ចប់ មានការយល់ឃើញក្នុងចំណោមសមាជិកក្រុមអ្នកស្តាប់មតិយោបល់

មួយចំនួនថា ប្រជាពលរដ្ឋនៅតែត្រូវបានទុកឱ្យស្ថិតនៅក្នុងភាពងងឹត តាមរយៈការផ្តល់ព័ត៌មានមិនត្រឹមត្រូវ ហើយព័ត៌មានត្រូវបានលាក់ដោយចេតនាមិនឱ្យពួកគេដឹង ដើម្បីកាត់បន្ថយការទទួលខុសត្រូវ (គណនេយ្យភាព) ពីព្រោះសាធារណជនដែលមានការអប់រំតិចតួច នឹងមិនបានដឹងឡើយ នៅពេលណាដែលមូលនិធិជំនួយមិនបានមកដល់ ឬនៅពេលដែលគោលដៅមិនទាន់ត្រូវបានសំរេច ។

## V. តម្រូវការសម្រាប់តម្លាភាព និងការត្រួតពិនិត្យថែមទៀត

នៅក្នុងខេត្តនីមួយៗ និងនៅក្នុងការសន្ទនាភាគច្រើន ប្រជាពលរដ្ឋបានរកឃើញមធ្យោបាយប្រាស្រ័យទាក់ទងដោយផ្ទាល់ និងជាប្រយោលថា ជំនួយមិនបានធ្លាក់ដល់ដៃអ្នកទទួលតាមការគ្រោងទុកឡើយ ។ ជាទូទៅ ប្រជាពលរដ្ឋ បានប្រាប់សមាជិកក្រុមអ្នកស្តាប់ថា ពួកគេមិនបានដឹងថា តើជំនួយដែលបាត់នោះ ទៅទីណា ឬហេតុអ្វីទេ ។ ប្រជាពលរដ្ឋ បាននិយាយថា ការទទួលខុសត្រូវចំពោះបញ្ហានេះ គឺជាបន្ទុករបស់អ្នកដើរតួមួយចំនួន ដែលរួមមាន រដ្ឋាភិបាល អង្គការផ្តល់ជំនួយបរទេស សមាជិកក្រុមប្រឹក្សាឃុំ ឬប្រធានភូមិ ។

នៅថ្នាក់ភូមិ មានទាំងកំហឹង និងការទទួលស្គាល់ថា អំពើពុករលួយ គឺជារបៀបអនុវត្តន៍នៅក្នុងសង្គម ចំណែកនៅទីក្រុងភ្នំពេញ អ្នកធ្វើការងារជំនួយ និងអ្នកវិភាគដែលមានបទពិសោធន៍ច្រើន បានពិភាក្សាអំពីមូលហេតុ និងដំណោះស្រាយ សម្រាប់អំពើពុករលួយ ។ ប្រជាពលរដ្ឋបាននិយាយអំពីឧទាហរណ៍ផ្សេងៗអំពីការគ្រប់គ្រងមូលនិធិមិនបានត្រឹមត្រូវ ដែលរួមមានការបង្វែរជំនួយសម្ភារៈ ឬជំនួយលើការកសាងសមត្ថភាព ទៅឱ្យមិត្តភ័ក្ត និងគ្រួសារ ឬរបៀបដែលជំនួយត្រូវបានប្រើប្រាស់សម្រាប់ការគាំទ្រនយោបាយ ឬការគាំទ្រផ្នែកសង្គម ។ ប្រជាពលរដ្ឋ បានផ្តល់យោបល់ជាច្រើនអំពីថា តើជំនួយគួរតែត្រូវបានចែកចាយដូចម្តេច និងជាពិសេសតាមរយៈស្ថាប័នណាមួយនោះ អាចជា រដ្ឋាភិបាល អង្គការអន្តរជាតិ អង្គការជាតិ ក្រុមប្រឹក្សាឃុំ ឬដល់ប្រជាពលរដ្ឋផ្ទាល់តែម្តង។ មានការព្រមព្រៀងថា ជំនួយបរទេសនឹងមានប្រសិទ្ធភាពច្រើន ប្រសិនបើកាត់បន្ថយអំពើពុករលួយបាន ។

ទោះបីជាប្រជាពលរដ្ឋបានបញ្ចេញកំហឹងចំពោះអំពើពុករលួយក៏ដោយ ក៏ប្រជាពលរដ្ឋភាគច្រើនយល់ថា ពួកគេគ្មានអំណាចក្នុងការផ្លាស់ប្តូរ អ្វីដែលពួកគេយល់ថាជារបៀបរបបសង្គមឡើយ ។ ប្រជាពលរដ្ឋមួយចំនួនយល់ថា ពួកគេមិនដឹងថា តើត្រូវតវ៉ាដូចម្តេចទេ ចំណែកប្រជាពលរដ្ឋមួយចំនួនទៀតយល់ថា ប្រព័ន្ធដែលគាំទ្រអំពើពុករលួយមានអំណាចខ្លាំងពេក គេមិនអាចតវ៉ាជំទាស់ និងផ្លាស់ប្តូរបានទេ។ ប្រជាពលរដ្ឋក៏យល់ដឹងផងដែរថា អ្នកដែលប្រព្រឹត្តិអំពើពុករលួយមានអភ័យឯកសិទ្ធិ។ ស្ត្រីម្នាក់នៅក្នុងខេត្តកំពតបាននិយាយថា "គេត្រូវតែគោរពសេចក្តីសម្រេចចិត្ត (ដែលអយុត្តិធមិ) ទាំងនេះ ។ ខ្ញុំគ្មានជម្រើសចំពោះបញ្ហានេះទេ តែខ្ញុំត្រូវតែគោរពសេចក្តីសម្រេចចិត្តទាំងនេះ ពីព្រោះអ្នកធ្វើការសម្រេចចិត្តដូចជាឪពុកម្តាយខ្ញុំដែរ ។ ទោះបីជាដូច្នោះក៏ដោយ ខ្ញុំនៅតែខឹងដដែល តែខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាងណានោះទេ" ។

មានការអំពាវនាវយ៉ាងទទូចសុំឱ្យម្ចាស់ជំនួយ ចុះតាមដាន និងត្រួតពិនិត្យឱ្យបានល្អ និងញឹកញាប់។ ដោយពួកគេគ្មានអំណាចនិយាយប្រឆាំង ឬបញ្ឈប់អំពើពុករលួយ ប្រជាពលរដ្ឋបានផ្តល់អនុសាសន៍ឱ្យអ្នកខាងក្រៅដើរតួនាទី និងទទួលខុសត្រូវលើបញ្ហានេះជំនួសពួកគេ។

## ក. សភាពនៃអំពើពុករលួយ

"បន្ទាប់ពីបានព្យាយាមកាត់បន្ថយភាពក្រីក្រតាមរយៈជំនួយបរទេស អស់រយៈពេល១៣ឆ្នាំមក ភាពក្រីក្រត្រូវបានកាត់បន្ថយ ប៉ុន្តែអំពើពុករលួយដែលបានក្លាយជាស្ថាប័ន បានធ្វើឱ្យអ្នកមានកាន់តែមានឡើង និងអ្នកក្រកាន់តែក្រទៅ"។ *(បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលជាតិ នៅភ្នំពេញ)* ។

"នៅកម្ពុជា មានការរីកចម្រើនតិចតួចណាស់ ពីព្រោះជំនួយបរទេសត្រូវបានប្រើប្រាស់ដោយមិនត្រឹមត្រូវ ដោយគ្រប់គ្នាសុទ្ធតែពុករលួយ។ មិនមែនស្ថាប័នពុករលួយទេ តែបុគ្គលិកស្ថាប័នទាំងនោះទេ ដែលពុករលួយ"។ *(ស្ត្រីអ្នកជំនួញពីរនាក់ ដែលស្ថិតក្នុងវ័យ២០ ឆ្នាំ នៅភ្នំពេញ)* ។

" ការប្រជុំមួយដែលម្ចាស់ជំនួយរៀបចំឡើង ផ្តល់ប្រាក់ពួកគេ ២០០០រៀលឱ្យចូលរួម។ ម្ចាស់ជំនួយបាន និយាយថាពួកគេមានទឹកប្រាក់ចំនួន១០០ ០០០ដុល្លារ សម្រាប់កិច្ចការផ្នែកជីវភាពរស់នៅ ហើយពួកគេនឹងផ្តល់ប្រាក់កម្ចី សម្រាប់ការចិញ្ចឹមមាន់ និងជ្រូក និងឧបករណ៍នេសាទស្របច្បាប់ថ្មី ប៉ុន្តែពួកគេមិនបានទទួលអ្វីសោះ។ ខ្ញុំមិនដឹងថា មានអ្វីកើតឡើងទេ។ លុយនោះមិនដែលបានធ្លាក់ដល់ដៃប្រជាពលរដ្ឋសោះ"។ *(ខេត្តពោធិ៍សាត់ ស្ត្រីម្នាក់អាយុ៥៥ឆ្នាំ រស់នៅក្នុងភូមិបណ្តែតទឹក)* ។

មនុស្សមួយក្រុមដែលគ្រប់គ្រងមណ្ឌលកុមារកំព្រាមួយកន្លែងនៅក្នុងខេត្តមណ្ឌលគីរី បានសារភាពថា ប្រសិនបើពួកគេបានទទួលលុយច្រើនលើសលប់យកមកកសាងមណ្ឌលកុមារកំព្រា (ដោយអ្នកខាងក្រៅ) ពួកគេប្រហែលជាចំណាយតិចតួចកសាងអគារឱ្យបានសមរម្យជាងនេះ និងទុកលុយ "ដែលនៅសល់"។ "យើងទុកលុយនេះដាក់ក្នុងហោប៉ៅ។ វាជាអត្ថប្រយោជន៍ ជាកំរៃសម្រាប់យើង"។

"អំពើពុករលួយធ្វើឱ្យកម្ពុជាបាត់បង់ទឹកប្រាក់ប្រមាណ៥០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ យោងតាមការអង្កេតរបស់ធនាគារពិភពលោក"។ *(ភ្នំពេញ សមាជិកសភា)* ។

"ចាប់តាំងពីឆ្នាំ១៩៩៣មក កម្ពុជាបានទទួលជំនួយជាទឹកប្រាក់ចំនួន៦ពាន់លានដុល្លារ ប៉ុន្តែអ្នកក្រនៅតែក្រីក្រជាបន្ត។ ប្រជាជន៣៤-៣៥% រស់នៅក្រោមបន្ទាត់ក្រីក្រ ដែលរកបានចំណូល២០០០រៀលក្នុងមួយថ្ងៃ ដោយសារអំពើ

ពុករលួយ និងសិទ្ធិលើកម្មសិទ្ធិដីធ្លី" ។ *(ភ្នំពេញ សមាជិកាសភា)* ។

"អំពើពុករលួយមានការរីករាលដាលយ៉ាងខ្លាំង។ ថ្នាក់ដឹកនាំ មិនបានទទួលរងផលប៉ះពាល់ទេ។ សហគមន៍អន្តរជាតិ ជំរុញឱ្យមានគណនេយ្យភាព ប៉ុន្តែពុំបានទទួលជោគជ័យច្រើនទេ.....។ បួនភាគប្រាំនៃថវិកាសាធារណៈដែលបានទម្លាក់ទៅថ្នាក់ភូមិ ត្រូវបានបញ្ជូនទៅក្នុងបំណងល្អ និងពួកគេគួរតែដឹងរឿងនេះ។ ប៉ុន្តែបញ្ហាបក្សពួក និងនយោបាយចូលជ្រៀតជ្រែកការងារនេះ" ។ *(ភ្នំពេញ បុគ្គលិកខ្មែរធ្វើការជាមួយអង្គការអន្តរជាតិមួយ)* ។

"អង្គការមិនមែនរដ្ឋាភិបាល សូកសំណូករហូតដល់២០% ដើម្បីទទួលបានថវិកាពីរដ្ឋាភិបាល។ នៅពេលដែលគេពិនិត្យមើល អ្វីៗត្រូវបានរៀបចំយ៉ាងល្អដើម្បីកុំឱ្យគេមើលឃើញថាមានបញ្ហាមិនប្រក្រតី ចំណែកទីប្រឹក្សាបច្ចេកទេសតែងតែនិយាយថា គ្រប់យ៉ាងបានល្អហើយ។ ទីប្រឹក្សាបច្ចេកទេស ក៏ដូចគ្នាដែរ (ពុករលួយ)។ អ្នកទទួលបន្ទុកពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុនឹងមិនអនុម័តដោយគ្មានសំណូកឡើយ" ។ *(ប្រធានអង្គការមិនមែនរដ្ឋាភិបាលជាតិម្នាក់ ស្ថិតក្នុងវ័យ៣០ឆ្នាំ)* ។

"ជំនួយបរទេសប៉ែតសិបភាគរយគួរបានធ្លាក់ដល់ដៃប្រជាពលរដ្ឋ តែផ្ទុយទៅវិញ វាធ្លាក់ទៅលើដៃរដ្ឋាភិបាល.....។ ត្រូវតែមាន "តុល្យភាព" ដើម្បីសម្រេចបានការរីកចម្រើន ដែលអ្នកផ្តល់ជំនួយបរទេសគួរជួយជំរុញបន្តិចតែកុំលឿនពេក.....។ ត្រូវចេះបត់បែន។ ត្រូវធ្វើអ្វីដែលអ្នកអាចធ្វើបាន" ។ *(បុគ្គលិកខ្មែរធ្វើការជាមួយអង្គការអន្តរជាតិមួយ)* ។

## ៩. មូលហេតុនៃអំពើពុករលួយ

ខ្សែស្រឡាយនិយម និងនយោបាយនីយកម្មលើជំនួយ ត្រូវបានមើលឃើញថា ជាការជួយសម្រួលដល់អំពើពុករលួយ។ ការរួញរារបស់ប្រជាពលរដ្ឋ ឬជាញឹកញាប់ភាពអវិជ្ជា ក្នុងការប្រយុទ្ធនឹងការបំពានអំណាចទាំងនេះ ក៏ត្រូវបានមើលឃើញថា ជាកត្តារួមចំណែកចំពោះវប្បធម៌ពុករលួយផងដែរ។

"ក្រុមការងារអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ មានអត្ថបទមួយចំនួនដើម្បីដោះស្រាយបញ្ហា អំពើពុករលួយ ប៉ុន្តែតុលាការមិនឯករាជ្យ ដោយពួកគេត្រូវស្ថិតនៅក្រោមឥទ្ធិពលអ្នកនយោបាយ និងក្រុមវរជន។ គ្មានការកាត់ក្តីដោយយុត្តិធម៌ទេ! មានអភ័យឯកសិទ្ធិ.....។ សន្តិភាព និងស្ថិរភាព ត្រូវតែផ្អែកលើយុត្តិធម៌ ប៉ុន្តែនៅកម្ពុជា គ្មានយុត្តិធម៌ទេ.....។ រដ្ឋាភិបាលមានធនធានមានកម្រិត ដើម្បីជួយប្រជាពលរដ្ឋក្រីក្រ។ ប្រាក់ខែរបស់គ្រូបង្រៀន និងបុគ្គលិកមន្ទីរពេទ្យមិនស៊ីសង្វាក់គ្នាទៅនឹងតថភាពឡើយ។ ដូច្នេះ ពួកគេត្រូវតែប្រព្រឹត្តិអំពើពុករលួយ" ។ *(ភ្នំពេញ សមាជិក*

*សភា)* ។

"ខ្ញុំចង់ឱ្យរដ្ឋាភិបាលចុះមកមើលខ្លួនឯង។ នៅពេលដែលអំណោយមកដល់ ប្រធានឃុំ ឬប្រធានភូមិ គឺជាអ្នកទទួលខុសត្រូវចំពោះការចែកអំណោយជូនប្រជាពលរដ្ឋក្រីក្រ តែពួកគេជ្រើសរើសយកតែឈ្មោះមិត្តភ័ក្ត និងបងប្អូនរបស់ខ្លួនប៉ុណ្ណោះ"។ *(ស្ត្រីកសិករ នៅខេត្តកំពត)* ។

"គ្មាននរណាម្នាក់បានចូលរួមនៅក្នុងការប្រជុំសហគមន៍ទេ ដូច្នេះអ្នកដែលមិនបានចូលរួម មានការខឹងសម្បារ ប្រធានគណៈកម្មការ គិតគូរពីបងប្អូនរបស់គេតែប៉ុណ្ណោះ មិនគិតគូរពីប្រជាជនឡើយ"។ *(ស្ត្រីម្នាក់ អាយុ៣០ឆ្នាំ រស់នៅក្នុងភូមិអណ្តែតទឹក ខេត្តពោធិ៍សាត់ )* ។

"ប្រសិនបើអ្នកជាសមាជិកគណបក្សប្រឆាំង អ្នកច្បាស់ជាមិនបានជំនួយដើម្បីអភិវឌ្ឍន៍តំបន់របស់ខ្លួនទេ។ ហើយគណបក្សកាន់អំណាច នឹងចោទគណបក្សផ្សេងថា មិនបានជួយប្រជាជន។ ជំនួយត្រូវបានគេប្រើប្រាស់ដើម្បីផលប្រយោជន៍នយោបាយ និងបង្ខូចប្រយោជន៍របស់គណបក្សផ្សេងទៀត។ ជំនួយបរទេសត្រូវបានប្រើប្រាស់ ដើម្បីបង្ហាញថាគណបក្សកាន់អំណាចមានចិត្តសប្បុរសធម៌"។ *(បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលជាតិ ខេត្តបាត់ដំបង )* ។

"គេងាយស្រួលបោកប្រាស់អង្គការមិនមែនរដ្ឋាភិបាលបរទេសណាស់"។ *(ប្រធានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកម្នាក់ អាយុ៣០ឆ្នាំ)* ។

## គ. ការពង្រឹងការត្រួតពិនិត្យ និងទប់ស្កាត់អំពើពុករលួយ

មតិអំពីថា តើជំនួយគួរតែចែងចែកនៅទីណា និងដូចម្តេច ជារឿយៗត្រូវបានលើកឡើងជាសំណូមពរសម្រាប់ការទប់ស្កាត់អំពើពុករលួយ។ ប្រជាពលរដ្ឋជាច្រើនដែលយើងបានស្តាប់ ចង់ឱ្យជំនួយធ្លាក់ដល់ដៃប្រជាពលរដ្ឋ "ដោយផ្ទាល់" ហើយបើសិនជាអាចធ្វើបាន ឱ្យរំលងរដ្ឋាភិបាល។ ការអប់រំប្រជាពលរដ្ឋ ត្រូវបានមើលឃើញថាជាមធ្យោបាយដ៏សំខាន់ក្នុងការផ្លាស់ប្តូរចលនាសង្គម ដែលបណ្តោយឱ្យមានអំពើពុករលួយ និងឱ្យប្រជាពលរដ្ឋមានការទទួលខុសត្រូវ។ ប្រជាពលរដ្ឋមានជំនឿថា សាធារណជនដែលមានការអប់រំ អាចប្តឹង និងក្រោកឈរទាមទារសិទ្ធិរបស់ខ្លួនបានល្អប្រសើរ។

ទោះបីជាមានការអំពាវនាវម្តងហើយម្តងទៀត ពីប្រជាពលរដ្ឋនៅតំបន់ទីក្រុង សុំឱ្យមានច្បាប់ដើម្បីទប់ស្កាត់ និងផ្តន្ទាទោសអំពើពុករលួយក៏ដោយ ក៏មានយល់ដឹងតិចតួចថា ច្បាប់នេះនឹងអាចសម្រេចបានក្នុងពេលដ៏ខ្លីខាងមុខដែរ។ យោបល់ទូទៅបំផុតក្នុងការទប់ស្កាត់អំពើពុករលួយ គឺសុំឱ្យម្ចាស់ជំនួយដើរតួនាទីដ៏សកម្ម ដោយការចុះទៅជួប "ប្រជាពលរដ្ឋដោយផ្ទាល់" តាមដានជំនួយដែលពួកគេបានផ្តល់ឱ្យ និងដោយការដាក់សម្ពាធឱ្យរដ្ឋាភិបាលចាត់វិធានការដើម្បីបញ្ឈប់អំពើពុករលួយ។

"ប្រសិនបើអ្នកចង់ជួយយើង សូមជួយដោយផ្ទាល់។ ផ្តល់ជំនួយតាមរយៈយើងផ្ទាល់ ហើយកុំឱ្យតាមរយៈអ្នកណាផ្សេង អាជ្ញាធរមូលដ្ឋាន ឬអ្នកផ្សេងទៀត"។ *(ខេត្តកំពត ការពិភាក្សាជាក្រុម)* ។

"អង្គការល្អជាងអាជ្ញាធរមូលដ្ឋាន ពីព្រោះការឧបត្ថម្ភតាមរយៈអង្គការ ធ្លាក់ដល់ប្រជាពលរដ្ឋលឿនណាស់"។ *(ប្តីប្រពន្ធវ័យក្មេងរស់នៅក្នុងភូមិនេសាទមួយ នៅក្នុងខេត្តពោធិ៍សាត់)* ។

"មូលនិធិ គួរតែផ្តល់ឱ្យអង្គការមិនមែនរដ្ឋាភិបាល ឱ្យច្រើនជាងរដ្ឋាភិបាល ពីព្រោះអាចជួយបង្កើនឥទ្ធិពលជាវិជ្ជមាននៃការងារទាំងអស់នេះ។ រដ្ឋាភិបាលមិនអាចបំពេញតម្រូវការទាំងអស់បានទេ។ លើសពីនេះទៀត ជួនកាលពួកគេធ្វើផែនការសម្រាប់វគ្គបណ្តុះបណ្តាលចំនួន១០ តែធ្វើបានតែ១វគ្គប៉ុណ្ណោះ"។ *(បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អាយុ៣០ឆ្នាំ នៅក្នុងខេត្តមណ្ឌលគិរី)* ។

"យើងត្រូវតែអប់រំសហគមន៍ និងពន្យល់ពួកគេពីមូលហេតុដែលធ្វើឱ្យពួកគេក្រីក្រ ពីមូលហេតុដែលគ្មានការអប់រំដោយឥតគិតថ្លៃ ពីមូលហេតុដែលធ្វើឱ្យទំនិញ និងសេវាសព្វសារពើឡើងថ្លៃ។ នៅពេលដែលពួកគេដឹង ពួកគេយល់ ពួកគេនឹងគិតអំពីបញ្ហានេះកាន់តែខ្លាំងឡើង.....។ គំរោងដែលត្រួតពិនិត្យដោយម្ចាស់ជំនួយខ្លួនឯង ទំនងដូចជាមានប្រសិទ្ធភាពច្រើន។ គំរោងដែលត្រួតពិនិត្យដោយរដ្ឋាភិបាល មានប្រសិទ្ធភាពតិចតួចដោយសារមានអំពើពុករលួយច្រើន។ ម្ចាស់ជំនួយត្រូវតែដាក់ល័ក្ខខ័ណ្ឌលើជំនួយ ដើម្បីឱ្យរដ្ឋាភិបាលអនុម័តច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ.....។ កាត់បន្ថយអំពើពុករលួយនៅថ្នាក់ជាតិ ដោយការធ្វើការដោយផ្ទាល់ជាមួយថ្នាក់ឃុំ។ គ្មាននរណាម្នាក់ធ្វើការបានល្អជាងពួកគេ (ថ្នាក់ឃុំ) ទេ.....។ ត្រូវធានាថា ការបោះឆ្នោតប្រព្រឹត្តិទៅដោយសេរី និងយុត្តិធម៌។ ចាប់ផ្តើមត្រួតពិនិត្យតាមដានលើសកម្មភាពនៃការបោះឆ្នោត រាប់បញ្ចូលទាំងការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោត។ ត្រូវជួយបង្កើតបរិយាកាសស្និទ្ធស្នាល។ ម្ចាស់ជំនួយគួរតែស្វែងយល់អំពីបញ្ហាទាំងនេះឱ្យបានលំអិតថែមទៀត"។ *(សមាជិកសភា ទីក្រុងភ្នំពេញ)* ។

"គ្មានថ្នាក់ដឹកនាំទេ ប៉ុន្តែអំណាច.....។ អំពើពុករលួយដែលបានក្លាយទៅជាស្ថាប័ន គឺជាបញ្ហាដ៏ធំ និងជាក់ស្តែងបំផុត ដោយយើងអាចមើលឃើញរថយន្តទំនើបៗជាច្រើនពាសពេញទីក្រុង.....។ ការអប់រំដែលមានគុណភាព អាចផ្លាស់ប្តូរសង្គមបាន។ ការកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាល នឹងផ្តល់ឱកាសឱ្យពួកគេបំពេញការងាររបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព"។ *(ចៅកែភោជនីយដ្ឋានមួយកន្លែង នៅទីក្រុងភ្នំពេញ)* ។

"អង្គការផ្តល់ជំនួយបរទេស មិនមានជំនឿលើរដ្ឋាភិបាល ក្នុងការគ្រប់គ្រងមូលនិធិប្រកបដោយតម្លាភាពទេ ប៉ុន្តែពួកគេមិនបង្រៀនយើងពីរបៀបគ្រប់គ្រងវាឱ្យបានត្រឹមត្រូវ។ ការផ្តល់ការបណ្តុះបណ្តាល គឺជាការសំខាន់បំផុត ដើម្បីឱ្យការងារមាននិរន្តរភាព នៅពេលដែលអង្គការខាងក្រៅ ចាកចេញទៅ"។ *(មន្ត្រីរដ្ឋាភិបាលមូលដ្ឋាន ខេត្តពោធិ៍សាត់)* ។

"ប្រទេសនេះ ត្រូវបានត្រួតត្រាដោយមនុស្សមួយក្ដាប់តូចប៉ុណ្ណោះ មិនមែនដោយនីតិរដ្ឋទេ។ គ្មានគំរូសម្រាប់គណនេយ្យភាពទេ។ ចៅក្រមត្រូវបានតែងតាំង ហើយបណ្ដេញចោល.....។ អ្នកយកលុយមកទម្លាក់ចោលនៅទីនេះ ហើយប្រជាជនកម្ពុជារើសយកលុយហ្នឹង ដូច្នេះអ្នកគួរតែតាមដានវា.....។ បើសិនជាម្ចាស់ជំនួយមានភាពក្លាហាន រដ្ឋាភិបាលអាចរៀនចេះទទួលខុសត្រូវបាន។ ទោះបីជាអ្នកផ្ដល់ជំនួយឱ្យយើងដប់ដងទៀតក៏ដោយ ក៏ខ្ញុំមិនយកដែរ បើសិនជាម្ចាស់ជំនួយមិនដាក់ល័ក្ខខ័ណ្ឌណាមួយទេនោះ។ គោលជំហរដែលគ្មានល័ក្ខខ័ណ្ឌនេះ នឹងបំផ្លិចបំផ្លាញប្រទេសកម្ពុជា"។ *(សមាជិកាសភា ទីក្រុងភ្នំពេញ)* ។

"ដើម្បីកែលំអប្រសិទ្ធិភាពជំនួយ ម្ចាស់ជំនួយគួរតែតាមដានឱ្យបានតឹងរឹង និងបង្ហាញអំពីការរំពឹងទុកច្បាស់លាស់ ហើយដាក់ទណ្ឌកម្មលើរដ្ឋាភិបាល ប្រសិនបើពួកគេប្រព្រឹត្តិខុស"។ *(បុរសអាយុ៥០ឆ្នាំម្នាក់ ជាបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលជាតិ នៅភ្នំពេញ)* ។

"ដើម្បីកែលំអជំនួយឱ្យបានល្អប្រសើរនៅពេលអនាគត ម្ចាស់ជំនួយគួរតែដាក់សម្ពាធឱ្យរដ្ឋាភិបាលកែលំអការអនុវត្តច្បាប់របស់ប្រទេស និងអប់រំសហគមន៍ឱ្យបានយល់ដឹងអំពីសិទ្ធិ ច្បាប់ និងឱ្យសហគមន៍ចូលរួមក្នុងដំណើរការនេះ"។ *(ព្រះភិក្ខុសង្ឃព្រះជន្ម៣០ វស្សា នៅខេត្តមណ្ឌលគីរី)* ។

"នៅក្នុងប្រទេសនេះ គ្មានឆន្ទៈនយោបាយក្នុងការដោះស្រាយបញ្ហាអំពើពុករលួយទេ។ ខ្ញុំមិនដែលឃើញប្រទេសណាមួយ ដែលច្បាប់អំពើពុករលួយ មិនត្រូវបានអនុម័តអស់រយៈពេល១០ឆ្នាំ មកហើយទេ។ ម្ចាស់ជំនួយត្រូវតែដាក់ល័ក្ខខ័ណ្ឌលើជំនួយ ដើម្បីឱ្យរដ្ឋាភិបាលអនុម័តច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ។ នៅពេលដែលម្ចាស់ជំនួយយកលេសថា "វាជារឿងនយោបាយ" ពួកគេបាត់បង់តម្លៃចំពោះភាពជាដៃគូ.....។ ម្ចាស់ជំនួយខ្លាចពេកមិនហ៊ានប្រកាន់ជំហរតឹងរឹង។ រដ្ឋាភិបាលដឹងថា ម្ចាស់ជំនួយនឹងមិនដកចេញទេ.....។ ម្ចាស់ជំនួយគួរតែសាកសួររដ្ឋាភិបាលអំពីជំនួយដែលពួកគេបានទទួល ដើម្បីកែលំអគុណភាពជីវិត និងការពារសិទ្ធិមនុស្ស..... (ប៉ុន្តែ) ម្ចាស់ជំនួយគឺជាអ្នកពឹងផ្អែកលើរដ្ឋាភិបាលទៅវិញ (មិនមែនរដ្ឋាភិបាលពឹងផ្អែកលើម្ចាស់ជំនួយទេ)។ ម្ចាស់ជំនួយមានការទទួលខុសត្រូវ។ ពួកគេផ្ដល់ជំនួយឱ្យរដ្ឋាភិបាលចំនួន៥០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ តើបានផលប្រយោជន៍អ្វីខ្លះ? សុំឱ្យម្ចាស់ជំនួយវាស់វែងភាពជោគជ័យ តើមានសូចនាករអ្វីខ្លះ? តើមានការវាយតម្លៃគុណភាពដូចម្ដេច? តើគុណភាពជីវិតត្រូវបានប៉ះពាល់ដូចម្ដេច? *(ភ្នំពេញ សមាជិកាសភា)* ។

## ***ការឆ្លុះបញ្ចាំងរបស់សមាជិកក្រុមអ្នកស្ដាប់មតិយោបល់***

មានការយល់ដឹងជាទូទៅថា អ្នកដើរតួទាំងអស់នៅក្នុងប្រព័ន្ធជំនួយ កំពុងរួមចំណែកតាមមធ្យោបាយផ្សេងៗដល់

ការអនុវត្ត ដែលធ្វើឱ្យមានអំពើពុករលួយកាន់តែច្រើនឡើង។ សមាជិកក្រុមអ្នកស្តាប់មតិយោបល់ម្នាក់បានកត់សម្គាល់ថា: "សូម្បីតែបើកអង្គការមួយ និងចុះបញ្ជីជាផ្លូវការ ក៏អ្នកត្រូវតែបង់ប្រាក់សំណូកដែរ ហើយអ្នកប្រើលុយជំនួយបរទេសដើម្បីសូកពួកគេ។ តើម្ចាស់ជំនួយបានដឹងអំពីបញ្ហានេះឬទេ? អត់ទេ ពីព្រោះពួកគេគ្មានប្រព័ន្ធតាមដាន"។

សមាជិកក្រុមអ្នកស្តាប់មតិយោបល់ បានឆ្លុះបញ្ចាំងលើសំណើរបស់តំណាងរដ្ឋាភិបាលថ្នាក់ខេត្តមួយរូប ដែលស្នើសុំឱ្យមានការបណ្តុះបណ្តាលថែមទៀត អំពីវិធីធ្វើយ៉ាងណាដើម្បីឱ្យកាន់តែមានតម្លាភាព និងវិធីធ្វើយ៉ាងណាដើម្បីបំពេញការងារឱ្យបានត្រឹមត្រូវ។ ពួកគេបានលើកឡើងថា ជំនួយអន្តរជាតិដែលផ្តោតលើការកែលំអអភិបាលកិច្ច និងកាត់បន្ថយអំពើពុករលួយ ត្រូវបញ្ចូលការងារដែលត្រូវធ្វើថែមទៀតជាមួយមន្ត្រីរដ្ឋាភិបាលថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ជាពិសេសនៅក្នុងតំបន់ដាច់ស្រយាលមួយចំនួន នៅទូទាំងប្រទេស"។

មានការអំពាវនាវដ៏ទទូច សុំឱ្យម្ចាស់ជំនួយដើរតួនាទីឱ្យកាន់តែសកម្ម ក្នុងការដោះស្រាយបញ្ហាអំពើពុករលួយតាមរយៈល័ក្ខខ័ណ្ឌតឹងរឹងជាងមុនលើជំនួយ ការកែលំអការតាមដាន និងឆន្ទៈក្នុងការនិយាយដោយចំហអំពីអំពើពុករលួយ។ សមាជិកក្រុមអ្នកស្តាប់មតិយោបល់ម្នាក់ បាននិយាយបន្ថែមលើយោបល់ដែលគេបានឮនៅក្នុងសហគមន៍ថា "ម្ចាស់ជំនួយត្រូវតែចង់បានការងារដែលមានគុណភាពល្អ ផ្លូវដែលគង់វង្សបានយូរ។ ប៉ុន្តែអ្វីដែលម្ចាស់ជំនួយមើលឃើញ គឺផ្លូវបានកសាងឡើង មិនមែនមើលឃើញថា វាជាផ្លូវមិនល្អទេ។ ដូច្នេះបន្ទាប់ពីប្រើបានប្រាំឆ្នាំ ផ្លូវនោះក៏ខូចអស់។ ជនបរទេសគួរតែត្រួតពិនិត្យពីបញ្ហានេះ តាមរយៈការឃ្លាំមើលបន្ថែម និងការត្រួតពិនិត្យប្រកបដោយគុណភាព។ ម្ចាស់ជំនួយគួរតែចុះមកមើលឱ្យបានញឹកញាប់ ដើម្បីទប់ស្កាត់អំពើពុករលួយ"។

សមាជិកក្រុមអ្នកស្តាប់មតិយោបល់មួយចំនួន មើលឃើញថា សំណើស្របគ្នាដែលសុំឱ្យម្ចាស់ជំនួយចុះពិនិត្យគំរោងនៅមូលដ្ឋានឱ្យបានច្រើន គឺជាមធ្យោបាយមួយដើម្បីទប់ស្កាត់អំពើពុករលួយ ដោយមិនធ្វើឱ្យជំពាក់វាក់វិនដល់អ្នកភូមិ។ នៅពេលដែលម្ចាស់ជំនួយកោះហៅប្រជុំ ប្រជាជនត្រូវតែមកចូលរួម ហើយបើសិនជាពួកគេនិយាយជាមួយអ្នកទទួលជំនួយដោយយកចិត្តទុកដាក់ ពួកគេអាចរកឃើញការពិត ដោយមិនធ្វើឱ្យអ្នកភូមិមើលឃើញថា ពួកគេមានកំហុស ដោយសារការជំរុញឱ្យមានតម្លាភាពឡើយ។ សមាជិកក្រុមអ្នកស្តាប់មតិយោបល់មួយចំនួនបានលើកឡើងថា ម្ចាស់ជំនួយគួរតែកោះហៅគណបក្សប្រឆាំងទាំងអស់ ឱ្យជួបជាមួយគណបក្សកាន់អំណាចនៅពេលផ្តល់ជំនួយ ហើយតម្លៃនៃកិច្ចប្រឹងប្រែងផ្តល់ជំនួយ នឹងផ្តល់អោយយ៉ាងជាក់ច្បាស់ទៅអោយម្ចាស់ជំនួយវិញ។

ជាចុងក្រោយ ដូចដែលពួកគេបានកត់សម្គាល់នៅក្នុងការពិភាក្សាអំពីតម្លៃនៃការអប់រំ សមាជិកក្រុមការងារគំរោងស្តាប់មតិយោបល់ បានកត់សម្គាល់ម្តងទៀតថា ការផ្តល់ព័ត៌មានដល់ប្រជាជន ការអប់រំពួកគេឱ្យយល់ដឹងអំពីសិទ្ធិរបស់ខ្លួន ការគាំទ្របរិយាកាសដែលមានតម្លាភាព នឹងអាចកាត់បន្ថយអំពើពុករលួយ និងបង្កើនការទទួលខុសត្រូវ

(គណនេយ្យភាព)។  ក្រុមការងារក៏បានពិភាក្សាលើការផ្សារភ្ជាប់បន្ថែមទៅនឹងបញ្ហាផ្សេងៗទៀត  ដូចជាការប្រាស្រ័យទាក់ទងជាមួយអ្នកទទួលជំនួយ ការកសាងទំនុកចិត្ត វត្តមានរបស់អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយ និងពីរបៀបដែលបញ្ហាទាំងនេះ រួមចំណែកបង្កើតបរិយាកាសមួយ ដែលអ្នកទទួលជំនួយទទួលបានចំណេះដឹង ទំនុកចិត្ត និងការគាំទ្រពីក្រៅ ដើម្បីចូលរួមប្រយុទ្ធប្រឆាំងនឹងកង្វះខាតតម្លាភាព និងលើកកំពស់គណនេយ្យភាព។

## VI. ភាពជាម្ចាស់ជំនួយល្អ

បញ្ហាមួយក្នុងចំណោមបញ្ហាជាទូទៅបំផុត  ដែលប្រជាពលរដ្ឋបានលើកឡើង  គឺរបៀបដែលពួកគេចង់ឱ្យម្ចាស់ជំនួយប្រព្រឹត្តិចំពោះពួកគេ។ ប្រជាពលរដ្ឋបានចាត់ទុក "ម្ចាស់ជំនួយ" ជាស្ថាប័នមួយ ដែលបានផ្តល់ជំនួយដល់ពួកគេ។ ដូច្នេះភាគច្រើននៃអ្វីដែលប្រជាពលរដ្ឋបានពិភាក្សា  គឺជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាល  ច្រើនស្មើគ្នានឹងអ្វីដែលពួកគេបានពិភាក្សាអំពីម្ចាស់ជំនួយធំៗនៅទីក្រុងដែរ។ វាជាការសោកស្តាយ ដែលយើងមិនបានពិភាក្សាជាមួយបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានច្រើន ពីព្រោះពួកគេបានលើកឡើងស្របគ្នានូវយោបល់ស៊ីជម្រៅ និងរិះគន់អំពីអ្វីដែលពួកគេជួបប្រទះពេលធ្វើការជាមួយម្ចាស់ជំនួយអន្តរជាតិបច្ចុប្បន្ន និងពេលធ្វើការជាមួយអង្គការអន្តរជាតិ នៅមុនពេលដែលពួកគេធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។

### ក. វត្តមានម្ចាស់ជំនួយដើម្បីស្វែងយល់ពីបរិបទនិងសហគមន៍

មានការព្រមព្រៀងគ្នាក្នុងចំណោមប្រជាពលរដ្ឋថា  ប្រសិនបើម្ចាស់ជំនួយបានចំណាយពេលច្រើននៅក្នុងភូមិ  ដែលពួកគេបានផ្តល់មូលនិធិឧបត្ថម្ភគំរោង  ពួកគេនឹងយល់ច្បាស់អំពីដែនកំណត់របស់គំរោង  និងអាចមានភាពបត់បែនច្រើនចំពោះការផ្លាស់ប្តូរការរៀបចំកម្មវិធី។  ពួកគេក៏មានជំនឿផងដែរថា  ប្រការនេះនឹងជួយឱ្យម្ចាស់ជំនួយបានយល់អំពីស្ថានភាព "ជាក់ស្តែង" និងតម្រូវការពិតប្រាកដ ដែលរួមចំណែកដល់ការផ្តល់ថវិកាកាន់តែសមស្រប។ ប្រជាពលរដ្ឋយល់ថា ការចុះមូលដ្ឋានច្រើនពីសំណាក់ម្ចាស់ជំនួយ ក៏នឹងជួយកសាងទំនាក់ទំនងកាន់តែល្អ និងអនុញ្ញាតឱ្យប្រជាពលរដ្ឋរួមគ្នាធ្វើការក្នុងស្មារតីភាពជាដៃគូ។ សំណូមពរមួយចំនួនពីប្រជាពលរដ្ឋផ្សេងៗ រួមមាន :

> "ម្ចាស់ជំនួយគួរតែបញ្ជូនបុគ្គលិករបស់ខ្លួនឱ្យចុះមូលដ្ឋានប្រាំមួយខែម្តង  ហើយអ្នកជំនាញ  និងអ្នកស្ម័គ្រចិត្តមួយចំនួនអាចមកស្នាក់នៅក្នុងសហគមន៍រយៈពេល១៥ថ្ងៃ   ដើម្បីស្វែងយល់អំពីស្ថានភាពពិតប្រាកដ"។  *(ខេត្តមណ្ឌលគិរី បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល)*។

"ម្ចាស់ជំនួយគួរតែជួបជាមួយប្រជាពលរដ្ឋ  ដើម្បីស្វែងយល់ពីតម្រូវការពិតប្រាកដរបស់ពួកគេ  មុនពេលផ្តល់ជំនួយឱ្យប្រជាពលរដ្ឋ។  អ្នកភូមិដឹងអំពីតម្រូវការពិតប្រាកដរបស់ខ្លួន។  ពួកគេចង់ប្រាប់ម្ចាស់ជំនួយឱ្យបានដឹង"។  *(ប្តីប្រពន្ធ*

*ក្នុងវ័យ៣០ឆ្នាំ រស់នៅក្នុងភូមិអណ្តែតទឹក ខេត្តពោធិ៍សាត់)* ។

"យើងចុះតាមដានរៀងរាល់ប្រាំមួយខែ។ យើងចង់ឃើញម្ចាស់ជំនួយរបស់យើងមកទីនេះឱ្យបានញឹកញាប់។ ប៉ុន្តែជាអកុសល នៅពេលដែលពួកគេមានជំនឿថា កម្មវិធីដំណើរការបានល្អ ពួកគេមិនចុះមកញឹកញាប់ទេ។ យើងចង់ឱ្យម្ចាស់ជំនួយចុះមកមើលស្ថានភាពជាក់ស្តែង កុំគ្រាន់តែអានរបាយការណ៍របស់យើង ឬប្រភពផ្សេងទៀត អំពីស្ថានភាពនោះ។ ឧទាហរណ៍ នៅក្នុងរបាយការណ៍មួយពួកគេនិយាយថា ការចុះមូលដ្ឋាន/ការបណ្តុះបណ្តាល ប្រើពេលមួយថ្ងៃ តែការពិតវាប្រើពេលពីរថ្ងៃ ដោយសារតែស្ថានភាពផ្លូវមានការលំបាក។ ម្ចាស់ជំនួយមិនយល់ទេ ពួកគេមិនដែលបានឃើញផ្លូវនៅមូលដ្ឋានទេ។ ពួកគេទាមទារចង់ដឹង ពីមូលហេតុដែលយើងបានចំណាយពេលច្រើនលើសកម្មភាពការងារ។ ពួកគេនឹងលែងសួរទាមទារចង់ដឹង បើសិនជាពួកគេមកចំណាយពេលច្រើននៅទីនេះ"។ *(បុគ្គលិកអង្គការក្នុងស្រុក ក្នុងវ័យ២០ឆ្នាំ ខេត្តមណ្ឌលគិរី)* ។

"បើសិនជាអ្នកផ្តល់ថវិកាសម្រាប់គំរោងនៅទីនេះ អ្នកគួរតែចុះមកមើលស្ថានភាពជាក់ស្តែង។ បើសិនជាអ្នកសម្រេចចិត្តសាងសង់ផ្លូវ អ្នកត្រូវពិនិត្យមើលថា តើផ្លូវនោះមានបញ្ហាពិតប្រាកដមែនឬទេ ឬវាជារឿងផ្សេង"។ *(ខេត្តមណ្ឌលគិរី សមាជិកក្រុមប្រឹក្សាឃុំ)* ។

ប្រជាពលរដ្ឋជាច្រើនបានបង្ហាញពីបំណងប្រាថ្នា ចង់ឃើញមុខ និងដឹងពីអារម្មណ៍របស់អ្នកដែលផ្តល់ជំនួយឱ្យពួកគេ និងដើម្បីស្វែងយល់ពីទឹកចិត្តរបស់ពួកគេឱ្យបានច្បាស់។ នៅក្នុងខេត្តមណ្ឌលគិរី ប្រជាពលរដ្ឋនៅក្នុងភូមិមួយ យល់ច្បាស់នៅពេលដែលពួកគេបាននិយាយអំពីជនបរទេសម្នាក់ ដែលបានមកញ៉ាំបាយជាមួយពួកគេ និងចេះនិយាយភាសាខ្មែរជាមួយពួកគេ។ សំណូមពរជាទទូច ដែលសុំឱ្យមានអ្នកខាងក្រៅច្រើនថែមទៀតមានវត្តមាននោះ គឺមិនគ្រាន់តែជាការអំពាវនាវឱ្យមានការពិនិត្យតាមដានល្អប្រសើរប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបានឆ្លុះបញ្ចាំងពីបំណងប្រាថ្នា ចង់ឱ្យទីភ្នាក់ងារទាំងឡាយកសាងទំនាក់ទំនងគោរពគ្នា ដែលធ្វើឱ្យមានភាពសុខដុមចំពោះគ្នាទៅវិញទៅមក។

## ៩. អាទិភាព និងវិធីសាស្ត្ររបស់ម្ចាស់ជំនួយ ដែលមិនស្របនឹងតម្រូវការរបស់អ្នកទទួល

អ្នកទទួលជំនួយបានកត់សម្គាល់ថា អាទិភាពរបស់ម្ចាស់ជំនួយ តែងតែមិនស្របនឹងអាទិភាពរបស់ពួកគេទេ ហើយឱកាសជាច្រើនត្រូវខកខាន ក្នុងការផ្តល់មូលនិធិដល់គំរោង ដែលផ្តោតគោលដៅលើអ្នកដែលត្រូវការពិតប្រាកដ ឬសម្រេចបានលទ្ធផលខ្ពស់។

"ម្ចាស់ជំនួយគ្រាន់តែមើលផលធៀបចំណាយ និងចំនួនអ្នកទទួលផលប៉ុណ្ណោះ ដូច្នេះសំណើមួយចំនួនរបស់យើង

មិនបានទទួលមូលនិធិពីម្ចាស់ជំនួយ។ ខ្ញុំសុំសំណូមពរថា ម្ចាស់ជំនួយគួរតែកែតម្រូវលក្ខណៈវិនិច្ឆ័យ នៃការជ្រើសរើស..... ចំណាប់អារម្មណ៍របស់ម្ចាស់ជំនួយ និងតម្រូវការរបស់ប្រជាពលរដ្ឋ មិនដែលត្រូវគ្នា.....។ ទោះបីជាចំនួនប្រជាពលរដ្ឋមានតិចតួចក៏ដោយ ក៏ពួកគេនៅតែត្រូវការជំនួយ ពីព្រោះពួកគេក្រីក្រណាស់។ ម្ចាស់ជំនួយមិនគួរជ្រើសរើសគំរោង ដោយផ្អែកលើចំនួនអ្នកទទួលផលសរុបទេ"។ *(លេខាធិការនៃក្រុមប្រឹក្សាឃុំ ខេត្តពោធិ៍សាត់)* ។

"គំរោងសំខាន់ៗមួយចំនួន អាចផ្លាស់ប្តូរជីវិតរបស់ប្រជាពលរដ្ឋបាន..... ប៉ុន្តែទស្សនវិស័យចង្អៀតចង្អល់របស់ម្ចាស់ជំនួយរារាំងមិនឱ្យការផ្លាស់ប្តូរនេះ កើតឡើងបាន....."។ *(សមាជិកក្រុមប្រឹក្សាឃុំ ខេត្តពោធិ៍សាត់)* ។

"អង្គការមិនមែនរដ្ឋាភិបាលមួយបានលើកឡើងថា បើសិនជាអ្នកកសាងអណ្តូងមួយ យើងនឹងឱ្យបង្គន់ដល់អ្នកដោយឥតគិតថ្លៃ។ ដូច្នេះប្រសិនបើគ្មានលុយកសាងអណ្តូងទេ អ្នកក៏គ្មានបង្គន់ដែលឥតគិតថ្លៃដែរ។ គំរោងនេះមិនជួយជនក្រីក្រដែលគ្មានលុយទេ ប៉ុន្តែវាជួយអ្នកដែលមានលុយខ្លះៗហើយ"។ *(ប្រពន្ធអនុប្រធានភូមិ ដែលមានអាយុប្រមាណ៤០ឆ្នាំ ខេត្តបាត់ដំបង)* ។

### ត. និន្នាការម្ចាស់ជំនួយ

អង្គការក្នុងស្រុក បានពន្យល់ប្រាប់សមាជិកក្រុមអ្នកស្តាប់មតិយោបល់ថា ពួកគេទម្លាប់នឹងនិន្នាការប្រែប្រួលរបស់ម្ចាស់ជំនួយទៅហើយ និងអនុវត្តទៅតាមនិន្នាការទាំងនោះ ពីព្រោះពួកគេពឹងផ្អែកលើជំនួយបរទេស។ ប្រធានអង្គការក្នុងស្រុកមួយបានមានប្រសាសន៍ថា ការផ្លាស់ប្តូរបេសកកម្មរបស់អង្គការរៀងរាល់ប្រាំឆ្នាំម្តង ដើម្បីតម្រូវតាមម្ចាស់ជំនួយត្រូវបានមើលឃើញថា ជាការចាំបាច់ដើម្បីតាមអោយទាន់សភាពការណ៍ និងទទួលបានមូលនិធិជាបន្ត។ ទោះបីជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋជាច្រើនបានអំពាវនាវសុំឱ្យមានការប្តេជ្ញាចិត្ត ផ្តល់មូលនិធិរយៈពេលវែង ដើម្បីផ្តល់ជំនួយដែលជួយឱ្យសម្រេចបានការផ្លាស់ប្តូរ ដែលអាចស្ថិតស្ថេរបានយូរអង្វែង។ សម្រាប់ប្រជាពលរដ្ឋជាច្រើន ការប្តេជ្ញាចិត្តបែបនេះត្រូវការពេលវេលាលើសពីបីឆ្នាំ។ សម្រាប់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ភាពស៊ីសង្វាក់គ្នារបស់ម្ចាស់ជំនួយ គឺជាបញ្ហាស្លាប់រស់។

"អង្គការមិនមែនរដ្ឋាភិបាល មិនអាចធ្វើផែនការសម្រាប់រយៈពេលយូរបានទេ ពីព្រោះជីវិតរបស់ពួកគេពឹងផ្អែកលើម្ចាស់ជំនួយ។ អ្នកត្រូវការពេលបីឆ្នាំ ដើម្បីរៀបចំផែនការបានល្អបំផុត"។ *(បុរសម្នាក់ អាយុជាង៣០ឆ្នាំ ជាប្រធានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក)* ។

"នៅក្នុងឆ្នាំ១៩៩៩ ម្ចាស់ជំនួយបានផ្លាស់ប្តូរបេសកកម្មរបស់ពួកគេ ហើយយើងត្រូវតែតម្រូវតាមពួកគេ។ ពួកគេបានផ្លាស់ប្តូរពីកសិកម្មទៅជាការកសាងសមត្ថភាព។ មានតែម្ចាស់ជំនួយមួយចំនួនតូចប៉ុណ្ណោះ ដែលមានបេសកកម្មរយៈពេលវែង។ ម្ចាស់ជំនួយគួរតែគោរពតាមបេសកកម្មរបស់ខ្លួន។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ផ្លាស់ប្តូរ

បេសកកម្មដើម្បីទទួលបានលុយ ពីព្រោះពួកគេមិនទាន់បានបញ្ចប់នូវអ្វីដែលពួកគេបានចាប់ផ្ដើម។ នៅពេលដែលពួកគេ (ម្ចាស់ជំនួយ) បញ្ចប់បេសកកម្មរបស់ខ្លួន យើងក៏បញ្ចប់បេសកកម្មរបស់យើងដែរ។ ម្ចាស់ជំនួយនិយាយថា ពួកគេមិនចង់ឱ្យអ្នកផ្លាស់ប្ដូរបេសកកម្មទេ តែការពិតពួកគេផ្លាស់ប្ដូរខ្លួនឯង"។ *(ប្រធានអង្គការក្នុងស្រុកម្នាក់ អាយុ៥០ឆ្នាំ នៅខេត្តបាត់ដំបង)* ។

"ម្ចាស់ជំនួយមិនគួរផ្លាស់ប្ដូរចិត្តញឹកញាប់ពេកទេ។ ការអប់រំមិនមែនជាផ្នែកមួយ ដែលយើងអាចឃើញផល ក្នុងរយៈពេលតែបីឆ្នាំនៃការគាំទ្រប៉ុណ្ណោះទេ"។ *(ស្ត្រីវ័យ៥០ឆ្នាំ ជាប្រធានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ផ្នែកអប់រំ នៅភ្នំពេញ )* ។

"ខ្ញុំបានធ្វើការជាមួយជនបរទេស៣០នាក់ មកពីប្រទេសផ្សេងៗ យើងបានផ្លាស់ប្ដូរពីមនុស្សម្នាក់ទៅម្នាក់ទៀត។ រាល់ពេលដែលគេផ្លាស់ប្ដូរបុគ្គលិក ពួកគេផ្លាស់ប្ដូរកម្មវិធី និងឧបករណ៍ អ្នកត្រូវតែប្រើប្រាស់ឧបករណ៍របស់ខ្ញុំ"។ *(បុរសវ័យ៣០ឆ្នាំ ជាប្រធានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ)* ។

## ឃ. គោលនយោបាយ និងនីតិវិធីរបស់ម្ចាស់ជំនួយ

មានការយល់ដឹងជាទូទៅ ជាពិសេសក្នុងចំណោមអ្នកធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ថាម្ចាស់ជំនួយមានតម្រូវការច្រើនពេកលើការសរសេរ ទាំងសម្រាប់របាយការណ៍ ទាំងសម្រាប់សំណើសុំមូលនិធិ។ លើសពីនេះ ក៏មានការអាក់អន់ចិត្តផងដែរថា ពេលវេលា និងទម្រង់របាយការណ៍ មិនស្របគ្នាក្នុងចំណោមម្ចាស់ជំនួយ។ ដូច្នេះអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនត្រូវចំណាយពេល និងកិច្ចប្រឹងប្រែងច្រើន លើការសរសេររបាយការណ៍ភាពជឿនលឿន ជាងផ្ដោតលើការអនុវត្តគំរោង។ ការបង់ប្រាក់លើចំណាយគំរោងតែម្យ៉ាង ហើយមិនបង់ថ្លៃចំណាយរដ្ឋបាល ព្រមទាំងការយឺតយ៉ាវក្នុងការបង់ថ្លៃចំណាយគំរោង ក៏ជាកង្វល់សម្រាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកផងដែរ។

"ការសរសេរសំណើ និងរបាយការណ៍ជាភាសាអង់គ្លេស គឺជាការខ្ជះខ្ជាយពេលវេលាយ៉ាងច្រើន។ ការកៀរគរថវិកា គឺជាបញ្ហាប្រឈមចំពោះមុខសម្រាប់អង្គការតូចៗ និងមធ្យម។ មូលនិធិរយៈពេលខ្លីមិនបានជួយដល់គំរោងរបស់យើងមួយចំនួន ដែលត្រូវការជំនួយរយៈពេលវែងទេ.....។ ម្ចាស់ជំនួយនីមួយៗមានគោលនយោបាយផ្សេងគ្នា លើល័ក្ខខ័ណ្ឌផ្ដល់មូលនិធិរបស់ពួកគេ។ ម្ចាស់ជំនួយភាគច្រើនចាប់អារម្មណ៍លើហេដ្ឋារចនាសម្ព័ន្ធ ហើយមិនចាប់អារម្មណ៍លើការគាំទ្រថ្លៃចំណាយរដ្ឋបាលទេ។ ដូច្នេះការជំរុញឱ្យប្រើប្រាស់មូលនិធិរួម គឺជាបញ្ហាលំបាកមួយ"។ *(អ្នកគ្រប់គ្រងកម្មវិធីរបស់អង្គការជាតិមួយ នៅភ្នំពេញ)* ។

"ដើម្បីបានប្រាក់១០ 000 ដុល្លាអាមេរិក យើងត្រូវបំពេញល័ក្ខខ័ណ្ឌ ដោយត្រូវសរសេររបាយការណ៍ឱ្យបាន ២០ទំព័រ។

សម្រាប់អង្គការតូច ការងារនេះមិនអាចធ្វើបានទេ"។ *(បុរសវ័យ៣០ឆ្នាំ ជាប្រធានអង្គការក្នុងស្រុកមួយ នៅខេត្តបាត់ដំបង)* ។

"ម្ចាស់ជំនួយមិនផ្ទេរមូលនិធិបានទាល់ពេលវេលាទេ។ យើងចុះហត្ថលេខាលើសំណើនៅក្នុងខែវិច្ឆិកា ប៉ុន្តែពួកគេមិនទាន់ផ្ញើលុយមកឱ្យយើង។ បញ្ហានេះធ្វើឱ្យមានការលំបាក ដោយយើងត្រូវធ្វើបុរេប្រទានមូលនិធិ។ យើងត្រូវដកលុយពីថវិកាផ្សេង"។ *(បុគ្គលិកអង្គការអន្តរជាតិមួយ នៅភ្នំពេញ)* ។

## ៦. តម្រូវការសម្រាប់ការពិនិត្យតាមដានបន្ថែម និងប្រសើរជាងមុន

ប្រជាពលរដ្ឋបានសំណូមពរជាទូទៅ សុំឱ្យមានការត្រួតពិនិត្យតាមដានឱ្យបានញឹកញាប់ និងហ្មត់ចត់ដែលផ្តោតលើការវាស់វែងឥទ្ធិពល ដែលរាប់បញ្ចូលទាំងឥទ្ធិពលជាគុណភាព។

"ម្ចាស់ជំនួយគ្រាន់តែតាមដានលុយដែលបានចំណាយប៉ុណ្ណោះ។ ពួកគេមិនតាមដានឥទ្ធិពលឡើយ"។ *(មន្ត្រីជាន់ខ្ពស់មួយរូប នៅក្រសួងកិច្ចការនារី នៅភ្នំពេញ)* ។

"បើសិនជាពួកគេមើលឃើញកំហុស ប្រាប់យើងភ្លាមទៅ កុំឱ្យដូចប៉ូលីសដេញចាប់ចោរ។ នៅពេលដែលពួកគេចុះតាមដាន មើលទៅដូចជាការងារអធិការកិច្ចច្រើនជាង។ បើសិនជាពួកគេរកឃើញកំហុស កំហុសដូចជាមិនច្បាស់សោះ។ មានការយល់ច្រឡំ។ ឧទាហរណ៍ ពួកគេគិតថា យើងពឹងពាក់អាជ្ញាធរ តែយើងពន្យល់ពួកគេថា យើងសហការជាមួយអាជ្ញាធរ ហើយយើងជាអ្នកសម្រេចចិត្តធ្វើការងារនេះ។ យើងត្រូវតែសហការជាមួយពួកគេ។ ខ្ញុំមានអារម្មណ៍មិនសប្បាយសោះ ដូចជាយើងត្រូវបានចោទប្រកាន់ថាបានលួចលុយជំនួយ និងកេងប្រវ័ញ្ចជនក្រីក្រ។ ក្នុងនាមជាដៃគូ យើងត្រូវតែពិភាក្សាគ្នា។ ពួកគេត្រូវតែប្រមូលព័ត៌មានឱ្យបានច្បាស់លាស់។ សូមឱ្យប្រាកដថា យើងចែកចាយព័ត៌មានបានត្រឹមត្រូវ។ ពួកគេទទួលបានព័ត៌មានតែម្ខាងប៉ុណ្ណោះ។ នៅចុងបញ្ចប់ ម្ចាស់ជំនួយគួរតែអង្គុយពិភាក្សាជាមួយយើង។ ពួកគេត្រូវផ្តល់ព័ត៌មានត្រឡប់ភ្លាមៗ"។ *(ស្ត្រីវ័យ៥០ឆ្នាំ ជាប្រធានអង្គការក្នុងស្រុកមួយ នៅខេត្តបាត់ដំបង)* ។

"ម្ចាស់ជំនួយសង្កត់ធ្ងន់តែលើបរិមាណប៉ុណ្ណោះ។ ខ្ញុំកំពុងតស៊ូមតិសុំឱ្យពួកគេបញ្ចូលការសង្កត់ធ្ងន់លើគុណភាពផង"។ *(ស្ត្រីខ្មែរម្នាក់ក្នុងវ័យ៣០ឆ្នាំ ដែលធ្វើការជាមួយអង្គការអន្តរជាតិមួយ)* ។

"អ្នកសម្របសម្រួលគំរោងចុះមូលដ្ឋានរៀងរាល់បីខែ ម្ចាស់ជំនួយអន្តរជាតិចុះមកមួយឆ្នាំម្តង មិនច្រើនទេ។ វាជាការល្អ ប្រសិនបើចុះមកច្រើនដង ដើម្បីកុំឱ្យមានការយល់ច្រឡំ និងលើកទឹកចិត្តដល់យើង មិនគ្រាន់តែឱ្យដាក់របាយការណ៍ជូនប៉ុណ្ណោះទេ"។ *(បុរសម្នាក់វ័យ៥០ឆ្នាំ ជាប្រធានអង្គការក្នុងស្រុកមួយ នៅខេត្តបាត់ដំបង )* ។

## ច. អ្វីដែលម្ចាស់ជំនួយគួរផ្តល់មូលនិធិ

មនុស្សជាច្រើន មានយោបល់ស្របគ្នាលើអ្វីដែលម្ចាស់ជំនួយគួរផ្តល់មូលនិធិ។ ក្នុងចំណោមយោបល់ទាំងនេះ យោបល់ជាទូទៅបំផុត គឺការសង្កត់ធ្ងន់លើផ្នែកកសិកម្ម។ ក៏មានការព្រមព្រៀងគ្នាផងដែរថា កិច្ចប្រឹងប្រែងកសាងសមត្ថភាពមានតម្លៃយ៉ាងខ្លាំង សម្រាប់ការលើកកំពស់ជីវភាពរស់នៅ ចំណែកការអប់រំជំរុញឱ្យមានតម្លាភាព និងជាមធ្យោបាយនៃការធ្វើឱ្យរដ្ឋាភិបាលទទួលខុសត្រូវ។

"ត្រូវធ្វើសមាហរណកម្មកំណែទម្រង់កសិកម្ម និងកំណែទម្រង់ច្បាប់ថែមទៀត.....។ ម្ចាស់ជំនួយគួរតែពង្រឹងសហប្រតិបត្តិការ ហើយពួកគេគួរតែគាំទ្រចំពោះបញ្ហារបស់ស្ត្រី ពីព្រោះស្ត្រីនៅក្នុងប្រទេសនេះត្រូវការជំនួយច្រើន។ សូមផ្តល់សិទ្ធិអំណាចដល់សង្គមទាំងមូល ទោះបីជាវាត្រូវការពេលវេលាច្រើនក៏ដោយ.....។ បុរសអាចដើរបាន ចំណែកស្ត្រីគ្រាន់តែវារប៉ុណ្ណោះ"។ *(មន្ត្រីជាន់ខ្ពស់នៅក្រសួងកិច្ចការនារី នៅភ្នំពេញ)*។

"ការអប់រំមានសារៈសំខាន់ណាស់ ពីព្រោះវាអាចជួយផ្លាស់ប្តូរសង្គមបាន ដូច្នេះម្ចាស់ជំនួយគួរតែផ្តោតលើវិស័យនេះ"។ *(ស្ត្រីក្នុងវ័យ៥០ឆ្នាំ ជាអនុប្រធានអង្គការក្នុងស្រុកមួយ)*។

"ម្ចាស់ជំនួយផ្នែកអភិវឌ្ឍន៍ គួរតែផ្តល់មូលនិធិលើការកសាងសមត្ថភាព និងអ្វីដែលបានកំណត់ដោយបុគ្គលិកក្នុងស្រុក"។ *(បុរសក្នុងវ័យ៣០ឆ្នាំ ជាប្រធានអង្គការក្នុងស្រុកមួយ នៅខេត្តបាត់ដំបង)*។

"ជំនួយបរទេសគួរតែផ្តោតលើការផ្លាស់ប្តូរគោលនយោបាយ គោលនយោបាយរូបិយវត្ថុ (ទប់ស្កាត់អតិផរណា) ការលើកទឹកចិត្តដល់វិនិយោគទុនក្នុងស្រុក និងសហគ្រាសខ្នាតតូច។ រដ្ឋាភិបាលនៅតែទទួលបានមូលនិធិ ច្រើនជាងសង្គមស៊ីវិលដដែល ហើយបើសិនជាគ្មានតម្លាភាពនៅក្នុងរដ្ឋាភិបាល អ្វីៗមិនអាចល្អប្រសើរបានឡើយ"។ *(បុរសក្នុងវ័យ៣០ឆ្នាំ ជាអ្នកសម្របសម្រួលអង្គការក្នុងស្រុក នៅភ្នំពេញ)*។

### *ការឆ្លុះបញ្ចាំងរបស់សមាជិកក្រុមអ្នកស្តាប់មតិយោបល់*

សមាជិកក្រុមអ្នកស្តាប់មតិយោបល់បានទទួលស្គាល់ថា តម្រូវការ និងប្រព័ន្ធម្ចាស់ជំនួយមួយចំនួន "មានភាពងាយស្រួល សម្រាប់អ្នកប្រើប្រាស់"។ ក្នុងអំឡុងជំនួបចំរុះទីភ្នាក់ងារ នៅចុងបញ្ចប់នៃការប្រជុំស្តីពីគំរោងស្តាប់មតិយោបល់ តំណាងអង្គការអន្តរជាតិមួយចំនួន បានបង្ហាញពីចំណាប់អារម្មណ៍លើការធ្វើស្តង់ដារ សម្រាប់តម្រូវការធ្វើរបាយការណ៍ ដើម្បីសម្រាលបន្ទុកទាំងនេះលើអង្គការមិនមែនរដ្ឋាភិបាល។

មានការព្រមព្រៀងជាទូទៅថា វដ្តមូលនិធិរយៈពេលខ្លី និងមិនអាចបត់បែន បានរារាំងដល់ការធ្វើឱ្យកម្មវិធីមាននិរន្តរភាព ហើយការផ្លាស់ប្តូរធំដុំ ត្រូវការការប្តេជ្ញាចិត្តរយៈពេលវែងពីម្ចាស់ជំនួយ។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល

មួយបានបញ្ចេញយោបល់ថា "យើងគិតអំពីយុទ្ធសាស្ត្រពេលបញ្ចប់ជំនួយ នៅពេលដែលយើងចាប់ផ្តើមគំរោងមួយ"។ បុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាលមួយ បានកត់សម្គាល់ថា គេត្រូវការពេលវេលា១៥ ឆ្នាំ ដើម្បីវាស់វែងផលប៉ះពាល់នៃកម្មវិធីរបស់ពួកគេបានពិតប្រាកដ ប៉ុន្តែជារឿយៗ បុគ្គលិកមានកិច្ចសន្យារយៈពេលពីរឆ្នាំ ហើយដៃគូមានកិច្ចសន្យារយៈពេលតែមួយឆ្នាំ។ គេមានការយល់ដឹងថា អង្គការអន្តរជាតិ និងម្ចាស់ជំនួយបានគិតអំពីរយៈពេលវែង ប៉ុន្តែដំណើរការ និងនីតិវិធីរបស់ប្រព័ន្ធជំនួយ ពុំស្របគ្នាជាមួយទស្សនវិស័យនេះឡើយ។ អ្នកសង្កេតការណ៍ម្នាក់បានកត់សម្គាល់ថា "អង្គការអន្តរជាតិបញ្ចប់(គំរោង) និងសរសេរនូវអ្វីដែលពួកគេបានធ្វើនៅក្នុងសំណើ ហើយនិយាយថា វាជាជោគជ័យមួយ គំរោងបានបញ្ចប់ ប៉ុន្តែបន្ទាប់មកគំរោងនោះពុំមាននិរន្តរភាពឡើយ"។

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការតូចៗត្រូវប៉ះពាល់យ៉ាងខ្លាំង ដោយសារនិន្នាការ និងតម្រូវការមិនទៀងទាត់របស់ម្ចាស់ជំនួយ កង្វះខាតធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ឬជំនាញភាសាអង់គ្លេសដើម្បីបំពេញតម្រូវការទាំងនោះ។ អ្នកដែលយើងបានស្តាប់ បានកត់សម្គាល់ថា ពួកគេយល់ពីមូលហេតុដែលធ្វើឱ្យអាទិភាពរបស់ម្ចាស់ជំនួយមានការប្រែប្រួល ហើយការងារអភិវឌ្ឍន៏នឹងនៅតែបន្តប្រែប្រួល ដើម្បីបញ្ចូលបញ្ហាបច្ចុប្បន្ន ដូចជាការផ្លាស់ប្តូរអាកាសធាតុ យេនឌ័រ និងបរិស្ថាន។ បុគ្គលិកជំនួយម្នាក់បានកត់សម្គាល់បន្ថែមលើទស្សនៈនេះថា "ការកសាងស្ពាន និងការកសាងទំនុកចិត្តឡើងវិញ មានសារៈសំខាន់យ៉ាងខ្លាំងនៅក្នុងគំរោងអភិវឌ្ឍន៏។ យើងធ្វើការងារនេះមិនទាន់បានគ្រប់គ្រាន់នៅឡើយទេ ការប្តេជ្ញាចិត្តមិនទាន់បានល្អគ្រប់គ្រាន់ឡើយ ការប្តេជ្ញាចិត្តផ្នែកនយោបាយមិនទាន់រឹងមាំទេ។ នៅមានការខ្វែងគំនិតគ្នាក្នុងចំណោមម្ចាស់ជំនួយ និងអង្គការអន្តរជាតិ.....។ ការកសាងទំនាក់ទំនងត្រូវការពេលវេលា។ យើងត្រូវបានជំរុញដោយអន្តរាគមន៏រយៈពេលខ្លី និងលទ្ធផលភ្លាមៗ។ ការងាររបស់យើងជាអង្គការអន្តរជាតិ គឺផ្តោតលើផលិតផល (outputs) និងលទ្ធផល (outcomes) ច្រើនពេក ហើយមិនបានផ្តោតលើឥទ្ធិពល (impact) គ្រប់គ្រាន់ និងជាពិសេសលើធនធានដែលមិនមែនជាសម្ភារៈផ្សេងទៀត ដែលកំពុងបំភ្លេចចោល"។

ជាចុងក្រោយ ទាំងអ្នកទទួលជំនួយ ទាំងសមាជិកក្រុមអ្នកស្តាប់មតិយោបល់ បានកត់សម្គាល់ថា របៀបដែលអ្នកខាងក្រៅវាស់វែងឥទ្ធិពលនៃអន្តរាគមន៏អភិវឌ្ឍន៏ ឬសម្រេចថា គំរោងមួយ "បានជោគជ័យ" ត្រូវការការវាយតម្លៃឡើងវិញ។ អ្វីដែលទីភ្នាក់ងារជំនួយបរទេសអាចហៅថា "ជោគជ័យ" នៅលើក្រដាស អ្នកភូមិនៅកម្ពុជា អាចហៅថាជាការបរាជ័យ។ សមាជិកក្រុមអ្នកស្តាប់មតិយោបល់ម្នាក់បានកត់សម្គាល់ថា "ម្ចាស់ជំនួយ គួរតែធ្វើឱ្យគំរោងមាននិរន្តរភាព។ កុំសប្បាយនឹងជោគជ័យ ដែលអ្នកធ្វើសម្រេចបាននៅកម្ពុជាក្នុងរយៈពេលបីឆ្នាំ នៅពេលដែលចាកចេញទៅវិញគ្មានអ្វីនៅសល់ទេ"។

## VII. បញ្ហាវប្បធម៌ ការគោរព និងក្រមសីលធម៌

ប្រជាពលរដ្ឋខ្មែរដែលមានបទពិសោធន៏ធ្វើការជាមួយស្ថាប័នផ្តល់ជំនួយជាតិ និងអន្តរជាតិ អស់រយៈពេលជា

ច្រើនទសវត្ស បានបញ្ចេញយោបល់លើទំនាក់ទំនងរវាងបុគ្គលិកអង្គការជាតិ និងអន្តរជាតិ និងទំនាក់ទំនងរវាងស្ថាប័នផ្តល់ជំនួយជាតិ និងអន្តរជាតិ។ អ្នកទាំងនោះយល់ថា បុគ្គលិកជំនួយបរទេសជាច្រើន មិនស្វែងយល់ពីវប្បធម៌ដែលពួកគេកំពុងបំពេញការងារជាមួយ។ ដូច្នេះជួនកាលពួកគេសម្តែងអាកប្បកិរិយាដោយគ្មានការគោរពចំពោះបុគ្គលិកខ្មែរ។ មិនតែប៉ុណ្ណោះ ក៏មានការយល់ដឹងផងដែរថា ទីភ្នាក់ងារជំនួយអន្តរជាតិ មិនបានឱ្យទីភ្នាក់ងារក្នុងស្រុកចូលរួមក្នុងស្មារតីនៃភាពជាដៃគូពិតប្រាកដឡើយ ដោយអនុវត្តបទដ្ឋាន(ស្តង់ដារ)ផ្សេងៗគ្នា ចំពោះអង្គការក្នុងស្រុក ដូចជារៀបចំគំរោងថវិកាខុសគ្នាសម្រាប់គំរោង និងបុគ្គលិក និងកង្វះការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ។ ការពិគ្រោះយោបល់កាន់តែធ្វើឱ្យធ្ងន់ធ្ងរដោយទិន្នាការឈានទៅរករបៀបប្រាស្រ័យទាក់ទងតាមបែបបស្ចឹមប្រទេស និងតម្រូវឱ្យចេះភាសាអង់គ្លេសស្ទាត់ជំនាញ។

ការតម្រូវឱ្យអនុវត្តតាមទស្សនៈ និងអាទិភាពរបស់បស្ចឹមប្រទេសទាំងស្រុង នៅក្នុងការរៀបចំបង្កើតគំរោងត្រូវបានរិះគន់ និងជាពិសេសទស្សនៈ និងអាទិភាពទាំងឡាយ ដែលផ្តោតលើយេនឌ័រ អំពើហឹង្សាក្នុងគ្រួសារ កម្មវិធីប្រយុទ្ធប្រឆាំងមេរោគអេដស៍/ជំងឺអេដស៍ និងគំរោងអភិរក្សបរិស្ថាន។ ជារឿយៗ វាគឺជាដំណើរការបញ្ចូលនូវអ្វីដែលគេយល់ថាជាទស្សនៈ "ពីខាងក្រៅ" ដែលបង្កឱ្យមានបញ្ហាចម្រូងចម្រាស់ លើសពីទស្សនៈនោះទៅទៀត។ ប្រជាពលរដ្ឋខ្មែរ យល់ថាពេលវេលាច្រើន និងការកសាងទំនាក់ទំនង អាចជួយបានច្រើនក្នុងការបញ្ចូលទស្សនៈផ្នែកវប្បធម៌ និងសង្គមថ្មីៗសមស្របខណៈដែលកាត់បន្ថយភាពរំខានប្រកបដោយគ្រោះថ្នាក់មួយចំនួន ដែលការបង្កើនល្បឿនដំណើរការនេះអាចបង្កឡើង។

ជាចុងក្រោយ ប្រជាពលរដ្ឋខ្មែរ និងបុគ្គលិកជំនួយបរទេស បានបញ្ចេញយោបល់លើការចំណាយមូលនិធិជំនួយអន្តរជាតិខ្ជះខ្ជាយ។ ចំពោះប្រជាពលរដ្ឋខ្មែរទាំងឡាយដែលបានលើកឡើងអំពីប្រធានបទនេះ ការចំណាយលុយលើប្រាក់ខែ និងអត្ថប្រយោជន៍ដ៏លើសលប់ និងជំនួយបច្ចេកទេស "ជំនាញ" និងការអនុញ្ញាតឱ្យប្រើប្រាស់មូលនិធិដោយមានតម្លាភាពតិចតួច ត្រូវមើលឃើញថា ជាការបាត់បង់ឱកាស ក្នុងការជួយប្រជាពលរដ្ឋខ្មែរក្រីក្រពិតប្រាកដ។ ចំពោះអ្នកមួយចំនួន ទង្វើបែបនេះត្រូវបានចាត់ទុកថា ជាទង្វើប្រាសចាកសីលធម៌ទៀតផង។

## ក. ការមិនយល់ដឹង និងភាពក្រអឺតក្រទមផ្នែកវប្បធម៌

មនុស្សមួយចំនួនបានរៀបរាប់អំពីឥរិយាបថ និងទង្វើដែលគ្មានការគោរពរបស់បុគ្គលិកជំនួយបរទេស និងបុគ្គលិកខ្មែរដែលធ្វើការជាមួយអង្គការអន្តរជាតិ ចំពោះបុគ្គលិកខ្មែរដែលធ្វើការនៅក្នុងអង្គការជាតិ។ ជារឿយៗ ទង្វើនេះបង្កឱ្យមានការឈឺចាប់ និងក្តីអាម៉ាស។

"យើងធ្លាប់រស់នៅក្រោមអាណានិគមបារាំង ប៉ុន្តែឥឡូវនេះ សម័យអាណានិគមបានបញ្ចប់ទៅហើយ ប៉ុន្តែពួកគេ

នៅតែប្រព្រឹត្តចំពោះយើង និងមានប្រតិកម្មចំពោះយើង ដូចជាសម័យអាណានិគមដដែល"។ *(បុរសម្នាក់ ក្នុងវ័យ៣០ឆ្នាំ ជាប្រធានអង្គការក្នុងស្រុកមួយ នៅខេត្តបាត់ដំបង)* ។

"គេចេះតែនិយាយ ចេះតែថាកសាងសមត្ថភាព។ ប៉ុន្តែការពិត គេចាត់ទុកប្រជាជនមូលដ្ឋានដូចជាអាយ៉ង។ ពួកគេត្រូវតែឆ្លើយថា "ព្រម" និងធ្វើអ្វីៗតាមបែបបរទេស"។ *(ស្ត្រីម្នាក់ក្នុងវ័យ៣០ឆ្នាំ ជាបុគ្គលិកអង្គការជំនួយអន្តរជាតិ)* ។

"យើងចង់ពិភាក្សាជាមួយម្ចាស់ជំនួយ ប៉ុន្តែពួកគេគិតថា ពួកគេគឺជាស្តេច។ ពួកគេត្រូវមកទីនេះ ដើម្បីបំរើប្រជាជនខ្មែរ"។ *(បុរសក្នុងវ័យ៣០ឆ្នាំម្នាក់ ជាប្រធានអង្គការក្នុងស្រុកមួយ នៅខេត្តបាត់ដំបង)* ។

"សូម្បីតែយើងក៏គេមិនអនុញ្ញាតឱ្យដឹងថា តើលុយនោះចំណាយទៅទីណា ឬទីភ្នាក់ងារម្ចាស់ជំនួយចំណាយទៅលើបុគ្គលិករបស់គេ ឬជួលជំនួយបច្ចេកទេសដែលយើងមិនទាំងត្រូវការ មកឱ្យយើងអស់ប៉ុន្មានដែរ ជួនកាលអ្នកទាំងនោះមិនមានជំនាញផ្ទាល់ខ្លួនច្បាស់លាស់ផង ហើយពួកគេចេះតែបញ្ជាយើង។ ទង្វើបែបនេះគ្មានការគោរពសោះ"។ *(មន្ត្រីជាន់ខ្ពស់ក្រសួងកិច្ចការនារី នៅទីក្រុងភ្នំពេញ)* ។

"បុគ្គលិកម្នាក់ស្រែកទៅកាន់អ្នកបើកបរថា "អ្នកឯងគ្មានខួរក្បាលទេឬ?" នេះគឺជាពាក្យសម្តីធ្ងន់ធ្ងរណាស់ ពីព្រោះពាក្យថា ក្បាលសំខាន់ណាស់នៅក្នុងវប្បធម៌ព្រះពុទ្ធសាសនា។ ពួកគេគួរតែពិចារណាឱ្យបានច្រើនពីរបៀបប្រាស្រ័យទាក់ទង ពាក្យសម្តីនេះគ្មានសីលធម៌ទេ។ ពួកគេមិនគួរធ្វើទង្វើបែបនេះទេ ស្រែកដាក់ពួកយើង។ ខ្ញុំខ្មាសគេណាស់ យើងជាមនុស្សដូចគ្នា.....។ អ្នកឯងមកស្រុកខ្មែរ អ្នកគួរតែរៀនសូត្រពីវប្បធម៌ខ្មែរ"។ *(បុរសម្នាក់ក្នុងវ័យ៣០ឆ្នាំ ជាប្រធានអង្គការក្នុងស្រុកមួយ នៅខេត្តបាត់ដំបង)* ។

## ៩. ការដាក់ទស្សនៈបស្ចឹមប្រទេសនៅក្នុងអាទិភាពនៃការរៀបចំកម្មវិធី

មនុស្សជាច្រើនបានរាយការណ៍អំពីផលប៉ះពាល់ជាអវិជ្ជមាន ឬអប្រសិទ្ធិភាពជាក់លាក់ ចំពោះគំរោងផ្សេងៗ ដែលត្រូវបានមើលឃើញថា ជាការលើកកំពស់ "តម្លៃពីខាងក្រៅ"។ ផលប៉ះពាល់ទាំងនោះរួមមាន របៀបបង្រៀនអំពីការលើកកំពស់ការយល់ដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍ និងអំពើហិង្សាក្នុងគ្រួសារ និងគំរោងទាក់ទងនឹងការអភិរក្ស និងសហគមន៍ព្រៃឈើ។ ទស្សនៈនានា ដូចជា លក្ខណៈវិនិច្ឆ័យភាពងាយរងគ្រោះ ក៏ត្រូវបានលើកឡើងថាជា "ទស្សនៈរបស់បស្ចឹមប្រទេស" ផងដែរ ខណៈដែលការភ្ជាប់គ្រីស្តសាសនាទៅនឹងជំនួយអភិវឌ្ឍន៍ ធ្វើឱ្យប្រជាពលរដ្ឋមានការព្រួយបារម្ភ ពីព្រោះការភ្ជាប់សាសនាគ្រីស្តទៅនឹងជំនួយនោះ ត្រូវបានគេមើលឃើញថា ជាការលើកទឹកចិត្តដល់ការផ្លាស់ប្តូរសាសនា និងជាការលើកទឹកចិត្តមួយ ដែលជារឿយ ប្រជាពលរដ្ឋទីទ័លក្រមិនអាចបដិសេធបាន។

### <u>ការលើកកំពស់ការយល់ដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍ អំពើហិង្សាក្នុងគ្រួសារ និងយេនឌ័រ</u>

ប្រជាពលរដ្ឋ មានការព្រួយបារម្ភថា តាមរយៈការអប់រំអំពីមេរោគអេដស៍/ជំងឺអេដស៍ [អង្គការមិនមែនរដ្ឋាភិបាល] បានបង្ហាញយុវជនអំពីការរួមភេទ នៅខណៈដែលបង្រៀនពួកគេអំពីវិធីបង្ការ ហើយការធ្វើបែបនេះ ជះឥទ្ធិពលជាអវិជ្ជមានលើតម្លៃវប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីខ្មែរ។ ដូចប្រធានអង្គការក្នុងស្រុកម្នាក់បានលើកឡើងថា "ដោយការការពារកុំឱ្យឆ្លងមេរោគអេដស៍ ចំនួនអ្នកផ្ទុកមេរោគអេដស៍មិនថយចុះសោះ តែកើនឡើងទៅវិញ។ ការប្រើស្រោមអនាម័យ ក៏ជាបញ្ហាមួយដែរ។ ការអប់រំអំពីភេទ មានន័យថា មនុស្សចង់សាកល្បងរួមភេទ"។

នៅក្នុងតំបន់មួយចំនួន ប្រជាពលរដ្ឋក៏បានបញ្ចេញកង្វល់ចំពោះការបង្រៀន និងវិធីសាស្ត្របង្រៀនអំពីយេនឌ័រ និងអំពើហិង្សាក្នុងគ្រួសារ។ ពួកគេយល់ថា ទាំងនេះគឺជាទស្សនៈដែលបង្ខំឱ្យអនុវត្តដោយអ្នកខាងក្រៅ ដែលមិនមែនប្រជាជនទាំងអស់សុទ្ធតែយល់ស្របទេ។ ទោះបីជាមនុស្សមួយចំនួនយល់ថា កម្មវិធីទាំងនេះត្រូវបានរៀបចំឡើង ដោយបំណងល្អក៏ដោយ ក៏ពួកគេទាមទារអោយពិនិត្យមើលវិធីសាស្ត្រ និងត្រូវការពេលវេលាច្រើនថែមទៀត ដើម្បីឱ្យប្រជាជនផ្លាស់ប្តូរទំនៀមទម្លាប់ វប្បធម៌ ដែលបានចាក់ឫសយ៉ាងជ្រៅដែរ។

បុរសម្នាក់បាននិយាយថា "អ្នកអាចដាក់ចំណីក្នុងមាត់ប្រពន្ធរបស់អ្នកបាន តែអ្នកមិនអាចបង្ខំនាងឱ្យញ៉ាំបានទេ"។ គាត់បានពន្យល់ថា ប្រហែលជាអ្នកខាងក្រៅកំពុងបញ្ចូលនូវការផ្លាស់ប្តូរជាវិជ្ជមានចំពោះបទដ្ឋានវប្បធម៌ តែគេមិនអាចធ្វើឱ្យនរណាម្នាក់មើលវាឃើញ ឬធ្វើជាម្ចាស់វាបានទេ។ គាត់បានលើកឡើងជាបន្តថា នៅពេលដែលការអប់រំ និងការលើកកំពស់ការយល់ដឹងមិនបានគ្រប់គ្រាន់ គេតែងតែមានជម្រើសផ្សេង ដោយទាមទារឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយាទាំងនេះ តាមរយៈកំណែទម្រង់ច្បាប់។

"ប្រជាជនយល់ឃើញថា យើងបង្រៀនស្ត្រីអំពីសិទ្ធិរបស់ពួកគេ..... បន្ទាប់ពីការអប់រំ ស្ត្រីគិតថា គាត់មានសិទ្ធិ ហើយជឿថា គាត់អាចក្រោកឈរតវ៉ាជាមួយប្តីរបស់ខ្លួនបាន ប៉ុន្តែប្រការនេះធ្វើឱ្យកាន់តែដុនដាបទៅវិញ។ វាជាការឆ្លើយតបមួយដែលមិនសមស្របតាមវប្បធម៌។ ការផ្លាស់ប្តូរក៏កំពុងកើតឡើងយ៉ាងលឿនផងដែរ ហើយ ឱ្យការអប់រំឧនេះ គ្មានការចូលរួមពីបុរស.....។ យេនឌ័រគឺជារឿងថ្មី ហើយនៅពេលដែលពួកគេ ឱ្យអង្គការមិនមែនរដ្ឋាភិបាលឧចាប់ផ្តើម ការងារនេះ វាបង្កឱ្យមានបញ្ហាច្រើនសម្រាប់គ្រួសារ។ វាឆាប់ពេក។ បើសិនជាអ្នកបង្រៀនក្មេងស្រីថា ពួកគេមានសិទ្ធិដូច គ្នា និងអាចធ្វើអ្វីៗបានដូចបុរសដែរនោះ ពួកគេនឹងតមាត់ ហើយទង្វើនេះនឹងបង្កឱ្យមានអំពើហិង្សា។ ការអប់រំយេនឌ័រ គឺជាការសំខាន់ តែការអប់រំនេះត្រូវអនុវត្តឱ្យបានសមស្របតាមវប្បធម៌ខ្មែរ។ បើមិនដូច្នោះទេ ការបណ្តុះបណ្តាលយេនឌ័រ អាចក្លាយជា ភ្លើងដុតសាំង"។ *(បុរសម្នាក់វ័យ៣០ឆ្នាំ ជាប្រធានអង្គការក្នុងស្រុកមួយ នៅខេត្តបាត់ដំបង)* ។

## ការអភិរក្ស និងសហគមន៍ព្រៃឈើ

ការងារអភិរក្សបរិស្ថាន កំពុងផ្លាស់ប្តូរការចិញ្ចឹមជីវិតជាប្រពៃណី ដោយមានលទ្ធផលចំរុះ ជាពិសេសនៅក្នុងខេត្តមណ្ឌលគិរី។ ប្រជាជនបានបង្ហាញពីការអាក់អន់ចិត្ត ជាមួយការផាកពិន័យចំពោះការកាប់បំផ្លាញព្រៃឈើ ថាជារឿងអយុត្តិធម៌ និងចាត់ចែងមិនបានស្មើគ្នារវាងជនជាតិព្នង និងជនជាតិខ្មែរ។ ជាពិសេស ជនជាតិព្នងជាច្រើនមិនយល់ថា តើហេតុអ្វីបានជាពួកគេត្រូវបានបដិសេធមិនឱ្យប្រកបរបរចិញ្ចឹមជីវិតជាប្រពៃណីរបស់ពួកគេ។

"យើងមិនសប្បាយចិត្តជាមួយ (អង្គការអភិរក្សបរិស្ថាន) ទេ ពីព្រោះពួកគេឃាត់បងប្អូនយើងមិនឱ្យកាប់ឈើដើម្បីធ្វើចំការ។ បងប្អូនយើងត្រូវចាប់ខ្លួន ហើយសហគមន៍មានការខឹងសម្បារយ៉ាងខ្លាំង និងត្រូវរៃលុយគ្នាដើម្បីដោះលែងអ្នកដែលគេចាប់ឱ្យមានសេរីភាពវិញ។ ខ្ញុំព្រួយបារម្ភខ្លាចក្រែងកូនចៅរបស់ខ្ញុំគ្មានដីធ្វើចំការ ឬរស់នៅ នៅពេលដែលគ្រួសារកាន់តែធំទៅៗ"។ *(ស្ត្រីជនជាតិព្នងម្នាក់ អាយុប្រមាណ៣០ឆ្នាំ នៅខេត្តមណ្ឌលគិរី)*។

"អង្គការបរទេសភាគច្រើនល្អ ហើយពួកគេផ្តល់ការគាំទ្រដល់ប្រជាជនក្រីក្រ ជាពិសេសជនជាតិព្នងដូចពួកយើង។ ប៉ុន្តែ យើងមិនយល់ស្របជាមួយគោលការណ៍របស់អង្គការអន្តរជាតិមួយ ពីព្រោះពួកគេមិនអនុញ្ញាតឱ្យយើងបន្តការប្រកបរបរចិញ្ចឹមជីវិតជាប្រពៃណីដោយកសិកម្មពនេចរ និងការបរបាញ់សត្វតូចៗពីព្រៃ។ យើងយល់ថា យើងត្រូវអភិរក្សបរិស្ថាន ប៉ុន្តែដូនតាយើងបានពឹងផ្អែកលើការរស់នៅរបៀបនេះ ហើយយើងគ្រាន់តែកាប់ឈើតូចៗ និងសម្លាប់សត្វតូចៗប៉ុណ្ណោះ"។ *(ប្តីប្រពន្ធជនជាតិព្នង ក្នុងវ័យ៣០ឆ្នាំ)*។

"ឆ្នាំខ្លះការនេសាទខុសច្បាប់បានថយចុះ ឆ្នាំខ្លះទៀតមិនបានថយចុះទេ។ នៅពេលដែលប្រជាជនជួបប្រទះភាពក្រីក្រ ពួកគេត្រូវតែនេសាទទោះបីជាតាមវិធីណាក៏ដោយ។ ការអភិរក្សបរិស្ថានមិនអាចដំណើរការបានទេ នៅពេលដែលនៅមានភាពក្រីក្រនៅឡើយ។ *(ស្ត្រីវ័យ៥៥ឆ្នាំ ជាប្រធានសហគមន៍នេសាទ នៅក្នុងភូមិអណ្តែតទឹក ខេត្តពោធិ៍សាត់)*។

## **ការភ្ជាប់ជំនួយជាមួយសាសនាគ្រីស្ត**

"ខ្ញុំចង់បានការធានាថា ពួកគេគោរពវប្បធម៌យើង និងមិនបង្រៀនគ្រីស្តសាសនាដល់ពុទ្ធបរិស័ទ។ សាសនាទាំងអស់សុទ្ធតែល្អ"។ *(បុរសជានាយកសាលាម្នាក់ វ័យ៣០ឆ្នាំ នៅខេត្តបាត់ដំបង)*។

"បច្ចុប្បន្ននេះ គ្រប់គ្នានៅក្នុងតំបន់តាំងទីលំនៅថ្មី សុទ្ធតែក្រីក្រលំបាក។ ប្រជាពលរដ្ឋមួយចំនួនបានផ្លាស់ចូលកាន់សាសនាគ្រីស្ត ដើម្បីឱ្យពួកគេបានទទួលការឧបត្ថម្ភជាបន្ត"។ *(បុរសពីរនាក់ ក្នុងវ័យ៣០ឆ្នាំ នៅទីក្រុងភ្នំពេញ)*។

## **លក្ខណៈវិនិច្ឆ័យភាពងាយរងគ្រោះ**

សំណួរថា តើនរណាជាអ្នកសម្រេចចិត្តថា អ្នកណាត្រូវទទួលជំនួយ បានលេចឡើងនៅក្នុងទីកន្លែងមួយចំនួន។ ទស្សនៈរបស់បស្ចឹមប្រទេសអំពីភាពងាយរងគ្រោះ ឬភាពជាអ្នកធូរធារ តែងតែមិនស៊ីគ្នាជាមួយទស្សនៈក្នុងស្រុក។

សម្រាប់ក្រុមជនជាតិភាគតិច ដូចជាព្នង ដែលអះអាងថា ពួកគេជឿថាបុគ្គលគ្រប់រូបមានសិទ្ធិស្មើគ្នា ហើយសមនឹងទទួលបានជំនួយដូចគ្នានោះ ទស្សនះរបស់បរទេសចំពោះភាពងាយរងគ្រោះ ប្រឆាំងជាមួយទស្សនៈនៃភាពយុត្តិធម៌របស់ប្រជាជនមូលដ្ឋាន។

"ពួកគេមកសួរយើងអំពីតម្រូវការរបស់យើង ហើយក្រោយមក យកអំណោយមកចែកឱ្យយើងជាមួយមន្ត្រីស្រុក។ ប្រជាជនគ្រប់គ្នាទទួលបានអ្វីៗដូចគ្នា និងចំនួនស្មើគ្នា.....។ ប៉ុន្តែ អាហារូបករណ៍សម្រាប់តែកូនចៅអ្នកក្រីក្រប៉ុណ្ណោះ។ យើងមិនយល់ស្របជាមួយការជ្រើសរើសនេះទេ។ ការវាយតម្លៃលើភាពក្រីក្រផ្អែកលើល័ក្ខខ័ណ្ឌថា បើគ្រួសារនោះមានម៉ូតូ ឬផ្ទះឈើ (ជាអ្នកធូរធារ) ឬគ្មានម៉ូតូ និងផ្ទះឬស្សី (ជាអ្នកក្រីក្រ)។ ប្រជាជនខឹងសម្បារចំពោះល័ក្ខខ័ណ្ឌជ្រើសរើស ហើយបានចូលលុកលុយការប្រជុំសហគមន៍ទាំងកំហឹង"។ *(បុរសអាយុ៣០ឆ្នាំម្នាក់ នៅភូមិជនជាតិព្នងមួយ នៅខេត្តមណ្ឌលគិរី)* ។

"ខ្ញុំគ្មានបង្គន់ (ព័រសឺឡែន) ទេ ពីព្រោះបង្គន់(ក្រៅផ្ទះ) របស់ខ្ញុំមានជញ្ជាំង [ហើយបង្គន់មានជញ្ជាំង ត្រូវបានសន្មតថាមានបង្គន់ព័រសឺឡែន។] ខ្ញុំច្រណែននឹងអ្នកដែលមានបង្គន់ព័រសឺឡែន"។ *(ស្ត្រីមេម៉ាយអាយុប្រហែល៣៥ឆ្នាំ នៅភូមិជនមាតុភូមិនិវត្តន៍ ខេត្តបាត់ដំបង)* ។

## គ. ការបង្ខំឱ្យអនុវត្តតាមរបៀបប្រាស្រ័យទាក់ទងរបស់បស្ចិមប្រទេស

បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលខ្មែរ និងមានបរទេសមួយចំនួនតូច បាននិយាយថា ភាពខុសគ្នាផ្នែកវប្បធម៌នៅក្នុងរបៀបប្រាស្រ័យទាក់ទង បានរារាំងទៅនឹងការជំរុញឱ្យបុគ្គលិកខ្មែរកាន់តែច្រើន មានតួនាទីនៅក្នុងទីភ្នាក់ងារជំនួយអន្តរជាតិ។ អ្នកដែលមិនពូកែភាសាអង់គ្លេស ឬមិនពូកែប្រាស្រ័យទាក់ទងតាមរបៀបវប្បធម៌បរទេស ទំនងជាបាត់បង់ឱកាសសម្រាប់ការតម្លើងតួនាទី ឬការចូលរួមកាន់តែច្រើន។

"ជនបរទេស មិនយល់ពីការប្រាស្រ័យទាក់ទងរបស់ខ្មែរ។ យើងនិយាយ យើងពន្យល់ពីគំនិតរបស់យើង ហើយបន្ទាប់មកទើបនិយាយចំណុចសំខាន់នោះ។ អ្នកមកពីបស្ចិមប្រទេស លើកពីចំណុចសំខាន់មុន រួចទើបពន្យល់ពីគំនិតរបស់គេ។ របៀបនេះធ្វើអោយខ្មែរគ្មានសមត្ថភាពតាំងពីពេលចាប់ផ្តើម។ យើងពន្យល់ពីគំនិត ដោយមិននិយាយពីចំណុចនោះភ្លាមទេ"។ *(ស្ត្រីខ្មែរម្នាក់អាយុ៣០ឆ្នាំ ធ្វើការជាមួយអង្គការម្ចាស់ជំនួយអន្តរជាតិ)* ។

"កិច្ចប្រឹងប្រែងរបស់បុគ្គលិកបរទេស ប៉ះពាល់ដល់កិច្ចប្រឹងប្រែងរបស់បុគ្គលិកខ្មែរ ក្នុងការចូលរួមដោយមានន័យ។ យើងត្រូវចំណាយពេលច្រើនលើបុគ្គលិក។ បុគ្គលិកអង្គការអន្តរជាតិ និយាយភាសាអង់គ្លេសញាប់ពេក និងប្រើពាក្យពិបាកៗ។ ដូច្នេះពួកគេធ្វើឱ្យបុគ្គលិកខ្មែរមិនអាចចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ អ្នកខាងក្រៅ គឺជាអ្នករៀបចំឆាកសម្តែង

បុគ្គលិកខ្មែរថែមទាំងមិនត្រូវបានអញ្ជើញឱ្យចូលរួមការប្រជុំថ្នាក់ដឹកនាំផង។ ដូច្នេះ មានវប្បធម៌ស្មុគ្រស្មាញ នៅក្នុងរបៀបរបបធ្វើការងារ.....។ អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយមានការរំពឹងថា ប្រសិនបើយើងមានអំណាច យើងនឹងនិយាយជាចំហ និងក្រោកឈរឡើងដើម្បីការពារសិទ្ធិរបស់ខ្លួន ជារួម គឺធ្វើដូចបុគ្គលិកបរទេសដែរ។ មានតែធ្វើបែបនេះទេ ទើបយើងមានសិទ្ធិក្នុងការដឹកនាំ។ ប៉ុន្តែបុគ្គលិកខ្មែរធ្វើការប្រាស្រ័យទាក់ទងតាមរបៀបដែលពួកគេចង់បាន និងចូលចិត្ត ដែលពួកគេយល់ថាវាច្បាស់លាស់ហើយ បុគ្គលិកបរទេសមិនយល់ពីចំណុចនេះ ហើយរំពឹងចង់បានការប្រាស្រ័យទាក់ទងដែលច្បាស់លាស់ជាងនេះទៀត"។ *(បុគ្គលិកជំនួយអន្តរជាតិម្នាក់ អាយុ៣០ឆ្នាំ)* ។

"ពួកគេ (បុគ្គលិកបរទេស) សុំឱ្យយើងពិចារណាភ្លាមៗ តែយើងមិនបង្ហាញពីអារម្មណ៍របស់យើងបែបនេះទេ"។ *(ប្រធានអង្គការក្នុងស្រុកមួយ អាយុ៣០ឆ្នាំ នៅខេត្តបាត់ដំបង)* ។

## ឃ. ធ្វើការក្នុងស្មារតីភាពជាដៃគូរវាងអង្គការជាតិ អង្គការអន្តរជាតិ និងបុគ្គលិក

បុគ្គលិកខ្មែរជាច្រើន បានប្រាប់សមាជិកក្រុមអ្នកស្តាប់មតិយោបល់ថា ពួកគេចង់បានតួនាទីសកម្មថែមទៀត នៅក្នុងអង្គការអន្តរជាតិ ដែលពួកគេធ្វើការ ហើយការប្រាស្រ័យទាក់ទង មិនសូវមានការគោរពគ្នា និងបង្ហាញពីស្មារតីភាពជាដៃគូពិតប្រាកដឡើយ។ ពួកគេបានពន្យល់ថា បុគ្គលិកអង្គការក្នុងស្រុកនឹងមានភាពម្ចាស់ការ បើសិនជាពួកគេគិតថាពួកគេបានចូលរួមក្នុងការធ្វើផែនការ ការរៀបចំបង្កើតគំរោង និងការរៀបចំថវិកា។ ទំនាក់ទំនងរវាងការយល់ថាសមទទួលបានការចូលរួមក៏រិតនេះ និងការយល់អំពីភាពម្ចាស់ការ គឺជាការសំខាន់សម្រាប់ "ការងារជាមួយគ្នា" នៅក្នុង ឬជាមួយអង្គការអន្តរជាតិ។ លើសពីនេះទៀត គេក៏ឃើញមានការមិនគោរព នៅក្នុងតម្រូវការរបស់អង្គការអន្តរជាតិ ក្នុងការជួលបុគ្គលិកបរទេសជាប្រចាំ ជាជាងបុគ្គលិកខ្មែរ ដើម្បីដឹកនាំអង្គការ ឬផ្តល់ជំនួយបច្ចេកទេសផងដែរ។

"យើងមកទីនេះជាដៃគូ តែពួកគេចាត់ទុកយើងដូចជាកម្មករសំណង់ យើងត្រូវតែបញ្ចប់ការងារឱ្យទាន់ពេលវេលា ដោយមិនគិតថាមានបញ្ហាអ្វីឡើយ។ ពួកគេគិតតែពីរឿងដល់ពេលកំណត់ និងធ្វើឬកដូចជាមេបញ្ជាការ"។ *(ប្រធានអង្គការក្នុងស្រុកមួយ អាយុ៣០ឆ្នាំ នៅខេត្តបាត់ដំបង)* ។

"ក្រសួងកិច្ចការនារីមិនដែលបានទទួលលុយដោយផ្ទាល់ទេ។ គឺទីភ្នាក់ងារដែលផ្តល់លុយហ្នឹងគ្រប់គ្រងលុយឱ្យយើង ដូចជា ឱ្យឈ្មោះម្ចាស់ជំនួយបីឧ។ ការគ្រប់គ្រងប្រភេទនេះ មិនអនុញ្ញាតឱ្យមានការលើកទឹកចិត្ត កើតឡើងនៅថ្នាក់ក្រសួងបានឡើយ។ អ្វីៗដែលយើងចង់ធ្វើ យើងត្រូវធ្វើសំណើសុំពីម្ចាស់ជំនួយ។ ការធ្វើនេះមិនត្រឹមត្រូវទេ"។ *(មន្ត្រីជាន់ខ្ពស់នៅក្រសួងកិច្ចការនារី នៅភ្នំពេញ)* ។

"ដើម្បីគ្រប់គ្រងអង្គការអន្តរជាតិមួយ អ្នកមិនចាំបាច់ត្រូវការមនុស្សអន្តរជាតិទេ.....។ តើវាមានភាពខុសគ្នា

ដូចម្តេច យើងជាមនុស្សដូចគ្នា ប្រសិនបើយើងមានឱកាស យើងធ្វើបានដូចតែគ្នាទេ ដូច្នេះផ្តល់ឱកាសអោយយើងមក៏។ គុណភាពការងាររបស់អង្គការជាតិ និងអង្គការអន្តរជាតិ មិនខុសគ្នាប៉ុន្មានទេ"។ *(បុរសអាយុ៣០ឆ្នាំម្នាក់ ជាប្រធានអង្គការក្នុងស្រុកមួយ)* ។

"ជារឿយៗ ម្ចាស់ជំនួយផ្តល់ជំនួយបច្ចេកទេសច្រើនពេក ហើយជួលទីប្រឹក្សាបច្ចេកទេសបរទេសថ្លៃៗ ដោយមិនជួលទីប្រឹក្សាបច្ចេកទេសក្នុងស្រុក ឱ្យធ្វើការងារនោះទេ"។ *(សមាជិកាសភា នៅភ្នំពេញ)* ។

## ង. ក្រមសីលធម៌សម្រាប់វិសមភាពថវិកា និងការចំណាយ

បុគ្គលិកខ្មែរដែលបានធ្វើការជាមួយអង្គការជាតិ ឬអង្គការអន្តរជាតិ បានរាយការណ៍ថា គ្មានភាពយុត្តិធម៌ទេ សំរាប់វិសមភាពប្រាក់ខែ និងថវិការវាងស្ថាប័នជាតិ និងអន្តរជាតិ។ វិសមភាពដ៏ធំបែបនេះ គឺដូចជាការបន្ថែមលើភាពមិនគោរពចំពោះតម្លៃការងាររបស់បុគ្គលិកខ្មែរ ឬអង្គការខ្មែរ។ វិសមភាពនៃការចំណាយ ត្រូវបានរិះគន់ជាពិសេសចំពោះការខ្ជះខ្ជាយ។ ទាំងបុគ្គលិកទីភ្នាក់ងារជំនួយខ្មែរ និងបរទេសបានប្រាប់យើងថា ពួកគេអាក់អន់ចិត្ត ដោយឃើញថវិកាត្រូវបានចំណាយខ្ជះខ្ជាយ ឬចំណាយលើ "ការរស់នៅបែបទំនើប"។ បុគ្គលិកម្នាក់បានហៅការចំណាយបែបនេះថា "អំពើពុករលួយផ្លូវចិត្ត" ចំណែកបុគ្គលិកម្នាក់ទៀត បានហៅថា ជាការប្រព្រឹត្តិប្រាសចាកសីលធម៌។

"សមាជិកសហគមន៍ផ្តល់ជំនួយអន្តរជាតិ កំពុងចំណាយលុយច្រើនជ្រុលលើគ្នាឯង លើរបៀបរស់នៅដ៏ប្រសើររបស់ពួកគេ ប្រាក់ខែដ៏ហូរហៀរ និងឧបករណ៍ប្រើប្រាស់ប្រណីតៗ ដូចជា ឡានជាដើម ចំណែកអ្នកដែលធ្វើការនៅទីនេះ ហូបចុកមិនគ្រប់គ្រាន់ឡើយ។ មានការចំណាយផ្សេងៗច្រើនពេក និងចំណាយខ្ជះខ្ជាយ..... ជារឿយៗ ជំនួយគឺសម្រាប់ការលំអ"។ *(បុគ្គលិកខ្មែរម្នាក់ ធ្វើការជាមួយអង្គការផ្តល់ជំនួយមួយ នៅភ្នំពេញ)* ។

"វាជាការចំណាយលុយខ្ជះខ្ជាយលើការរស់នៅបែបទំនើប ហើយមិនចំណាយលើប្រជាជនខ្មែរ។ លុយដែលបានចំណាយលើប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ ឬឡាន និងប្រាក់ខែ អាចជួយកុមារកម្ពុជាជាច្រើននាក់.....។ ពួកគេកំពុងបោកប្រាស់ លុយមិនបានធ្លាក់ទៅដល់ដៃកុមារទេ វាជាអំពើពុករលួយមួយប្រភេទ.....។ ពួកគេនិយាយថា លុយហ្នឹងយកមកជួយប្រទេសនេះ ប៉ុន្តែ [អង្គការអន្តរជាតិ] បានប្រាក់ខែ២០០០ដុល្លារក្នុងមួយខែ ព្រមទាំងប្រាក់ឧបត្ថម្ភប្រចាំថ្ងៃចំនួន២០០ដុល្លារ ក្នុងមួយថ្ងៃ ការថែទាំកូន និងឡាន។ល។ ខ្ញុំចង់ឱ្យអង្គការអន្តរជាតិបង្ហាញពីថ្លៃចំណាយផ្សេងៗរបស់ពួកគេ"។ *(ប្រធានអង្គការក្នុងស្រុកម្នាក់ អាយុ៣០ឆ្នាំ ខេត្តបាត់ដំបង)* ។

"ប្រាក់ខែរវាងអង្គការជាតិ និងអង្គការអន្តរជាតិ ខុសគ្នាឆ្ងាយណាស់។ ប្រាក់ខែអ្នកបើកបររបស់អង្គការអន្តរជាតិ ស្មើនឹងប្រាក់ខែរបស់ប្រធានអង្គការក្នុងស្រុកមួយ"។ *(បុរសអាយុ៣០ឆ្នាំម្នាក់ ជាប្រធានអង្គការក្នុងស្រុកមួយ)* ។

"គួរតែកំណត់ពន្ធលើចំនួនប្រាក់ខែ ដែលអង្គការមិនមែនរដ្ឋាភិបាលត្រូវបើកឱ្យបុគ្គលិករបស់ខ្លួន។ មានការកើនឡើងនៃការបាត់បង់បុគ្គលិកដែលមានជំនាញ ដោយហេតុថា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក កសាងសមត្ថភាពរបស់បុគ្គលិក ប៉ុន្តែក្រោយមក ពួកគេរត់ទៅធ្វើការជាមួយអង្គការអន្តរជាតិ ដែលពួកគេអាចបានប្រាក់ខែច្រើនជាង។ ម្ចាស់ជំនួយគួរតែឱ្យលុយស្មើគ្នា មិនថាអង្គការតូច ឬអង្គការធំទេ"។ *(ស្ត្រីអាយុ៥០ឆ្នាំម្នាក់ ជាប្រធានអង្គការក្នុងស្រុកដែលធ្វើការលើវិស័យអប់រំ)* ។

"ពួកគេចំណាយលុយយ៉ាងច្រើនទៅលើឡានឡង់គ្រូស័រ ហើយនៅពេលដែលយើងដាក់សំណើទៅពួកគេ ដើម្បីសុំសាំងម៉ូតូ ពួកគេប្រាប់យើងថា តម្លៃសាំងនោះខ្ពស់ជ្រុល"។ *(បុរសអាយុ៣០ឆ្នាំម្នាក់ ជាប្រធានអង្គការក្នុងស្រុកមួយ)* ។

### *ការឆ្លុះបញ្ចាំងរបស់សមាជិកក្រុមអ្នកស្តាប់មតិយោបល់*

បញ្ហាការបង្ខំឱ្យអនុវត្តតម្លៃ ឬទស្សនៈរបស់បស្ចឹមប្រទេស ទៅលើវប្បធម៌មួយទៀត មិនបានបកស្រាយច្បាស់លាស់ ដោយសមាជិកក្រុមអ្នកស្តាប់មតិយោបល់ទេ។ ខណៈដែលមនុស្សមួយចំនួន ដែលយើងបានស្តាប់ បានត្អូញត្អែរអំពីបញ្ហានេះ ថាជាការបង្ខំពីអ្នកខាងក្រៅ មនុស្សមួយចំនួនទៀតបានយល់ស្របជាមួយការបញ្ចូលទស្សនៈទាំងនេះ។ ចំពោះបញ្ហាលើកកំពស់ការយល់ដឹងអំពីយេនឌ័រ និងការផ្តល់ភាពក្លាហាន មានសំណួរបានលើកឡើងថា តើការបង្រៀនសិទ្ធិស្ត្រី គឺជាទស្សនៈរបស់បស្ចឹមប្រទេស ឬជាទស្សនៈសិទ្ធិមនុស្ស ដែលឆ្លងផុតពីឧបសគ្គនៃវប្បធម៌?

ទោះបីជាយ៉ាងណាក៏ដោយ មានការព្រមព្រៀងមួយចំនួនថា នៅក្នុងករណីភាគច្រើន ដែល "ទស្សនៈរបស់បស្ចឹមប្រទេស" ត្រូវជំរុញ គេពុំសូវឃើញមានការជំទាស់ច្រើនលើទស្សនៈនោះទេ (ដូចជា សហគមន៍ព្រៃឈើ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការលើកកំពស់ការយល់ដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍) ផ្ទុយទៅវិញ មានការមិនយល់ស្របពីរបៀបបញ្ចូលទស្សនៈទាំងនោះ និងពេលវេលាដែលគំនិតផ្តួចផ្តើមជំនួយត្រូវបានផ្តល់ ដើម្បីផ្លាស់ប្តូរបទដ្ឋានសង្គម និងវប្បធម៌ដែលមានស្រាប់ទៅវិញទេ។ អ្នកដែលបានត្អូញត្អែរអំពីគំរោងទាំងនោះ ជាទូទៅបានយល់ស្របថា ប្រសិនបើមានការលៃលកពេលវេលាច្រើន ការផ្លាស់ប្តូរទៅរកទស្សនៈវប្បធម៌ ឬសង្គមថ្មីមួយនឹងអាចសម្រេចបានល្អជាងនេះ។ មានការសង្កត់ធ្ងន់ថា នៅពេលធ្វើការជំរុញគំរោង ដែលជំទាស់នឹងបទដ្ឋានសង្គម និងវប្បធម៌ តម្រូវឱ្យមានដំណើរការ "មួយជំហានម្តងៗ" ពាក់ព័ន្ធនឹងការអប់រំ និងលើកកំពស់ការយល់ដឹងដល់អ្នកពាក់ព័ន្ធទាំងអស់។ សមាជិកក្រុមអ្នកស្តាប់មតិយោបល់ម្នាក់ បានកត់សម្គាល់ថា "ការបណ្តុះបណ្តាលមួយចំនួនរបស់យើង ដូចជា ការបណ្តុះបណ្តាលអំពីអំពើហិង្សាលើគ្រួសារ ត្រូវការពេលវេលាច្រើនមួយជំហានម្តងៗ ពីព្រោះ [ប្រជាជន] នឹងមិនងាយយល់បានភ្លាមៗទេ"។

បញ្ហានៃវិសមភាពលើប្រាក់ខែ និងប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ រវាងបុគ្គលិកខ្មែរ និងបុគ្គលិកបរទេស គឺជាបញ្ហាចម្រូង

ចម្រាស់ខ្លាំង។ នៅពេលដែលសមាជិកក្រុមអ្នកស្តាប់មតិយោបល់ម្នាក់ យល់ស្របជាមួយទស្សនៈរបស់អ្នកភូមិ នៅកម្ពុជាថា លុយត្រូវបានចំណាយខ្ជះខ្ជាយដោយអង្គការអន្តរជាតិនោះ ជនជាតិខ្មែរម្នាក់ដែលធ្វើការជាមួយអង្គការអន្តរជាតិមួយ បានលើកឡើងថា "ពួកគេប្រណែន ដោយសារយើងបានប្រាក់ខែខ្ពស់ជាង" ។

បញ្ហាអាកប្បកិរិយាមិនសមស្របផ្នែកវប្បធម៌ ឬមិនចេះគោរពគ្នា ត្រូវបានលើកឡើងដោយមនុស្សមួយចំនួនតូច តែមានបំណងខ្លាំងក្នុងការលើកឡើង។ ដោយក្រុមអ្នកស្តាប់មតិយោបល់នីមួយៗ មានសមាជិកបរទេសម្នាក់ ពួកគេមានក្តីក្លាហានជាពិសេស ក្នុងការលើកចំណុចនេះនៅចំពោះមុខជនបរទេស។ មានតែជនជាតិខ្មែរដែលនិយាយដោយចំហប៉ុណ្ណោះ ដែលហ៊ានលើកឡើងអំពីបញ្ហាទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលបានស្តាប់បន្ថែមទៀត យើងបានដឹងច្បាស់ថា ការលើកឡើងនេះ មិនមែនជាទស្សនៈឯកោឡើយ។ នៅពេលដែលត្រូវបានសួរថា តើជម្រើសអ្វីខ្លះ ដែលបុគ្គលិកខ្មែរគិតថានឹងជ្រើសរើស ដើម្បីដោះស្រាយបញ្ហាល័ក្ខខ័ណ្ឌ និងវិសមភាពនៃការធ្វើការជាមួយអង្គការអន្តរជាតិ ដែលគ្មានការគោរពចំពោះបុគ្គលិកខ្មែរ បុគ្គលិកមួយចំនួនបានលើកឡើងថា ពួកគេយល់ថាពួកគេគ្មានសិទ្ធិអំណាចក្នុងការប្តឹង។ បុគ្គលិកអង្គការក្នុងស្រុកម្នាក់បានបញ្ជាក់ថា "ពួកគេ (បុគ្គលិកខ្មែរនៅក្នុងអង្គការអន្តរជាតិ) ស្ថិតក្រោមសម្ពាធ ពីព្រោះពួកគេត្រូវការលុយ ការងារ។ គ្រប់គ្នាមានការឈឺចាប់ តែពួកគេត្រូវការលុយ ដើម្បីជួយផ្គត់ផ្គង់គ្រួសារ ដូច្នេះពួកគេត្រូវតស៊ូធ្វើដូចនេះ ដូចឆ្នា ពួកគេគ្មានជម្រើសផ្សេងទេ។ បណ្តាញនៃអង្គការមិនមែនរដ្ឋាភិបាល មានន័យថា ប្រសិនបើអ្នកត្រូវបានបណ្តេញចេញពីការងារនៅកន្លែងណាមួយ អ្នកនឹងមិនអាចការងារជាមួយអង្គការបានទៀតឡើយ។ បើសិនជាខ្ញុំរាយការណ៍ប្រាប់អ្នក ខ្ញុំក៏គ្មានបានប្រយោជន៍អ្វីដែរ។ ដូច្នេះ នៅស្ងៀមស្ងាត់វាគ្រាន់បើជាងនិយាយចេញ" ។